ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jul-2013, 14:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី២០៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ហ្វីលីព រ៉ូជឺ *(Mr.Roge Phillips)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡៃ ជុនធី

លោកស្រី បេនី យេ *(Ms. Beini YE)*

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ស្ទីវ ហេដឌ័រ | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ីវ ហេងឆ៉ះ** (TCE-33)

សួរបន្តដោយលោក ឃីត វេយ៍ន័រ ផ្តើមពី..........................................................ទំព័រ ១៨

# កិច្ចដំណើរការនីតិវិធី

[០៩:០២:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្ម ស្ទីវ ហេដឌ័រ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅខាងក្រោមបន្ទប់សវនាការ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស្ទីវិន ហេដឌ័រ។ ហើយលោកមានវត្តមានរួចនៅក្នុងបន្ទប់សវនាការនេះ។ សម្រាប់សវនាការថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

បាទ សូមផ្អាកបន្តិចសិន។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

សូមជម្រាបសួរលោក លោកស្រីចៅក្រម។ មេធាវី សហព្រះរាជអាជ្ញា និងភាគីទាំងអស់នៅក្នុងសាលសវនាការ។ លោកប្រធាន សូមអភ័យទោសដែលខ្ញុំសូមនិយាយកាត់សហព្រះរាជអាជ្ញានៅពេលនេះ ប៉ុន្តែយើងមានសំណើជាបន្ទាន់មួយដោយផ្អែកលើព័ត៌មានថ្មីដ៏សំខាន់ ដ៏វិសាមញ្ញ។

ព័ត៌មានដែលយើងបានទទួលនៅក្នុងរយៈពេលមីនុត ប៉ុន្មានមីនុតខ្លីៗកាលពីម្សិលមិញនេះ។ ព័ត៌មាននេះមានផលប៉ះពាល់ដ៏សំខាន់ទៅលើសវនាការនេះ ហើយនិងទាក់ទងដោយផ្ទាល់ទៅនឹងសក្ខីកម្មរបស់លោក ហេងឌ័រ នោះដែរ។ ខ្ញុំសូមជម្រាបថា យើងខ្ញុំនឹងប្រើពេល១០នាទីរបស់តុលាការ ដោយសារបញ្ហានេះសំខាន់សម្រាប់យើងខ្ញុំ។ ដូច្នេះ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំលើកនូវសំណើបន្ទាន់នេះ។

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធានខ្ញុំសូមអភ័យទោស! ដោយខ្ញុំសូមកាត់ ដែលខ្ញុំ -- ដូច្នេះអ្វីដែលមេធាវីត្រូវធ្វើនោះគឺត្រូវជូនដំណឹងជាមុន មិនអាចមកកាត់ភ្លាមៗបែបនេះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៦:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អង្គជំនុំជម្រះសួរទៅលោក កូប៉េ មួយចំនួន ជាបឋមនោះថាតើនេះជាបញ្ហាដែលទាក់ទងនឹងសាក្សីនេះដែលត្រូវដោះស្រាយមុនគាត់អញ្ជើញមក ឬក៏ត្រូវដោះស្រាយក្នុងសវនាការអសាធារណៈ? វាអាចនឹងជួយបានប្រសិនបើលោកជូនដំណឹងទៅសហព្រះរាជអាជ្ញាជាមុន។ យើងអាចនឹងមានពេលវេលា ដើម្បីត្រៀមរៀបចំ។ សូមលោកបន្ថែមយោបល់លើបញ្ហានេះបន្តិច!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ហើយពីបញ្ហានេះចៅក្រម ខាតវ៉ាយថ៍។ គឺរហូតទាល់តែពេលចុងក្រោយ ដែលយើងពិភាក្សានៅក្នុងក្រុមគ្រួសាររបស់យើង -- ក្រុមមេធាវីរបស់យើងដែលទាក់ទងទៅនឹងព័ត៌មានដែលយើងទទួលបាននេះ។

[០៩:០៧:២៤]

ខ្ញុំយល់ថាឃើញថា វាអាចល្អបំផុតក្នុងការយើងដោះស្រាយបញ្ហានេះ ដោយអវត្តមានរបស់សាក្សីរូបនេះ។ ជាពិសេសសាក្សីរូបនេះមិនមែនជាបុគ្គលណាម្នាក់ ដែលថាអាចនឹងផ្លាស់ប្តូរជំហរសក្ខីកម្មរបស់គាត់ក្រោយពីស្តាប់អ្វីៗដែលយើងនិយាយនោះទេ។ ក៏ប៉ុន្តែបើសិនជាអង្គជំនុំជម្រះ--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើយើងអាចបន្តសវនាការអសាធារណៈ ហើយដើម្បីស្រាយ ឬក៏ធ្វើជាសាធារណៈ? ទាំងសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះមិនមានគំនិតថាតើយើងត្រូវដោះស្រាយម្តេច។ ដូច្នេះត្រូវតែមេធាវី កូប៉េខ្លួនឯងជាអ្នកឲ្យយល់។

**លោក វ៉ិចទ័រ កូប៉េ៖**

តាមពិតយើងខ្ញុំចង់ដោះស្រាយបញ្ហានេះក្នុងសវនាការជាសាធារណៈ ពីព្រោះពីម្សិលមិញក៏យើងធ្វើជាសាធារណៈដែរ។ ដូច្នេះយុត្តិធម៌ត្រូវតែរកឲ្យឃើញ ហើយត្រូវតែបង្ហាញឲ្យឃើញថា ពិតជាបានរកឃើញជាសាធារណៈនោះផង។ ដូច្នេះ ខ្ញុំស្នើឲ្យការដេញដោលនេះក្នុងសាធារណៈ។

[០៩:០៨:៤៥]

**លោក ឃីត រេយ៍ន័រ៖**

នេះមិនមែនជាសំណើដែលត្រូវធ្វើដោះស្រាយក្នុងសាធារណៈទេ ហើយអ្វីជានីតិវិធីត្រឹមត្រូវហ្នឹង គឺថាគប្បីឲ្យសាក្សីនៅខាងក្រៅ ហើយខ្ញុំឮថា នេះគឺជាទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលត្រូវធ្វើបែបនេះ។ បើសិនជានេះជាទឡ្ហីករណ៍ផ្លូវច្បាប់ គឺថាដោយមានមេធាវីជាអ្នកលើកឡើងនូវសំណើនេះ។ ហើយខ្ញុំសូមជម្រាបថា សំណើដូច្នេះមិនត្រូវដោះស្រាយនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាទាក់ទងទៅបញ្ហានេះ គឺទាក់ទងទៅនឹងប្រធានបទជាសក្ខីកម្មដែលអាចនឹងកោះអញ្ជើញបុគ្គលម្នាក់នោះមក មិនទាក់ទងនឹងសាក្សីម្នាក់នេះដែលត្រូវបង្ហាញនៅពេលនេះទេ។

[០៩:០៩:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:១២]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីស្តាប់សំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា លើបញ្ហាប្រធានបទដែលត្រូវជជែកពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះយល់ឃើញថាបញ្ហានេះត្រូវតែធ្វើជាអសាធារណៈ។ ដូច្នេះអង្គជំនុំជម្រះឲ្យលោក ស្ទីវ ហេដឌ័រ ចាកចេញពីបន្ទប់សវនាការនេះសិន ទៅកាន់បន្ទប់រង់ចាំ ហើយនិងអង្គជំនុំជម្រះនឹងអញ្ជើញលោកត្រឡប់ចូលមកកាន់បន្ទប់សវនាការនេះវិញនៅក្រោយ

ពេលដែលអង្គជំនុំជម្រះបានសម្រេចលើពិភាក្សាលើបញ្ហាប្រធានបទដែលលើកឡើងដោយមេធាវីការពារក្តី កូប៉េ នេះ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ -- ផ្នែកខាងមន្ត្រីរដ្ឋបាលតុលាការបិទនូវវីដេអូហើយនិងផ្តាច់នូវប្រព័ន្ធសំឡេងទៅខាងក្រៅបន្ទប់សវនាការនេះ!

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនសាធារណជនផងដែរថា កិច្ចដំណើរការសវនាការជាសាធារណៈ អង្គជំនុំជម្រះនឹងបន្តធ្វើបន្ទប់ពីអង្គជំនុំជម្រះដោះស្រាយនូវបញ្ហានៅចំពោះមុខដែលលើកឡើងដោយលោកមេធាវីអន្តរជាតិ គឺលោក វ៉ិចទ័រ កូប៉េ ការពារក្តីលោក នួន ជា។ ដោយហេតុថាបញ្ហានេះគឺលោកមេធាវី គាត់បានលើកឡើងភ្លាមបន្ទាន់នៅពេលនេះ ដោយគាត់មិនបានជូនដំណឹងជាមុនដល់អង្គជំនុំជម្រះ និងដល់ភាគីម្ខាងទៀតនៃរឿងក្តីនេះទេ។

[០៩:១៣:០៨]

សូមអញ្ជើញលោក ស៊ីវ ហេងឆ័រ!

សូមអញ្ជើញលោកស្រីចៅក្រម តើមានអ្វីចង់បន្ថែមទេ?

បិទវីដេអូវាំងននបាទ!

*(សាក្សីចេញពីបន្ទប់សវនាការ)*

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

ខ្ញុំចង់បន្ថែមថា កាលណាយើងមើលឃើញច្បាស់ថា អាចបន្តជាសាធារណៈវិញ យើងនឹងប្រកាសបែបនោះ។ ហើយទី២ សាធារណជននឹងត្រូវបញ្ជូនដំណឹងថាតើយើងបញ្ជូនទៅដល់សាធារណជនមុនពេលដែលយើងបានដំណឹងថាអាចនឹងសាធារណៈពេលណាបាននោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយច៍--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោក វ៉ិចទ័រ កូប៉េ ដោយសារបញ្ហាបច្ចេកទេសដែលត្រូវចំណាយពេលវេលាបន្តិចក្នុងការផ្តាច់ប្រព័ន្ធសំឡេងទៅខាងសាធារណជន។

*(សម្រាករយៈពេលខ្លី)*

[០៩:១៤:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមជម្រាបជូនដល់ភាគីផងដែរថា ដោយសារបញ្ហាបច្ចេកទេស ដូច្នេះទំនាក់ទំនងរវាងអង្គជំនុំជម្រះជាមួយនឹងក្រុមផ្នែកខាងបកប្រែភាសាហ្នឹង ដោយមានរបាំងវាំងននដូច្នេះ គឺមិនអាចមើលឃើញ ហើយនិងងាយស្រួលក្នុងការបកប្រែភាសាបានទេ។ ដូច្នេះ អង្គជំនុំជម្រះមានការកែប្រែបន្តិចតាមអ្នកបច្ចេកទេសនិងខាងរដ្ឋបាល គឺស្នើសុំបើកចំហវាំងននឡើងវិញដើម្បីបង្កលទ្ធភាពឲ្យខាងអ្នកបកប្រែ ភាសាអាចមើលឃើញនូវកិច្ចដំណើរការប្រព្រឹត្តទៅនៃបន្ទប់សវនាការនេះ។ ហើយពេលវេលាបន្តិច ទៀតនេះអង្គជំនុំជម្រះនឹងបង្គាប់ឲ្យរូតវាំងននឡើងវិញក្រោយពេលដែលខាងសន្តិសុខបានសម្រប សម្រួលអញ្ជើញសាធារណជនចាកចេញពីបន្ទប់សាធារណៈ។

[០៩:១៥:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាបញ្ហាបច្ចេកទេសបន្ថែមមួយទៀត ដោយហេតុថាប្រព័ន្ធសោតទស្សន៍ត្រូវការកាត់ផ្តាច់នោះក៏គ្មានសំឡេងដែលបញ្ជូនទៅបន្ទប់ឃុំខ្លួនខាងក្រោមរបស់លោក នួន ជា ដែរ។ អ៊ីចឹងលោក នួន ជា មិនអាចទាក់ទងជាមួយខ្ញុំបានដែរ ហើយយើងក៏មិនអាចប្រាស្រ័យជាមួយគាត់បាន។

**ប្រធានអង្គជំនុំ៖**

បញ្ហាកន្លងមកយើងធ្លាប់បានដោះស្រាយហើយ។ អំមិញ គឺយើងផ្តាច់ប្រព័ន្ធទាក់ទងតែទៅសាធារណជនទេ។ ចំណែកឯបញ្ហាសំឡេង និងរូបភាពភ្ជាប់រវាងបន្ទប់សវនាការ ជាមួយនឹងលោក នួន ជា ដែលគាត់មានសិទ្ធិក្នុងការតាមដានកិច្ចដំណើរការនីតិវិធីសវនាការហ្នឹងគឺត្រូវតែប្រព្រឹត្តទៅធម្មតា។ បានហើយនៅ?

*(សម្រាករយៈពេលខ្លី)*

[០៩:១៩:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ អាចចាប់ផ្តើមបានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ព័ត៌មានដែលយើងបានទទួលកាលពីម្សិលមិញនោះគឺស្ថិតនៅក្នុងទម្រង់ជា អ៊ីម៉ែល មកពីលោក រ៉ប់ លឹមគិន *(Rob Lemkin)* ដូចដែលអង្គជំនុំជម្រះស្គាល់ហើយគាត់គឺ

ជាអ្នកសហនិពន្ធ ឆាកក្នុងខ្សែភាពយន្តសត្រូវរបស់ប្រជាជនដែលមានចំណងជើងថា "១ថ្ងៃនៅទួល-ពោធិជ្រៃ" អ៊ីម៉ែលនេះគាត់បានប្រគល់ឲ្យសហសេវិករបស់ខ្ញុំ ម៉ែខល ផេសមិន ដែលបានបញ្ជូនទៅឲ្យជំនាញការច្បាប់ ហើយជំនាញការច្បាប់បញ្ជូនមកឲ្យខ្ញុំ។ អ៊ីម៉ែលនោះ គឺគ្មានតាមការស្នើសុំពីភាគីទេ ក៏ប៉ុន្តែខ្ញុំបានផ្ញើជូនទៅអង្គជំនុំជម្រះ និងភាគីទាំងអស់នូវអត្ថបទអ៊ីម៉ែលនេះ ហើយអត្ថបទទាំងស្រុងនោះមានខ្លឹមសារដូចតទៅនេះ៖

[០៩:២០:០៥]

"លោក វ៉ិចទ័រ ជាទីរាប់អាន តាមរយៈការអានរឿងរ៉ាវកាសែតភ្នំពេញប៉ុស្តិ៍ក្នុងដំណើរការសវនាការពីម្សិលមិញទំនងជាមានការយល់ច្រឡំពីអ្វីដែលលោក នួន ជា និយាយនៅក្នុងឌីវីឌីរបស់យើង។ គាត់មិនបានយល់ស្របថាមន្ត្រីកំពូល លន់ នល់ ត្រូវបានគេសម្លាប់នោះទេ គាត់និយាយថា ពាក់ព័ន្ធកណ្តាលនៃគណៈរដ្ឋមន្ត្រីរបស់ លន់ នល់ ហើយនិងមន្ត្រីកំពូលៗត្រូវបានសម្រេចត្រឹមត្រូវតាមគោល-ការណ៍តុលាការយោធារបស់បដិវត្តន៍។ លោក នួន ជា មិនបានចូលរួមក្នុងការសម្រេចនោះទេ ហើយវិទ្យុភ្នំពេញបានផ្សាយជាផ្លូវការថា ការកាប់សម្លាប់នៅពេលនោះផងដែរ ហើយបានផ្តល់នូវមូលហេតុដូចលោក នួន ជា បានបញ្ជាក់នៅក្នុងឌីវីឌីរបស់យើងដែរ។ លោក នួន ជា មិនបានទទួលស្គាល់ថាមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះការកាប់សម្លាប់សមាជិកគណៈរដ្ឋមន្ត្រី លន់ នល់ ទេ ក៏ប៉ុន្តែគាត់បានអះអាងពីមូលហេតុនោះថាត្រឹមត្រូវ។ តាមពិតមូលហេតុមិនមានអ្វីខុសពីអ្វីដែលសហរដ្ឋអាមេរិកប្រកាសសម្លាប់ ប៊ិនឡាឌិន នោះទេ។ ខ្ញុំសង្ឃឹមថាភស្តុតាងនេះមិនមានលក្ខណៈជាការចោទប្រកាន់ដែលមានតម្លៃអ្វីធំធេងនោះទេ។ ដូច្នេះវាមានការបញ្ជាក់នៅក្នុងករណីខ្សែភាពយន្តរបស់យើង។ ប៉ុន្តែផ្ទុយទៅវិញទាក់ទងទៅនឹងទទួលពោធិ៍ជ្រៃនេះ គឺជាបញ្ហាសម្លាប់ដែលធ្វើឡើងដោយ រស់ ញឹម មិនមានក្រោមមជ្ឈិមនោះទេ។ យើងបានប្រមូលភស្តុតាងដ៏ច្រើនអំពីកម្មវិធីរបស់ រស់ ញឹម ប៉ុន្តែយើងមិនមានលទ្ធភាពបញ្ចប់ខ្សែភាពយន្តលើកទី២បានទេ ដោយសារថា ថេត សម្បត្តិ បានទៅសហរដ្ឋអាមេរិក ដោយសារមូលហេតុផ្ទាល់ខ្លួន។ ដោយក្តីគោរព រ៉ប់ លឹមគិន"។

[០៩:២២:១៥]

លោក លោកស្រីចៅក្រម លោកប្រធានជាទីគោរព! ព័ត៌មាននេះជាក់ស្តែងនេះ គឺមានសារៈសំខាន់បំផុត។ ខ្ញុំសូមអនុញ្ញាតពីមូលហេតុអ្វីដែលថា វាទាក់ទងទៅនឹងសក្ខីកម្មរបស់លោក ហេដឌ័រ។ ជាបឋមលោក លឹមគិន អាចជាអ្នកមាននៅព័ត៌មានដែលទាក់ទងផ្ទាល់ទៅនឹងភស្តុតាងដោះបន្ទុកសម្រាប់

នួន ជា ទាក់ទងទៅនឹងបទចោទប្រកាន់អំពីទួលពោធិ៍ជ្រៃ។ តាមពិត លឹមគិន មានព័ត៌មាន។ ប្រសិនបើវាបង្ហាញពីអ្វីដូចដែលគាត់អះអាង វាអាចបញ្ជាក់គោលជំហរដ៏រឹងមាំដែលយើងប្រកាន់ជាច្រើនខែមក ហើយដែលរាប់បញ្ចូលទាំងអ្វីដែលយើងដាក់ទឡ្ហីករណ៍ពីរថ្ងៃកន្លងមកនេះឯង។ ទោះបីជាទាក់ទងទៅនឹង រស់ ញឹម ដែលមានការទទួលខុសត្រូវលើហេតុការណ៍នៅទួលពោធិ៍ជ្រៃ យើងត្រូវតែពិនិត្យដេញដោលចំពោះអង្គជំនុំជម្រះផងដែរ។

[០៩:២៣:១៣]

ចំណុចទី២ ភស្តុតាងដែលលោក លឹមគិន គាត់ថាមានទាក់ទងទៅនឹង រស់ ញឹម ដោយផ្ទាល់ជាអ្នកសម្របសម្រួលទាក់ទង -- ដែលគាត់ប្រមូលរយៈពេលជាច្រើន ច្រើនឆ្នាំអំពីការរចនាសម្ព័ន្ធបញ្ជាប្រជាធិបតេយ្យរបស់ភូមិភាគ មេភូមិភាគ ព័ត៌មាននេះទាក់ទងដោយផ្ទាល់ទៅនឹងលោក ហេងឌ័រ ដែលជាអ្នកវិភាគជាបឋមលើការងារសំខាន់ៗទៅលើការអះអាង។ ដូច្នេះយើងឃើញថា បញ្ជីដែលសហព្រះរាជអាជ្ញាបានផ្តល់ឲ្យយើងម្សិលមិញ គឺមានការសម្ភាសជាច្រើនជាមួយនឹងកម្មាភិបាលមកពីភូមិភាគពាយ័ព្យ។ លោក ហេងឌ័រ គឺទំនងជាមានព័ត៌មានក្នុងការផ្តល់សក្ខីកម្មដែលទាក់ទងទៅនឹងអង្គហេតុដូចលោក លឹមគិន ដែរ។

ចំណុចទី៣ លោក លឹមគិន អាចនឹងមានព័ត៌មានដោយផ្ទាល់ដែលជាដោះបន្ទុកកូនក្តីរបស់ខ្ញុំទាក់ទងទៅនឹងការចោទប្រកាន់ថាមានកាប់សម្លាប់មន្ត្រីកំពូល លន់ នល់ ដូចដែលសហព្រះរាជអាជ្ញានិយាយម្សិលមិញថា ស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះ។

[០៩:២៤:២៤]

ចំណុចសំខាន់ទៀត គឺថាលោក លឹមគិន អាចនឹងពន្យល់វីដេអូ ដែលគាត់បានផលិតនោះ ដែលសហព្រះរាជអាជ្ញាពឹងផ្អែកលើជាភស្តុតាងដាក់បន្ទុកនោះ តាមពិតនោះជាភស្តុតាងដោះបន្ទុកទេ។ សក្ខី-កម្មនោះ គឺអាចនឹងគាំទ្រនូវអះអាងមេធាវី ខៀវ សំផន ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃខ្សែវីដេអូ ហើយយើងបញ្ជាក់ពីរថ្ងៃមកហើយទាក់ទងទៅនឹងតម្លៃភស្តុតាងនៃវីដេអូនោះ ជាពិសេសគឺមួយផ្នែកនៃខ្សែអាត់ជាច្រើនរាប់ពាន់ម៉ោងឯណោះដែលយើងនឹងត្រូវពិនិត្យមើល។

ដូច្នេះ ចំណុចទី១ យើងសូមឲ្យអង្គជំនុំជម្រះទទួលយកអ៊ីម៉ែលនេះ ថាជាភស្តុតាង អនុលោមតាមវិធាន៨៧ កថាខណ្ឌទី៤។ ដោយសារថា យើងមិនអាចរកបានពីមុន ហើយឯកសារអ៊ីម៉ែលនេះវាពាក់ព័ន្ធ ហើយវាទាក់ទងដូចទៅនឹងសៀវភៅលោក ថេត សម្បត្តិ នោះដែរ ដែលសហព្រះរាជអាជ្ញា

យកជាបង្អែកនៃការចោទប្រកាន់។ ចំណុចទី២ សំណើសុំឲ្យអង្គជំនុំជម្រះកោះលោក លឹមគិន មកបង្ហាញនិងធ្វើសក្ខីកម្មចំពោះអង្គជំនុំជម្រះតាមវិធាន៨៣។ ទី៣ យើងសូមឲ្យបង្អង់សក្ខីកម្មរបស់លោកហេងឆ័រ រង់ចាំរហូតតែមានលទ្ធផលនៃការស៊ើបអង្កេតករណីលោក លឹមគិន ជាចប់សិន។ ការផ្អាកនេះគឺមានសំខាន់ណាស់ ដើម្បីឲ្យយើង តុលាការមានកំណត់ត្រាត្រឹមត្រូវ គ្រប់គ្រាន់មុននឹងសាកសួរលោកហេងឆ័រ ពីប្រធានបទដែលពាក់ព័ន្ធទៅនឹងបញ្ហាពាក់ព័ន្ធដ៏សំខាន់នេះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៧:២៤]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាសូមអញ្ជើញអង្គុយចុះសិន!

បន្ទាប់ពីការស្តាប់នូវការលើកឡើងនូវសំណើសុំរបស់លោក វ៉ិចទ័រ កូប៉េ ដែលជាមេធាវីអន្តរ-ជាតិការពារក្តីឲ្យលោក នួន ជា។ អង្គជំនុំជម្រះយល់ឃើញថា បញ្ហាដែលលើកឡើងនេះ គឺជាសំណើសុំឲ្យទទួលយកនូវឯកសារថ្មី និងស្នើសុំឲ្យអង្គជំនុំជម្រះហ្នឹងស្តាប់សក្ខីកម្មសាក្សីថ្មីបន្ថែមទៀត ដោយផ្អែកលើអ៊ីម៉ែលដែលគាត់ទើបតែទទួលបានយប់មិញនេះ ដោយសារបញ្ហានេះ វាទំនងជាមិនមានអ្វីដែលត្រូវធ្វើជាអសាធារណៈនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថាកែប្រែផ្លាស់ប្តូរនូវកិច្ចពិភាក្សាលើសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ ដែលបានលើឡើងនេះធ្វើជាសាធារណៈវិញ ទី១។

ហើយបញ្ហាទី២ គឺស្នើសុំលោក វ៉ិចទ័រ កូប៉េ នៅពេលដែលអង្គជំនុំជម្រះរៀបចំដំណើរការជាសាធារណៈវិញ សូមឲ្យលោកបង្ហាញនូវសំណើសុំ ហើយនិងរបស់លោកនូវមូលហេតុទាំងឡាយដែលលោកបានលើកឡើងអម្បាញ់មិញនេះវិញ ជាសាធារណៈ ដើម្បីឲ្យបានផ្តល់នូវព័ត៌មានហ្នឹងទូលំទូលាយដល់សាធារណជនបានដឹងអំពីបញ្ហានេះ។ ជៀសវាងមានការខុសឆ្គងនៅក្នុងកិច្ចដំណើរការ។

[០៩:២៨:៥២]

បាទ បង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់នូវសំឡេងរូបភាពទៅសាធារណជនឡើងវិញ ដោយអង្គជំនុំជម្រះបានសម្រេចរួចហើយថាធ្វើជាសាធារណៈ។ ហើយផ្នែកខាងសន្តិសុខអាចអញ្ជើញឲ្យសាធារណជនអាចចូលមកស្តាប់នៅក្នុងបន្ទប់សវនាការ នៅក្នុងសាលសវនាការសាធារណៈនេះបានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមបន្តិចទេលោកប្រធាន តើលោកជម្រាបខ្ញុំថា ខ្ញុំប្រើឈ្មោះគាត់ទាំងស្រុង ឬក៏ថាជាឈ្មោះលេខកូដ។ ខ្ញុំគ្រាន់តែចង់បានយោបល់ពីអង្គជំនុំជម្រះទេ បាទ។

**ប្រធានអង្គជំនុំ៖**

មានលេខកូដហើយ អានេះជាគោលការណ៍យើងត្រូវរក្សាការសម្ងាត់។ បញ្ហា បើសិនជាលោកមានកូដ លោកគប្បីប្រើលេខកូដហើយ ព្រោះអង្គជំនុំជម្រះកំណត់ក្នុងគោលបំណង គឺអនុវត្តនូវវិធានការការពារ។ ទោះបីយ៉ាងណាក៏ដោយ យើងត្រូវតែមានភាពហ្មត់ចត់នៅក្នុងការអនុវត្តនូវវិធានការនេះ រហូតដល់នាទីចុងក្រោយនៃការស្តាប់សក្ខីកម្មរបស់គាត់។

*(សម្រាករយៈពេលខ្លី)*

មិនទាន់ប្រញាប់ប្រញាល់ពេកទេលោក វ៉ិចទ័រ កូប៉េ! លោករៀបចំឲ្យបានល្អទៅ ប្រហែលរយៈពេលប្រហែល៥នាទីទៀត ទើបខាងបច្ចេកទេសអាចរៀបចំបន្តភ្ជាប់នូវប្រព័ន្ធសំឡេងនិងរូបភាពទៅខាងសាធារណជនបាន។

*(សម្រាករយៈពេលខ្លី)*

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[០៩:៣២:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ព័ត៌មានដែលយើងបានទទួលពីកាលម្សិលមិញនោះ គឺស្ថិតទម្រង់ជាឯកសារអ៊ីម៉ែល ដែលផ្ញើមកពីសាក្សីម្នាក់ដែលយើងហៅថា TCW-382។ ដូចដែលអង្គជំនុំជម្រះជ្រាបហើយ TCW-382 បានសរសេរឈ្មុតឆាកនៅក្នុងរឿងខ្លាំងរបស់ប្រជាជន ដែលមានចំណងជើងថា “១ថ្ងៃនៅទួលពោធិ៍ជ្រៃ”។ អ៊ីម៉ែលនេះបានបញ្ជូនមកសហសេវិករបស់ខ្ញុំ *ម៉ីស្សី* ផេសមិន ដែលបានបញ្ជូនអ៊ីម៉ែលនេះទៅជំនាញការច្បាប់ ដែលអ្នកនោះបញ្ជូនមកឲ្យខ្ញុំ។ សាក្សីនេះគឺយើងមិនបានស្នើសុំឲ្យគាត់ផ្ញើទេ ហើយយើងផ្ញើអ៊ីម៉ែលនេះទាំងស្រុងទៅអង្គជំនុំជម្រះ និងភាគីទាំងអស់។ អត្ថបទនៃអ៊ីម៉ែលរបស់ TCW-382 នេះគឺដូចខាងក្រោមនេះ៖

“វ៉ិចទ័រ ជាទីរាប់អាន, តាមការអានរឿងរ៉ាវនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ អំពីសវនាការពីម្សិលមិញនេះ ខ្ញុំយល់ឃើញថាមានការយល់ច្រឡំអំពីអ្វីដែល នួន ជា បាននិយាយនៅក្នុងឌីវីឌីរបស់យើង។

គាត់មិនបាន គឺមិនបានយល់ថាមន្ត្រីកំពូលៗរបស់ លន់ នល់ ត្រូវបានសម្លាប់នោះទេ។ អ្វីដែលគាត់បាននិយាយ គឺគណៈរដ្ឋមន្ត្រីប្រហែលជា១២នាក់ ហើយនិងមេដឹកនាំកំពូលត្រូវបានកាត់ទោសតាមច្បាប់ត្រឹមត្រូវរបស់បដិវត្តន៍ ហើយនិងកាត់ទោសប្រហារជីវិតដោយតុលាការយោធា ដែលតាមការចងចាំ នួន ជា មិនស្ថិតនៅក្នុងផ្នែកនោះទេ។ គួរតែកត់សម្គាល់ថា វិទ្យុភ្នំពេញដែលជាវិទ្យុផ្លូវការកាលនោះបានផ្សាយអំពីការប្រកាសអំពីការសម្លាប់ទាំងនេះនៅក្នុងពេលនោះដែរ ហើយបានបញ្ជាក់មូលហេតុដូច នួន ជា បញ្ជាក់នោះដែរ។ នួន ជា មិនបានទទួលស្គាល់ថាគាត់មានការទទួលខុសត្រូវផ្ទាល់អំពីការការសម្លាប់សមាជិកគណៈរដ្ឋមន្ត្រី លន់ នល់ នោះទេ។ តែការអះអាងនេះមានមូលហេតុត្រឹមត្រូវ។ តាមពិតមូលហេតុនេះមិនមានអ្វីខុសពីដែលសហរដ្ឋអាមេរិកប្រកាសសម្លាប់ ប៊ិនឡាដិន នោះទេ។ ខ្ញុំគិតថាតុលាការត្រូវតែបញ្ជាក់ឲ្យច្បាស់ថា ខ្សែភាពយន្តនេះមិនមានតម្លៃអ្វីជាការចោទប្រកាន់ខ្លាំងទេ គឺមានតម្លៃតិចតួចតែប៉ុណ្ណោះ។ ហើយ គាត់និយាយថាម្យ៉ាងវិញទៀត ទាក់ទងទៅនឹងពោធិ៍ជ្រៃ នេះជាការកាប់សម្លាប់ដែលបញ្ជាដោយ រស់ ញឹម មិនមែនបញ្ជាពីថ្នាក់មជ្ឈិមទេ។ យើងបានប្រមូលនូវភស្តុតាងដោយច្រើនអំពីកម្មវិធីរបស់ ញឹម – រស់ ញឹម ប៉ុន្តែឥឡូវនេះយើងមិនអាចបញ្ចប់ខ្សែភាពយន្តទី២បានទេ ដោយសារ ថេត -- ដោយសារសហអ្នកផលិតករមានកិច្ចការផ្ទាល់ខ្លួននៅសហរដ្ឋអាមេរិក។

[០៩:៣៦:០៨]

លោក លោកស្រីចៅក្រម ព័ត៌មាននេះជាព័ត៌មានថ្មី ហើយសំខាន់ណាស់ ហើយយើងនឹងពន្យល់ពីថាហេតុអ្វី និងតើវាពាក់ព័ន្ធទៅសក្ខីកម្មរបស់លោក ហេងឆ័រ ដូចម្តេច?

ទី១ សាក្សី TCW-382 នេះគឺមានភស្តុតាងដោះបន្ទុកដោយផ្ទាល់ទាក់ទងទៅនឹងលោក នួន ជា ទាក់ទងនឹងបទចោទនៅទួលពោធិ៍ជ្រៃ។ ប្រសិនបើតាមពិត សាក្សីរូបនេះមានព័ត៌មាន ហើយប្រសិនបើវាបង្ហាញថាបែបដូចដែលគាត់អះអាងមែន វានឹងគាំទ្រនឹងគោលជំហររបស់យើងដែលយើងបានធ្វើឡើងជាច្រើនច្រើនខែមកហើយ ដោយរាប់ទាំងសេចក្តីសន្និដ្ឋានរបស់យើង២ថ្ងៃមកហើយដែរ។ វាពាក់ព័ន្ធទៅនឹង រស់ ញឹម ដែលជាអ្នកទទួលខុសត្រូវលើហេតុនៅទួលពោធិ៍ជ្រៃ ដែលយើងបានស្វែងរកដេញដោលក្នុងសវនាការនេះ។

ទី២ សាក្សី TCW-283 អះអាងថា រស់ ញឹម បានស៊ីសង្វាក់នៅក្នុងគោល -- មុខតំណែងរបស់គាត់ទាក់ទងទៅនឹងរចនាសម្ព័ន្ធបញ្ជាជាច្រើនពេលរាប់មិនអស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងថ្នាក់តំបន់។ ព័ត៌មាននេះទាក់ទងដោយផ្ទាល់ទៅនឹងលោក ហេងឆ័រ ដែលជាអ្នកវិភាគជាបឋមលើការ

អះអាងនេះ។ យើងពិនិត្យឃើញថា បញ្ជីបទសម្ភាសន៍របស់លោក ហេងឌ័រ ដែលបានសហព្រះរាជអាជ្ញាបានផ្តល់ម្សិលមិញនោះ ដាក់បញ្ចូលបទសម្ភាសន៍កម្មាភិបាលមកពីភូមិភាគពាយ័ព្យ។ លោក ហេងឌ័រ ទំនងជានឹងមានលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម ដែលទាក់ទងទៅនឹងអង្គហេតុដូចគ្នានឹង TCW-382។ សាក្សីរូបនេះអាចនឹងមានព័ត៌មានដោះបន្ទុកដោយផ្ទាល់ចំពោះកូនក្តីរបស់ខ្ញុំទាក់ទងទៅនឹងការចោទប្រកាន់ថាមានការកាប់សម្លាប់មន្ត្រីកំពូល លន់ នល់ ដែលសហព្រះរាជអាជ្ញានិយាយថា នៅក្នុងវិសាលភាពនៃសវនាការនេះ។

[០៩:៣៨:២៣]

ជាពិសេសទៅនេះ សាក្សី TCW-382 អាចនឹងពន្យល់អំពីវីដេអូដែលគាត់បានផលិតដែលសហព្រះរាជអាជ្ញាយកមកប្រើជាភស្តុតាងដាក់បន្ទុក ដែលតាមពិតនោះជាភស្តុតាងដោះបន្ទុកទេ។ សក្ខីកម្មនេះគឺសក្ខីកម្មរបស់ TCW-382 គឺអាចនឹងគាំទ្រគោលជំហររបស់មេធាវីការពារ ខៀវ សំផន ដែរទាក់ទងទៅនឹងការទទួលយកវីដេអូធ្វើជាភស្តុតាងនោះ។

ដូចយើងបានបញ្ជាក់ទាក់ទងទៅនឹងតម្លៃជាភស្តុតាង២ថ្ងៃកន្លងមកនោះដែរ ជាពិសេសគឺជាការចាត់ទុកពិនិត្យនូវខ្សែអាត់ដែលចំណាយពេលជាច្រើនពាន់ម៉ោងនោះដែរ។

ក្នុងបរិបទនេះដែរ យើងស្នើសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់យកអ៊ីម៉ែលនេះជាភស្តុតាងថ្មីដោយអនុលោមតាមវិធាន៨៧ កថាខណ្ឌ៤។ អ៊ីម៉ែលនេះ គឺយើងមិនទទួលបានពីមុនទេ។ ហើយអ៊ីម៉ែលនេះគឺពាក់ព័ន្ធយ៉ាងច្បាស់លាស់។ ហើយវាស្រដៀងទៅនឹងសៀវភៅរបស់ ថេត សម្បត្តិ ដែលសហព្រះរាជអាជ្ញាបានពឹងផ្អែកលើទាំងស្រុងនោះ។ ចំណុចទី២ យើងសូមឲ្យអង្គជំនុំជម្រះកោះអញ្ជើញ TCW-382 ដើម្បី -- ឬក៏អង្កេតឲ្យបានលម្អិតទៅតាមវិធាន៩៣។ ហើយទី៣ យើងសុំឲ្យមានការផ្អាកការធ្វើសក្ខីកម្មរបស់លោក ហេងឌ័រ រង់ចាំលទ្ធផលនៃការស៊ើបអង្កេតនេះ។ ការផ្អាកនេះជាការចាំបាច់ណាស់ដើម្បីឲ្យយើងបានកំណត់ត្រាទាំងស្រុងមុននឹងសួរដេញដោលលោក ហេងឌ័រ ផ្អែកលើប្រធានបទនៃភាពពាក់ព័ន្ធនៅក្នុងសវនាការនេះ។

[០៩:៤០:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃឹត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ លោកប្រធានខ្ញុំគិតថា កំហុសនៅក្នុងការដែលលើកឡើងភ្លាមៗដោយមេធាវីការពារក្តីគឺថា សំណើដែលអង្គជំនុំជម្រះទើបស្តាប់នេះគឺថាវាមានគួរឲ្យភ្ញាក់ផ្អើលណាស់ គឺថាវាស្ថិតនៅក្នុងរបៀបវារៈមួយដ៏ខ្ពស់របស់ក្រុមមេធាវីការពារក្តី នួន ជា។ យើងខ្ញុំសុំសំណូមពរថាមិនត្រូវធ្វើការស្នើសុំបែបនោះនៅក្នុងតុលាការទេ ហើយខ្ញុំសូមឲ្យលើកឡើងពីបញ្ហាពាក់ព័ន្ធទៅនឹងការផ្អាកការស្តាប់សក្ខីកម្មលោក ស្ទីវ ហេដឌ័រ។ ការសុំផ្អាកដែលមេធាវីការពារក្តីសំអាងទៅលើអ៊ីម៉ែល ដែលជាអ្នកផលិតខ្សែភាពយន្តដែលមិនមានវត្តមានទេ នៅពេលដែលលោក នួន ជា និយាយរឿងនេះនោះ។ គាត់បានធ្វើការអត្ថាធិប្បាយនូវអ្វីដែលលោក នួន ជាបាននិយាយនៅលើ ឌីវីឌី។ ដូច្នេះ វាមិនមែនជាបញ្ហារបស់លោក លឹមគិន ជាបញ្ហារបស់មេធាវីការពារក្តី។ ដូច្នេះលោកអាចស្តាប់ដឹងលោក នួន ជា និយាយថាដូចម្តេចនោះ លោក មិនបាច់សុំជំនួយពីលោក លឹមគិន នោះទេ។

[០៩:៤២:០៥]

លោក លឹមគិន អាចនឹងមានព័ត៌មាន។ ប្រសិនបើគាត់មានព័ត៌មាន យើងមិនដឹងដែរថាតើអំពីបញ្ហា រស់ ញឹម ទេ បើសិនមេធាវីការពារក្តីមានព័ត៌មានត្រូវដាក់សំណើសុំដល់តុលាការឲ្យកោះហៅសាក្សីរូបនេះ មិនត្រូវស្នើសុំតុលាការឲ្យផ្អាកសវនាការនេះយ៉ាងដូច្នេះទេ គឺថាមិនមាន -- ការធ្វើបែបនេះគឺមិនត្រឹមត្រូវទាល់តែសោះ។ មេធាវីការពារគឺអះអាងថាគាត់មានភស្តុតាងព័ត៌មានស៊ីសង្វាក់គ្នាយ៉ាងខ្លាំង។ ហើយយើងក្រោយមកលោក ហេដឌ័រ បានបង្ហាញនូវបញ្ហានេះដែលគាត់ពេលខ្លះគឺថាធ្វើឲ្យគាត់មានការទាក់ទងរវាងអ្នកផលិតខ្សែភាពយន្តជាមួយនឹងលោក ស្ទីវ ហេដឌ័រ ទៅវិញ។ ហើយបន្ទាប់មកយើងមានបញ្ហាច្រើនទៀតរបស់មេធាវីការពារក្តីនិយាយអំពីការវិភាគរបស់លោក ហេដឌ័រ។ លោក ហេដឌ័រ មិនមែនមកទីនេះដើម្បីផ្តល់ការវិភាគដល់អង្គជំនុំជម្រះនោះទេ។ ការជំនុំជម្រះគឺត្រូវ -- ការវិភាគត្រូវធ្វើឡើងដោយអ្នកជំនាញ។ ពេលនេះគាត់មិនមែនជាសាក្សីជំនាញទេ ដូច្នេះគាត់មិនអាចផ្តល់ការវិភាគបាននោះទេ។ ការវិភាគគឺជាការបកស្រាយនូវអង្គហេតុមិនមែនថាអង្គហេតុគឺជាអ្វី? អង្គហេតុគឺជាអង្គហេតុតែការបកស្រាយ ការវិភាគជាការបកស្រាយអង្គហេតុ។

អ្នកផលិតខ្សែភាពយន្តគឺនិយាយអំពីព័ត៌មានដែលបានជ្រើសរើស សម្រិតសម្រាំង។ ដូច្នេះតាមសំណើសុំរបស់យើងខ្ញុំត្រូវតែអនុវត្តទៅតាមវិធាន៨៧(៤) ហើយត្រូវស្តាប់សក្ខីកម្មលោក ហេដឌ័រ។

នេះគឺជាសំណើសុំដោយគោរពរបស់យើងខ្ញុំ។ ការធ្វើដ៏តក់ក្រហល់បែបនេះគឺមិនត្រឹមត្រូវ។

[០៩:៤៤:១១]

ខ្ញុំសុំលើកឡើងពីបញ្ហាជាក់លាក់មួយចំនួន។ បាទ បញ្ហាជាក់លាក់ចំនួនបី។ តើអ្វីដែលសហព្រះរាជអាជ្ញានិយាយ គឺយើងបានអ៊ីម៉ែលពីអ្នកណាម្នាក់ដែលនិយាយថាមានខ្សែភាពយន្តនៅក្នុងឯកសាររបស់តុលាការ។ វាមិនសំដៅថាផ្ទុះបញ្ចាំងនូវអ្វីក្នុងខ្សែភាពយន្តនោះទេ។ គួរឲ្យអស់សំណើចដែរ អ្វីដែលមាននៅក្នុងខ្សែភាពយន្តគឺជារឿងខ្សែភាពយន្តមិនត្រូវយកការបកស្រាយរបស់អ្នកណាម្នាក់ ឬក៏ធ្វើឡើងដោយការយល់ច្រឡំបែបនេះនោះទេ។ ខ្ញុំសូមសង្កត់ធ្ងន់ ហើយជាពិសេសព័ត៌មានដែលបានមកពីកន្លែងណាមួយ អ្នកណាម្នាក់ដែលគេមិនមានវត្តមាន គាត់ជាអ្នកផលិតភាពយន្ត គាត់មិនស្ថិតនៅទីនោះទេ។ ដូច្នេះ គាត់មិនអាចជួយអ្វីដល់យើងបាននោះទេ។ ព័ត៌មាននេះបង្ហាញឡើងនៅក្នុង ឌីវីឌី។ ថាតើអ៊ីមែលនេះវាមានការពាក់ព័ន្ធយ៉ាងដូចម្តេច គឺមិនមានការពាក់ព័ន្ធអ្វីទាល់តែសោះ។ ហើយអ៊ីម៉ែលគឺថាវាមានតម្លៃដាក់បន្ទុកតិចតួចណាស់ គាត់មិនមែនមកទីនេះ ដើម្បីធ្វើការ -- គាត់មិនមែនជាសាក្សីដែលអាចជួយដល់តុលាការនេះបាននោះទេ។ នេះគឺជាការធ្វើឲ្យមានការភ្ញាក់ផ្អើល ជាការធ្វើឲ្យភ្ញាក់ផ្អើលតក់ក្រហល់មែនទែនមកពីក្រុមមេធាវីការពារក្តីដដែលនេះឯង កាលណាមានតុលាការ តុលាការត្រូវទទួលយកសំណើសុំនិងវិភាគទៅលើភស្តុតាង។ ដូច្នេះ មិនត្រូវងើបឡើងធ្វើបែបតក់ក្រហល់ឲ្យមានការភ្ញាក់ផ្អើលបែបនេះទេ។ អ៊ីម៉ែលបែបនេះ មិនអាចជួយលោកបានស្អីទាល់តែសោះនោះទេ។

[០៩:៤៦:០៧]

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះបដិសេធចោលអ៊ីម៉ែល បដិសេធសំណើនេះមិនបាច់ពន្យារពេលវេលាសមហេតុសមផលណាមួយទេ គឺភ្លាមៗនេះតែម្តង។ អ៊ីម៉ែលនេះគ្មានប្រយោជន៍អីនោះទេ។ បើសិនមេធាវីការពារក្តីមានសេចក្តីថ្លែងពាក់ព័ន្ធទៅនឹង រស់ ញឹម ពាក់ព័ន្ធទៅនឹងការអនុវត្តនៅទួលពោធិ៍ជ្រៃ ដូច្នេះ យកឯកសារ និងភស្តុតាងទាំងអស់នោះមកតុលាការមក កុំស្នើសុំឲ្យធ្វើការផ្អាកការស្តាប់សក្ខីកម្មបែបនេះនោះ ហើយយើងក៏មិនដឹងថា អ្នកនោះមានស្អីផង ហើយអ៊ីម៉ែលនេះនិយាយថាមានព័ត៌មានអំពីរបៀបវារៈរបស់ រស់ ញឹម យ៉ាងច្បាស់លាស់តែម្តង។ យើងចង់ដឹងថាអ្វីកើតឡើងនៅទួលពោធិ៍ជ្រៃ មិនមែននិយាយអំពីរបៀបវារៈអីរបស់ រស់ ញឹម អីនោះទេ។ បើមេធាវីការពារក្តីមានឯកសារមានភស្តុតាងយកមក ហើយដាក់សំណើជូនតុលាការតែម្តង។ កុំមករំខានឆាឆៅទៅដល់សាក្សីរូបនេះ។

ទី២ សាក្សី TCW-382 បើថាចង់ឃើញអ្វីដែលបង្ហាញនៅក្នុងខ្សែភាពយន្តហ្នឹង អ្វីដែលធ្វើឲ្យ

មានការយល់ខុសនោះ គឺថាគ្មានន័យអីទេ។ បើមេធាវីការពារក្ដីមានហេតុផលមក គាត់អាចបង្ហាញភស្តុតាងដោយផ្ទាល់ ហើយដែលអាចជួយក្រុមខ្លួនបាន គឺសឹមលើកឡើងជូនតុលាការតាមនោះទៅ។

[០៩:៤៧:១៣]

ខ្ញុំសូមរំឭកទៅដល់មេធាវីការពារក្ដី គាត់គឺជាមនុស្សជំនិតរបស់អ្នកផលិតខ្សែភាពយន្តនេះ។ ខ្ញុំសុំឱ្យគាត់ផ្ដល់ ឬក៏ ក.ស.ច.ស ស្នើសុំឱ្យផ្ដល់ខ្សែភាពយន្តនេះមក? អត់ទេ ខ្ញុំសូមបដិសេធ។ ថាតើ ក.ស.ព ទទួលបានខ្សែភាពយន្តដោយរបៀបណា? លោកប្រធាននេះ គឺជាការស្វែងរក ដូចយើងរកស្ទីមួយនៅក្នុងព្រៃអាម៉ាហ្សូនអ៊ីចឹង យើងរកតាមអ៊ីនធឺណេតតើ! បុគ្គលបែបនេះមិនអាចជួយយក -- ជួយតុលាការនេះបានទេ។ បើសិនណាជារបៀបវារៈរបស់ រស់ ញឹម ពាក់ព័ន្ធទៅនឹងព័ត៌មាននេះ គឺថារឿងវាជារឿងរបស់ រស់ ញឹម។ ការមិនអាចស្នើសុំឱ្យសាក្សីរូបនេះមកជួយបកស្រាយរឿងនេះបាននោះទេ។

ហើយការដែលចំណុចទី៣ គឺជាចំណុចដែលអាចយល់ស្របជាមួយ។ ការស្នើសុំឱ្យផ្អាកសក្ខីកម្មលោក ហេដឌ័រ នេះប្រហែលជាគាត់អាចយកព័ត៌មាននេះពីទាហានមកពីភូមិភាគពាយ័ព្យដោយសារថាយើងមិនដឹងគេនិយាយអ្វីអំពី រស់ ញឹម នោះទេ។ បើមេធាវីការពារក្ដីចង់តាំងសំណួរទៅលើលោក ហេដឌ័រ មិនមែនពីរឿងការវិភាគរបស់គាត់នៅទួលពោធិ៍ជ្រៃទេ ដោយសារចំណុចនេះ គឺតុលាការមិនអនុញ្ញាតទេ។ បើចង់លើកឡើងព័ត៌មានភស្តុតាងដែលគាត់សរសេរពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ លើកយកព័ត៌មាននិងភស្តុតាងមកសួរដេញដោលគាត់ទៅ។

[០៩:៤៩:៣១]

ខ្ញុំសូមសង្កត់ធ្ងន់ម្ដងទៀតថា អ្វីដែលលោកនិយាយអ៊ីម៉ែលទាំងបីមកដល់ភាគី។ គោលបំណងរបស់លោក ហេដឌ័រ មកផ្ដល់សក្ខីកម្ម គឺផ្ដល់សក្ខីកម្មនិយាយអំពីអត្ថបទសារព័ត៌មាន និងសៀវភៅដែលគាត់សរសេរ និងកិច្ចសម្ភាសន៍ដែលគាត់ធ្វើឡើង និងបញ្ហាដទៃទៀត ដែលគាត់មានទំនាក់ទំនងដោយផ្ទាល់តែម្ដង។ គាត់មិនមែនមកនេះ ដើម្បីផ្ដល់ការវិភាគអំពីទួលពោធិ៍ជ្រៃ ឬការភាគ ឬក៏ផ្ដល់ជាមតិយោបល់ទៅលើបញ្ហាដទៃទៀតនោះឡើយ។

ខ្ញុំសង្កត់ធ្ងន់ម្ដងទៀតថា ខ្ញុំសូមឱ្យអង្គជំនុំជម្រះដោះស្រាយបញ្ហានេះជាបន្ទាន់ភ្លាមតែម្ដង។ ហើយសូមផ្អាកច្រានចោលបញ្ហាទាំងបីដែលបានលើកឡើងនេះ។ បាទ ហើយសូមមេត្តាឈប់បង្កឱ្យមានភាពរញ៉េរញ៉ៃបែបនេះតទៅ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ កុំអាលទាន់លោក កូប៉េ!

សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

[០៩:៥០:៥៩]

ខ្ញុំចង់បន្ថែមបន្តិចទៅហ្នឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា។ ជាដំបូងនោះ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំគាំទ្រទាំងស្រុងទៅលើយោបល់របស់សហព្រះរាជអាជ្ញា ហើយនិងគោលជំហរទៅការលើកឡើងការស្នើរបស់មេធាវីការពារក្តីលោក នួន ជា។ ខ្ញុំភ្ញាក់ផ្អើលនឹងការស្នើសុំបែបនេះណាស់ ទោះបីខ្ញុំយល់តាំងពីម្សិលមិញថានៅក្នុងដំណាក់កាលនេះ អ្វីដែលអាចកើតមានឡើងដែរ ហើយអ្វីក៏មានស្នើសុំដែរ ទោះបីជាមានមូលដ្ឋាន ឬក៏គ្មានមូលដ្ឋានក៏ដោយ។ ខ្ញុំក៏ភ្ញាក់ផ្អើលទៅនឹងមធ្យោបាយដែលប្រើដែរ គឺថាប្រាប់ជូនដំណឹងនៅពេលចុងក្រោយហើយ ថាវាគ្មានព័ត៌មានអីឲ្យច្បាស់លាស់សោះ ថានឹងធ្វើសំណើយ៉ាងម៉េចនោះ។

ចំពោះខ្ញុំផ្ទាល់ គឺថាការ -- ខ្ញុំមិនសូវទុកចិត្តទៅលើអ៊ីម៉ែលហ្នឹងទេ មិនដឹងថាមកពីណា ហើយមកពេលចុងក្រោយទៀត ពីអ្នក -- ពីមនុស្សម្នាក់ដែលគ្រាន់តែជាផលិតករ ហើយនិងជាអ្នកនិពន្ធរួម។ ហើយគាត់ផ្តល់យោបល់គាត់នៅក្នុងសវនាការដ៏ហ្មត់ចត់របស់យើងនេះ។ យើងមានខ្សែភាពយន្តមួយនៅក្នុងសំណុំរឿងរបស់យើង ហើយយើងក៏បានចាក់បង្ហាញតាំងពីដំបូងមកហើយ ខ្សែភាពយន្តនេះ គឺយើងចាក់មួយផ្នែកផ្សេងៗនៃខ្សែភាពយន្តនេះ ហើយយើងអាចឃើញទាំងអស់គ្នា យើងបានមើលហើយខ្សែភាពយន្តនោះជាភាសាខ្មែរ ហើយយើងឃើញរូបលោក នួន ជា ហើយមានសម្តីរបស់លោក នួន ជា ជាភាសាខ្មែរទៀត។

[០៩:៥២:៣៨]

ឥឡូវនេះ យើងមានផលិតករនៃខ្សែភាពយន្តនេះ ដែលគាត់បានប្រាប់យើងពីអ្វីដែលលោក នួន ជា នៅពេលនោះ ថាមិនពិតទេ។ ដូច្នេះ ខ្ញុំឃើញថាដូចជាចម្លែកណាស់ នៅពេលដែលលើកឡើងបែបនេះនោះ។ ហើយខ្ញុំក៏មានការភ្ញាក់ផ្អើលដែរ នៅពេលដែលនិយាយបែបនេះនោះ។

ដូច្នេះ ខ្សែភាពយន្តនេះគឺជាការផ្ដល់យោបល់ដើម្បីឱ្យអង្គជំនុំជម្រះពិភាក្សាសម្រេច ហើយគាត់មិនមែនជាអ្នកច្បាប់ទេ ហើយគាត់ក៏មិនបានចូលរួមនៅក្នុងការជជែកពិភាក្សាដេញដោលរបស់យើងនេះដែរ។ គាត់គ្រាន់តែជាផលិតករប៉ុណ្ណោះ។ ហើយការអត្ថាធិប្បាយរបស់គាត់នោះ គឺពាក់ព័ន្ធទៅនឹងរឿង "១ថ្ងៃនៅទួលពោធិ៍ជ្រៃ" ហើយយើងក៏បានមើលរឿងហ្នឹងអស់ហើយ។ មនុស្សនៅក្នុងរឿងហ្នឹង គឺនិយាយជាភាសាខ្មែរ លើកលែងតែខ្ញុំភាន់ច្រឡំនោះ មិនមានពេលណាមួយនោះ គេនិយាយអំពីឈ្មោះរស់ ញឹម ទេ នៅក្នុងខ្សែភាពយន្តនោះ។

ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃនេះ ខ្ញុំគិតថា ដើម្បីថាផ្ដល់ជាលក្ខណៈប្រាកដប្រជាទៅលើសំណើរបស់មេធាវីការពារក្ដី នួន ជា នេះ គាត់គួរតែធ្វើសំណើជាលាយលក្ខណ៍អក្សរយោងតាមវិធាន ៨៧(៤) ដើម្បីបញ្ជាក់មូលដ្ឋាននៃសំណើរបស់គាត់។ នេះជាអ្វីដែលគាត់ត្រូវធ្វើ។ គាត់ត្រូវតែពន្យល់ -- គាត់មិនគួរណាលើកអ៊ីម៉ែលយកមកអានបែបនេះទេ។ ហើយយើងក៏អាចអានមើលបានដែរ។ គាត់មិនអាចលើកមកអានអ៊ីម៉ែល ហើយបញ្ជាក់ថានេះជាមូលដ្ឋានដើម្បីទទួលយកសំណើភស្តុតាងថ្មីនោះទេ។ ដូច្នេះសូមឱ្យគាត់ធ្វើជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់។ ហើយគាត់បានជ្រើសរើសវិធីមួយផ្សេងទៀត។ គាត់ស្នើសុំឱ្យអង្គជំនុំជម្រះសម្រេចទៅលើសំណើរបស់គាត់ដោយផ្ទាល់មាត់។ ដូច្នេះគាត់គួរតែធ្វើសំណើជាលាយលក្ខណ៍អក្សរ ក៏ប៉ុន្តែការលើកឡើងជាផ្ទាល់មាត់នោះ ក៏អង្គជំនុំជម្រះអាចសម្រេចបានដែរ។

[០៩:៥៤:៤៧]

អ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ ខ្ញុំសូមគាំទ្រទាំងស្រុង ហើយខ្ញុំមិននិយាយឡើងវិញដដែលទេ គឺថាសូមឱ្យអង្គជំនុំជម្រះបដិសេធចោលនូវសំណើជាផ្ទាល់មាត់របស់មេធាវីការពារក្ដី នួន ជា ហើយនិងបដិសេធចោលនូវការដាក់អ៊ីម៉ែលនេះជាភស្តុតាង។ នេះមិនមែនជាសំណើហួតចត់នោះទេ។ ដូច្នេះអង្គជំនុំជម្រះសូមមេត្តាបដិសេធចោល។ ដូច្នេះ ខ្ញុំក៏សូមឱ្យអង្គជំនុំជម្រះបដិសេធចោលនូវសាក្សី TCW-382 ផងដែរ។ ហើយជាចុងក្រោយនោះខ្ញុំនឹងព្យាយាមស្វែងរកមូលហេតុផ្ដល់យុត្តិកម្មពាក់ព័ន្ធទៅនឹងការផ្អាកសក្ខីកម្មរបស់លោក ហេដឌ័រ។

យើងបានរៀបចំអស់រយៈពេលជាយូរមកហើយ ហើយបើសិនជាមេធាវីការពារក្ដីចង់ចោទសួរអ្វីទៅលើលោក ហេដឌ័រ គាត់សួរទៅ។ ដូច្នេះ នៅក្នុងដំណាក់កាលនេះការដែលស្នើសុំឱ្យផ្អាកសវនាការស្ដាប់សក្ខីកម្មលោក ស្ទីវ ហេដឌ័រ នោះគឺវាមិនសមស្របនោះទេ។ ដូច្នេះការដែលគាត់ស្នើសុំនោះ គឺ

គ្រាន់តែគាត់ធ្វើយ៉ាងម៉េចឲ្យការបិទសវនាការយើងនេះកាន់តែយូរទៅៗ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះបដិសេធចោលនូវសំណើទី៣ ដែលថាមិនមានមូលដ្ឋានទាល់តែសោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានគាត់បានដាក់សំណើ ដូច្នេះគាត់មិនត្រូវមានការឆ្លើយតបនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ឃើញថាការលើកឡើងនោះមិនមានស្អីគួរឲ្យខ្ញុំចាប់អារម្មណ៍នោះទេ។

[០៩:៥៦:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០១:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីវៀ ខាតវ៉ាយថ៍ ដើម្បីបង្ហាញអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ដែលបានលើកឡើងអម្បាញ់មិញនេះ ពាក់ព័ន្ធជាមួយនឹងការស្នើសុំទទួលយកឯកសារថ្មី ហើយនិងការស្នើសុំស្តាប់សក្ខីកម្មសាក្សី 382។

សូមអញ្ជើញលោកស្រីចៅក្រម -- និងបញ្ហាមួយទៀតសូមផ្អាកនូវការស្តាប់សក្ខីកម្មសាក្សី ស្ទីវិន ហេដឌ័រ។

សូមអញ្ជើញលោកស្រីចៅក្រម!

[១០:០២:៣០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានសម្រេចដូចតទៅថា អង្គជំនុំជម្រះនឹងមិនផ្អាកការស្តាប់សក្ខីកម្មសាក្សី ស្ទីវិន ហេដឌ័រ នេះទេ។

ទី២ ព័ត៌មានដែលផ្តល់កន្លងមកដោយមេធាវីការពារក្តី នួន ជា មិនបំពេញលក្ខខណ្ឌឲ្យអង្គជំនុំជម្រះ -- មិនបំពេញតាមលក្ខខណ្ឌនៅក្នុងវិធាន៨៧(៤) នោះទេ។ ក៏ប៉ុន្តែបើសិនជាក្រុមមេធាវីការពារ

ក្ដី នួន ជា ដាក់សំណើជាលាយលក្ខណ៍អក្សរអនុវត្តតាមវិធាន៨៧(៤) គឺត្រូវធ្វើឡើងនៅម៉ោងចុងក្រោយបំផុតគឺថ្ងៃចន្ទ ម៉ោងពីរសប្ដាហ៍ក្រោយ ដោយលើកឡើងនូវភស្តុតាងថ្មី ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

ដោយសារតែពេលវេលាដែលកំណត់សម្រាប់ការដាក់សំណើសុំនេះ គឺថាសំណើសុំអាចដាក់លក្ខខណ្ឌនេះ គឺត្រូវតែដាក់ជាភាសាអង់គ្លេស និងត្រូវដាក់ជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបានលឿនបំផុត។

តើចំណុចដែលខ្ញុំលើកឡើងនេះចប់អស់ហើយឬនៅលោកប្រធាន?

[១០:០៣:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ត្រឹមត្រូវហើយ។

ជាបន្តទៅនេះអង្គជំនុំជម្រះសូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ស៊ីវិន ហេងឆ័រ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការវិញ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:០៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ស៊ីវ ហេងឆ័រ។ ទី១ សូមរំឭកលោកថា គប្បីលោកប្រើចម្ងាយរវាងលោកជាមួយនឹងក្បាលមីក្រូហ្វូនឲ្យកម្រិតមួយប្រហែលហ្នឹងគឺសមស្របហើយ អាចស្រូបសំឡេងបានហើយចៀសវាងការជិតពេកនាំឲ្យមានបញ្ហាខូចសំឡេងពិបាកក្នុងការបកប្រែភាសា។ ហើយបន្តទៅទៀតអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីវ ហេងឆ័រ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរសាជាថ្មីម្តងទៀតលោក ហេងឆ័រ ខ្ញុំសូមចាប់ផ្ដើមសួរ លោកឲ្យលម្អិតបន្តិចអំឡុងពេល២០០៥ ពេលដែលលោកចាកចេញពីក្រុម សូអាស (SOAS) តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើកិច្ចសម្ភាសន៍ត្រូវធ្វើឡើងដោយរបៀបណា? តើវា

មានការណែនាំឲ្យការរៀបចំជាសំណួរកត់ត្រាហើយតើចម្លើយហ្នឹងត្រូវទទួលបានដោយរបៀបណា? លោកអាចរៀបរាប់ចំណុចនេះបានទេ?

**លោក ស្មីវ ហេងឆ័រ៖**

**ឆ៖** វាតម្រូវឲ្យមានការឆ្លើយបញ្ជាក់បន្តិចទាក់ទងទៅនឹងកិច្ចការផ្នែក*អាកាឌីមិច* នេះ។ ខាងស្រាវជ្រាវកិច្ចការស្រាវជ្រាវ។ ការស្រាវជ្រាវ គឺធ្វើឡើងត្រូវដោយមានសមាជិកក្រុម មានវិន័យ មានជារបៀបជាអង្គការត្រឹមត្រូវមានវិធានផ្ទៃក្នុងមាននីតិវិធីដែលបុគ្គលម្នាក់ៗ ឬក៏បញ្ញវន្តណាដែលចូលបំពេញការងារក្នុងសមត្ថភាពបុគ្គលហ្នឹងគឺត្រូវធ្វើតាមនេះ។ គឺថាមិនត្រូវដឹកនាំឲ្យធ្វើខុសអីដោយប្រធានផ្នែកណាមួយទាក់ទងទៅនឹងកិច្ចការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយនោះ មិនមានការកំណត់នូវវិធានណា -- យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវណាមួយ គឺយើងត្រូវដឹងអំពីការស្រង់យកព័ត៌មានទិន្នន័យ។ វាមានការញែកដាច់ពីគ្នារវាងកិច្ចសម្ភាសន៍ជាទូទៅដែលយើងមានរៀបចំជាចង្កោមសំណួរអាចជាចង្កោមសំណួរផ្សេងៗ ឬក៏យើងអាចប្រើជាសំណួរបើកវាជាដំណើរការមួយយ៉ាងសាមញ្ញទាក់ទងទៅនឹងការតាំងជាសំណួរបើកអីនេះ។

[១០:០៨:៤២]

កិច្ចសម្ភាសន៍នេះគឺថាមិនកត់ត្រាទេ។ ការអនុវត្តរបស់ខ្ញុំជាច្រើនឆ្នាំ គឺធ្វើឡើងដោយការតាំងសំណួរជាភាសាខ្មែរ ហើយបន្ទាប់មកខ្ញុំសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់ខ្ញុំ។ ហើយថ្មីៗខ្ញុំកត់ត្រាចូលក្នុងកុំព្យូទ័រជាភាសាអង់គ្លេស។ ដូច្នេះ មិនមានអត្ថបទជាភាសាខ្មែរនៅពេលក្រោយនោះទេ បើមិនការបកប្រែភ្លាមៗដោយផ្ទាល់នោះទេ។ ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថាលទ្ធផលនៃកិច្ចសម្ភាសន៍គឺថាគេអាចទទួលបាន តុលាការក៏អាចទទួលបាន ផ្នែកណាក៏អាចទទួលបាន។ ខ្ញុំបំពេញមុខងារនេះគឺថាដូចជាអ្នកប្រវត្តិវិទូវិទ្យាសាស្ត្រនយោបាយ ដើម្បីធ្វើម៉េចបំពេញទៅតាមវិជ្ជាជីវៈរបស់ខ្ញុំ ទោះបីវាល្អក្តី ថាមិនល្អក្តី នេះគឺជាមធ្យោបាយមួយដែលខ្ញុំធ្វើកិច្ចសម្ភាសន៍អំពីបញ្ហាទាក់ទងទៅនឹងរបប ខ្មែរក្រហមដែលស្ថិតនៅក្នុងអំណាច។ ខ្ញុំចាប់ផ្តើមធ្វើកិច្ចការនេះក្នុងឆ្នាំ១៩៧៨ ហើយមុនខ្មែរក្រហមកាន់អំណាចគឺក្នុង៧៣ ទៅដល់ ៧៥ ក៏ខ្ញុំបំពេញការងារជាអ្នកយកសារព័ត៌មាន។ ដូច្នេះ គឺសម្រាប់អ្នករួមអាជីពនេះគឺជាលទ្ធផល -- បាទ អានេះគឺជាលទ្ធផលដែលខ្ញុំធ្វើឡើង។

[១០:១០:៥៥]

**ស៖** គឺថាតាមចម្លើយរបស់លោកមានចំណុចពីរដែលជួយបំពេញបន្ថែមទៀត។ ទី១ លោក

អាចជម្រាបជូនពីកម្រិតនៃវិជ្ជាជីវៈរបស់លោកបានទេ?

**ឆ៖** លោកចង់ធ្វើតេស្តមកដល់ខ្ញុំនៅក្នុងតុលាការនេះ។ ទាក់ទងទៅនឹង -- គឺថាវាមានលក្ខណៈ ល្អមែនទែន រលូន ខ្ញុំអាចផ្តល់ឧទាហរណ៍ជូនលោកបាន។ ជាទូទៅ ប្រសិនណាខ្ញុំនិយាយទៅ ហៅអ្នក ណាម្នាក់ជាភាសាខ្មែរ គេបដិសេធថាខ្ញុំនឹងគឺថាមែនជាៗដទៃទេថា ជាខ្មែរ ហើយពេលណាខ្ញុំនៅក្រៅ ប្រទេស។ នេះដោយសារតែភាពស្ទាត់ជំនាញក្នុងការនិយាយភាសារបស់ខ្ញុំ ហើយភាពស្ទាត់ជំនាញនេះ គឺមានន័យថាខ្ញុំមិនបានសិក្សាភាសាខ្មែរនៅក្នុងថ្នាក់រៀននោះទេ។ ខ្ញុំរៀនតាមសៀវភៅ ខ្ញុំរៀន គឺថា ដោយខ្លួនឯងតាំងពីថ្ងៃដំបូងមកម្ល៉េះ។ ដូច្នេះមានន័យថាយ៉ាងដូច្នេះ។ ឧទាហរណ៍ ចិន ភាសាចិន ដែលខ្ញុំ ចេះនិយាយនេះ គឺថាវាហាក់ដូចស្រដៀងទៅនឹងចិនមែន ភាសាខ្មែរស្រដៀងកសិករខ្មែរ។

[១០:១២:៣៩]

**សៈ** ខ្ញុំអត់បានដឹងអំពីឆ្នាំ១៩៧៣ទេ ពេលដែលលោក -- ពេលណាលោកនិយាយបានត្រឹមតែ ថាមួយគ្រប់គ្រាន់ ហើយពេលណាលោកនិយាយទៅស្ទាត់ជំនាញល្អពេលលោក -- ចាប់តាំងពីពេល ដែលលោកចាប់ផ្តើមរៀនមកនោះ?

**ឆ៖** ខ្ញុំបានចាប់ផ្តើមមុនពេលដែលខ្ញុំសិក្សាភាសាខ្មែរ ខ្ញុំសិក្សាភាសាថៃ។ សិក្សាដោយសារតែ មានការទំនាក់ទំនងមានភាពស្រដៀងគ្នាទៅនឹងពាក្យបច្ចេកទេ វាក្យស័ព្ទបច្ចេកទេសក្នុងភាសាខ្មែរ និង ភាសាថៃ ហើយមូលដ្ឋាន គឺថាខ្ញុំបានសិក្សារយៈពេល១ឆ្នាំកន្លះ គឺសិក្សាពិបាកមែនទែន មុននឹងខ្ញុំអាច ធ្វើការសន្ទនាទៅលើប្រធានបទជាទូទៅណាមួយបានដោយស្រួល ឬក៏មុននឹងខ្ញុំអាចអាចអត្ថបទ ឬក៏ ប្រធានបទណាមួយនោះ។ នៅពេលនោះ ខ្ញុំចាកចេញពីកម្ពុជាក្នុង -- នៅថ្ងៃទី១៧ មេសា ៧៥ ពេល ហ្នឹងខ្ញុំចេះនិយាយបានល្អហើយ និយាយខ្មែរបានល្អហើយ ប៉ុន្តែមិនទាន់ស្ទាត់ជំនាញទេ។ គឺថាការ និយាយភាសាបានស្ទាត់ជំនាញនេះ គឺដោយាសារតែពេលវេលា ខ្ញុំបានចំណាយពេលវេលានៅចន្លោះ រវាងព្រំដែនកម្ពុជាថៃ ១៩៨៤ -- ៨០-៨៤ នៅពេលដែលមានការលេចឡើង ពេលនោះគឺថាទីតាំង នោះគឺថាគេមាននិយាយ -- ជាបរិយាកាសមួយបង្កឲ្យយើងនិយាយភាសាថៃ ភាសាខ្មែរ។ អ៊ីចឹងដើម ទសវត្សរ៍១៩៨០ គឺថាសំឡេងនៃការនិយាយភាសារបស់ខ្ញុំវាស្ទើរតែនឹងដូចវា ភាសាអ្នកនិយាយភាសា កំណើតទៅហើយ។

[១០:១៤:៥៧]

**សៈ** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីភាពស្ទាត់ជំនាញនៃការនិយាយភាសាថៃ ភាសា

វៀតណាម ក៏ដូចជាភាសាចិនផងបានទេ?

**ឆ៖** ខ្ញុំគិតថា ភាសាខ្មែរនិយាយស្ទាត់ជំនាញ និយាយបានច្រើនបំផុត។ ឯការអានភាសាថៃរបស់ខ្ញុំនេះគឺគ្រាន់បើជាងអានភាសាខ្មែរ។ នេះដោយសារថានៅថៃគេមានព័ត៌មានត្រូវអានច្រើនបានច្រើនជាងនៅកម្ពុជា។ មានអត្ថបទនៅថៃច្រើនជាងនៅខ្មែរ ដែលគេហៅថាអត្ថបទដែលត្រូវនេះវានៅមានកម្រិតនៅឡើយ បើយើងប្រៀបធៀបទៅនឹងអ្វីដែលអាចមាននៅក្នុងប្រទេសថៃនោះ។ អ៊ីចឹងមានន័យថា -- ខ្ញុំអាចនិយាយយ៉ាងដូច្នេះបានទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវរបស់ខ្ញុំ គឺចង់និយាយការទំនាក់ទំនងខាងផ្នែកនយោបាយ ដែលកុម្មុយនីស្តកម្ពុជា បក្សកុម្មុយនីស្ត--

[១០:១៦:២៨]

**ស៖** ខ្ញុំសូមអធ្យាស្រ័យក្នុងការកាត់ផ្តាច់លោក។ សូម ទី១ សូមឲ្យលោកនិយាយអំពីកម្រិតនៃភាពស្ទាត់ជំនាញជាភាសាថៃ វៀតណាម ចិន។ សូមឲ្យលោកឆ្លើយខ្លីបាទ។

**ឆ៖** ខ្មែរ ថៃ ចិន វៀតណាម ចុងក្រោយបែបមិនទាន់គឺបារាំង ខ្ញុំនិយាយភាសាបារាំងផងដែរ។

**ស៖** ចំពោះភាសាខ្មែរម៉េចដែរ? ដោយសារខ្ញុំចេះនិយាយបានតែជាមួយអ្នករត់តាក់ស៊ី។ លោកបានលើកឡើងពីឆ្នាំ១៩៧៨ ខ្ញុំសូមសួរទៅលោករបៀបនេះ លោកបានធ្វើការសម្ភាសជាច្រើន តើលោកជម្រាបជូនអង្គជំនុំជម្រះបានទេ ខ្ញុំយកឆ្នាំ១៩៧៨ ជាគោល។ តើពេលណាជាលើកដំបូងដែលលោកធ្វើការពិភាក្សាសម្ភាសយកចម្លើយដែលពាក់ព័ន្ធទៅនឹងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ? ក្នុងអំឡុងពេលហ្នឹងក្រោយមក ឬក៏យ៉ាងម៉េច? តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

[១០:១៧:៥៦]

**ឆ៖** ខ្ញុំគិតថាយើងកំពុងនិយាយអំពីថ្ងៃ១៧ មេសា ៧៥ ទៅដល់ថ្ងៃ០៧ មករា ១៩៧៩។ បាទនេះវាជាយុត្តាធិការពេលវេលា។ ដំបូងបំផុតគឺថ្ងៃបើកឆាកដំបូង គឺខែមករា ១៩៧៩ ខ្ញុំគិតថាហ្នឹងអាចជាថ្ងៃទី០៣ ឬក៏ទី០៤ មករា ៧៩។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ពេលនោះ គឺខ្ញុំៗនៅទល់មុខជាមួយនឹងតាព្រះយ៉ា នៅក្នុងប្រទេសថៃ។ ពេលនោះមេតំបន់បក្សកុម្មុយនីស្តកម្ពុជា មេតំបន់៥ ភូមិភាគពាយ័ព្យ គឺខ្ញុំសម្ភាសនៅក្នុងនៅព្រំដែនកម្ពុជា-ថៃ តែខាងក្នុងទឹកដី នៅតាព្រះយ៉ានៅតាមព្រំដែន។ ហើយកិច្ចសម្ភាសន៍មួយចំនួនទៀតនោះ ខ្ញុំធ្វើឡើងនៅក្នុងទឹកដីកម្ពុជា ក្បែរតាព្រះយ៉ាហ្នឹង។

**ស៖** លោកតើលោកសម្ភាសអំពីជនភៀសខ្លួន ឬសមាជិកនៃរបបនោះ ឬក៏កម្មាភិបាលថ្នាក់ទាប? លោកអាចផ្តល់ជាយោបល់បានទេ?

**ឆ៖** បាទ ខ្ញុំ -- អ្នកដែលខ្ញុំសម្ភាសនៅក្នុងទឹកដីថៃ គឺខ្ញុំអាចនិយាយថាអ្នកទាំងអស់នោះគឺជាអ្នកស្នើសុំរកសិទ្ធិជ្រកកោន ហើយអ្នកដែលខ្ញុំសម្ភាសនៅខាងផ្នែកតំបន់៥ តាមដែលខ្ញុំយល់នោះគឺជាមនុស្សធម្មតាទេ មិនមែនជាកម្មាភិបាល មិនមែនជាកងប្រដាប់អាវុធរត់ ឬក៏ជាយុទ្ធជន។ អ្នកទាំងអស់នោះ គឺជាអ្នករត់គេចខ្លួនចេញពីសហករណ៍ ដែលជាផ្នែកមួយនៃតំបន់៥។ ដោយសារតែការខ្លាចការចូលមកដល់នៃវៀតណាម។

[១០:២១:០២]

**ស៖** លោកបានជូនឯកសារពីម្សិលមិញ គឺមានតួរលេខ។ តើលោកមានឯកសារនៅហ្នឹងដែរទេ? សូមលោកទៅទំព័រលេខ៤។ នៅខាងក្រោមនោះ យើងមានលេខ២ បទសម្ភាសន៍លោក ហេងឌ័រ ជាមួយជនជាប់ចោទ ជនភៀសខ្លួន និងអ្នកដទៃទៀត។ ខ្ញុំផ្តង់អារម្មណ៍ទៅលើចំណុចទី២ខាងលើ គឺបទសម្ភាសន៍ជាមួយលោក ខៀវ សំផន។ ខ្ញុំអាចបញ្ចាឯកសារហ្នឹងបាន បើសិនលោកចង់មើល។ ទី១ ខ្ញុំនិយាយអំពីលេខ៧០ ជាបទសម្ភាសន៍នៅថ្ងៃទី៤ ខែសីហា ឆ្នាំ១០៨០។ តើលោកបានសម្ភាសនិយាយជាមួយគាត់នៅថ្ងៃហ្នឹងទេ? តើមានកំណត់ត្រាអ្វីដែរឬទេ?

**ឆ៖** បាទ តាមដែលខ្ញុំចាំ គឺត្រឹមត្រូវហើយ ជាកាលបរិច្ឆេទត្រឹមត្រូវ។ ខ្ញុំជឿថាការដែលជួបគាត់នោះក្នុងរយៈ២ថ្ងៃ ខ្ញុំចំណាយពេល១យប់នៅកន្លែងហ្នឹង ហើយតាមដែលខ្ញុំចាំហ្នឹងគឺថាកំណត់ត្រានៃការជួប នៃការសម្ភាសនោះ ហើយនិងចម្លើយដែលបានកត់ត្រានោះគឺចម្លើយខ្លះបានថតជាខ្សែអាត់ អ្នកខ្លះ កន្លែងខ្លះគឺយើងកត់ត្រាជាសរសេរផ្ទាល់ដៃ គឺដោយការបកប្រែប្រដេញផ្ទាល់ឲ្យ ស្ទីវ ហេដឌ័រ គឺយើងបានកត់នៅពេលនោះ។ មិនមែនថតខ្សែអាត់គ្រប់បទសម្ភាសន៍ទាំងអស់នោះទេ តាមដែលខ្ញុំចាំនោះ ប៉ុន្តែខ្ញុំអាចនឹងកត់ត្រាសរសេរផ្ទាល់ដៃ ឬប្រតិចារឹកនៅក្នុងកំណត់សម្គាល់ក្នុងសៀវភៅនោះបាទ។

[១០:២៣:៣២]

**ស៖** ខ្ញុំចង់សំណួរលោក គឺសូមការអនុញ្ញាតពីលោកប្រធាន គឺឯកសារនេះ អំពីគឺលេខ៦៩នៅលើបញ្ជី ដែលយើងមានលេខឯកសារគឺថា E3/198។ ខ្ញុំសូមអនុញ្ញាតបង្ហាញលោក គឺឯកសារនោះគឺលេខ IS20.23។ ខ្ញុំសូមជូនទៅលោកតាមការអនុញ្ញាតរបស់លោកប្រធាន តើលោកនឹកឃើញអំពីការជួបជាមួយលោក ខៀវ សំផន នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក ឃីត រេយ៍ន័រ៖**

ដូច្នេះ មេធាវី គឺលោកអាចមើលឯកសារ IS20.23 បាទ។

[១០:២៥:០០]

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ឯកសារនេះខ្ញុំមិនបានធ្វើទេ ដោយខ្លួនឯង ប៉ុន្តែជាមនុស្សម្នាក់ដែលខ្ញុំធ្វើការជាមួយតាមដែលខ្ញុំ ចាំនោះគឺខ្ញុំមិនដឹងថាមានការបកប្រែដោយតុលាការ ឬក៏ជាការបកប្រែដោយសារខ្ញុំដែលបានកត់ត្រានៅពេលនោះឬទេ? ខ្ញុំមើលទៅដូចជាឯកសារបកប្រែដោយតុលាការ មិនមែនជាការបកប្រែរបស់ខ្ញុំដែលថាទាក់ទងទៅនឹងរបៀបដែលខ្ញុំបកប្រែគឺវាមានលក្ខណៈពិសេសខុសពីនេះ។

**ស៖** ឥឡូវនេះគឺខែសីហា ឆ្នាំ២០០៥ លោកបាននៅក្នុងប្រទេសកម្ពុជា។ តើលោកនៅចាំថាបានឃើញឯកសារជាទម្រង់ដើម ឬកំណត់ដៃអំពីបទសម្ភាសន៍ ឬក៏មានជាខ្សែអាត់ ឬតើលោកអាចពន្យល់អ្វីអំពីបទសម្ភាសន៍នៅពេលនោះ? យើងមើលកំណត់ដៃ ឬក៏មើលឯកសារបកប្រែតើលោកអាចពន្យល់អ្វីបានបន្ថែមទេ?

**ឆ៖** តាមដែលខ្ញុំចាំនោះគឺថាកំណត់ដៃនោះយើងបានកត់ត្រាជាអក្សរដៃខ្មែរជាច្បាប់ដើម។ បន្ទាប់មក គឺមិនយូរប៉ុន្មានពីបទសម្ភាសន៍នោះទេ ខ្ញុំចង់ជម្រាបថាប្រហែលជា១អាទិត្យ ឬក៏អាច១ខែ មិនមែន១ថ្ងៃ ២ថ្ងៃទេ។ ហើយគេដាក់បញ្ចូលភាសាខ្មែរទៅជាឯកសារក្នុងកុំព្យូទ័រ។ ដូច្នេះ អាចហ្នឹងជាការបកប្រែដែលធ្វើឡើងផ្អែកតាមអត្ថបទនៅក្នុងកុំព្យូទ័រ ដែលផ្អែកទៅលើកំណត់ដៃច្បាប់ដើមពីដំបូងនោះឯង។

[១០:២៧:១៧]

**ស៖** ទាក់ទងទៅនឹងបែបបទនៃការកត់ត្រា លោករៀបរាប់អំពីបែបបទដែលលោកកត់ត្រា។ តើអ្នកផ្សេងទៀតនៅក្នុងក្រុមនោះ គឺប្រើប្រព័ន្ធសួរសំណួរនិងឆ្លើយ ហើយកត់ត្រាទុក? តើគេរៀបចំសំណួរ ឬក៏បានថតជាខ្សែអាត់សំឡេងដែរឬទេ?

**ឆ៖** ខ្ញុំច្បាស់ថា វិធីសាស្ត្រនោះគឺដូចគ្នា ដូចដែលខ្ញុំរៀបរាប់សម្រាប់ខ្លួនឯងនោះដែរ។ ដូចដែល

លោកអាចឃើញហើយគឺយើងមិនធ្វើមួយពាក្យកត់ត្រាពាក្យតាមពាក្យនោះទេ មិនមែនទម្រង់ហ្នឹងទេ។ ដោយមិនដឹងថាយើងផលិតក្រោយមកហ្នឹងគឺគេប្រាប់គឺថាឲ្យធ្វើនូវសេចក្ដីសង្ខេបដែលសត្យានុម័ត។

**ស៖** បាទ ខ្ញុំសូមឯកសារនោះត្រឡប់មកវិញ។ ឥឡូវនេះ យើងនឹងបន្តទៅទៀតមើលទៅលេខនៅក្នុងទំព័រទី៥ នៃបញ្ជីលេខឯកសារនោះ។ បាទមានចំណងជើងថា "បទសម្ភាសន៍ជាមួយនឹង អៀង សារី" ហើយយើងឃើញនៅក្នុងបទសម្ភាសន៍នៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ ហើយនិង១៧ ខែធ្នូ ឆ្នាំ១៩៩៦។ ខ្ញុំនិយាយអំពីចំណុចទី១ គឺលេខ៧៤, ៧៥, ៧៦ ដែលទាក់ទងទៅនឹងថ្ងៃទាំងនេះគឺយើងមានខ្សែអាត់ជាសំឡេង។ តើលោកបានសម្ភាសលោក អៀង សារី នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ នោះតើមានថតជាខ្សែអាត់សំឡេងដែរឬទេ?

[១០:២៩:៣២]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថាខ្ញុំអាចរៀបរាប់អំពីអ្វីដែលបានកើតឡើងនៅពេលដែលជួបជាមួយលោក អៀង សារី កាលណោះ។ នៅក្នុងដំណើរការដែលយើងបានជួបនោះយើងបានសម្ភាសដោយថតជាខ្សែអាត់ ដោយគាត់បានយល់ព្រមឲ្យថត ជាពិសេស គឺដោយមានវត្តមាននៅសមមិត្តជាលេខារបស់គាត់ឈ្មោះ អ៊ី ឈាន ដែលនាំគាត់ទៅកន្លែងយើងសម្ភាសនៅអូតែលមួយនៅចាន់បូរីនៅប្រទេសថៃ។ បន្ថែមលើកឯកសារខ្សែអាត់សំឡេងនេះ គឺយើងមានការសន្ទនាដែលជាការសន្ទនាក្រៅផ្លូវការ ដែលធ្វើឡើងនៅពេលពិសាអាហារផ្សេងៗនៅអូតែលនោះដែរ នៅក្នុងសណ្ឋាគារនោះដែរ។ គឺថាអ៊ីចឹងអ្វីៗទាំងអស់ដែលយើងសួរនាំដេញដោល គឺមិនបានឆ្លុះបញ្ចាំងនៅក្នុងខ្សែអាត់ទាំងបីនោះទេ។ ប៉ុន្តែភាគច្រើនគឺបាននៅក្នុងខ្សែអាត់នោះហើយ។

**ស៖** ខ្ញុំនឹងសួរសំណួរពិស្តារបន្ថែមទៀត ប៉ុន្តែគ្រាន់តែសូមឲ្យលោកបញ្ជាក់ទេសំណួរនេះ។ អ៊ីចឹងតាមពិតនៅក្នុង នៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ តើលោកអាចពន្យល់បានទេ តើយើងប្រើកំណត់ហេតុផ្ទាល់ដៃ ឬក៏ប្រើខ្សែអាត់ថតសំឡេងនៃបទសម្ភាសន៍ហ្នឹង?

[១០:៣១:៣៣]

**ឆ៖** បាទ ទី១នេះគឺមានលក្ខណៈក្រៅផ្លូវការបន្តិច។ យើងបានជួបគ្នានៅក្នុងកន្លែងទទួលភ្ញៀវរបស់សណ្ឋាគារ អូតែលរ៉ូយ៉ាល់ភ្នំពេញ នៅទីក្រុងភ្នំពេញនេះឯង។ ក្រោយមកអូតែលនោះ ក៏ត្រូវបានបាត់ទៅវិញ គឺដោយសារមានការបាតុកម្មប្រឆាំងថៃក៏បានខូចខាតអស់ទៅ។ ខ្ញុំមានសៀវភៅកត់ត្រាតូចមួយដែលថាកត់ត្រាហ្នឹងក្រៅផ្លូវការ ខ្លះគឺយើងមានការសន្ទនា ហើយខ្ញុំកត់ត្រឡប់ឡើងត្រឡប់ចុះនៅ

ក្នុងកូនសៀវភៅរបស់ខ្ញុំនោះ។

**ស៖** តើលោកសួរឡើងចុះអំពីបញ្ហាបច្ចុប្បន្នកាល កាលនោះ ឬក៏នៅក្នុងអតីតកាល?

**ឆ៖** ខ្ញុំគិតថា មានអ្វីដែលខ្ញុំបានធ្វើឡើងដែលខ្ញុំបំពេញបន្ថែមនៅពេលក្រោយបញ្ហាដែលខ្លឹមសារដែលខ្ញុំកត់ត្រានៅកាលនោះ ទាក់ទងទៅនឹងមូលដ្ឋាននៃឯកសារមជ្ឈិមដែលទាក់ទងបញ្ហាមួយចំនួន ហើយឯកសារក្រៅផ្លូវការ ហើយបើនិយាយពីបរិយាកាសនោះ គឺខ្ញុំបានបន្ថែមនៅពេលក្រោយ។

[១០:៣៣:១២]

**ស៖** ទំព័រទី៥ គឺបទសម្ភាសន៍ជាមួយជនភៀសខ្លួន។ សូមលោកពន្យល់តុលាការ ខ្ញុំមិនឲ្យលោកពណ៌នាអំពីប្រវត្តិមូលនិធិ ឬក៏ថវិកាអីទេ គឺថាតើអ្នកណាខ្លះដែលលោកសម្ភាសនៅព្រំដែនខ្មែរ-ថៃ នៅខែកុម្ភៈ ខែមីនា ឆ្នាំ១៩៨០ នោះបាទ?

**ឆ៖** បាទ បទសម្ភាសន៍ទាំងអស់នេះបានធ្វើឡើងនៅភាគីខាងថៃ ទាំងស្រុង គឺនៅជិតព្រំដែនខ្មែរ-ថៃ គឺពីខែកុម្ភៈ ដល់ខែមីនា ឆ្នាំ១៩៨០ ហើយភាគច្រើនបើមិនមែនជាបទសម្ភាសន៍គ្រប់ទាំងអស់ចុងក្រយនោះទេ។ ខ្ញុំមានអ្នកអមដំណើដោយអ្នកកាសែតជប៉ុនម្នាក់មកពីតូក្យូញ៉ូវ ម៉ាតាស៊ីវាក់ នោះ។

**ស៖** ហើយខ្ញុំនឹងសួរលម្អិតពីបទសម្ភាសន៍ជាមួយអ្នកជនភៀសខ្លួននៅពេលក្រោយ តើលោកបានធ្វើសម្ភាសគ្រប់ទាំងអស់ជាមួយ ម៉ាស៊ុស៊ីតា ឬក៏ប៉ុន្មាន? តើលោកអាចបំភ្លឺបានទេ?

**ឆ៖** ខ្ញុំមិនប្រាកដថា ខ្ញុំយល់សំណួរលោកទាំងអស់ទេ ខ្ញុំបានធ្វើសម្ភាសគ្រប់ទាំងអស់ដោយខ្លួនឯង។ ប៉ុន្តែមានឱកាសមួយចំនួនដែលខ្ញុំពន្យល់ ម៉ាស៊ុស៊ីតា នោះ នៅពេលដែលគាត់សួរខ្ញុំឲ្យសួរបន្ថែមនោះ? អ៊ីចឹងត្រឹមត្រូវដែលថាបទសម្ភាសន៍ ៩៩.៩ ដែលខ្ញុំសួរសំណួរ ហើយខ្ញុំកត់ត្រានៅក្នុងសំណុំរឿងដែលថា -- នៅក្នុងសំណុំឯកសារដែលខ្ញុំមាននោះ។

[១០:៣៥:១៨]

**ស៖** យើងទៅមើលទំព័រទី៥ ដដែលគឺបទសម្ភាសន៍នៅ អូ.ស៊ី.អាយ.ជេ – ការិយាល័យសហចៅក្រមស៊ើបអង្កេត – លោកបញ្ជាក់បានទេ តើលោកបានធ្វើបទសម្ភាសន៍ណាខ្លះទេ នៅពេលដែលលោកធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** និយាយពីការិយាល័យសហចៅក្រមស៊ើបអង្កេត?

**ស៖** នៅទំព័រលេខ៥ នៅខាងក្រោមដែលមានចំណងជើងថា "បទសម្ភាសន៍ការិយាល័យសហចៅក្រមស៊ើបអង្កេត"។

**ឆ៖** បាទ បទសម្ភាសន៍ទាំងអស់នោះត្រូវបានធ្វើឡើងនៅពេលដែលអង្គការសហប្រជាជាតិផ្តល់ជំនួយដល់សាលាក្តីខ្មែរក្រហមនេះ។ ខ្ញុំបានធ្វើការសម្ភាសមួយចំនួនក្នុងអំឡុងពេលដែលមានកិច្ចស៊ើបអង្កេតនោះឯង។

**ស៖** ឥឡូវនេះ បាទអរគុណ យើងចូលទៅដល់ទំព័រលេខ៦ ពិនិត្យមើលលេខ៩៤, ៩៥, ៩៦, ៩៧ ហើយនិង៩៩។ លោកឃើញនៅក្នុងចំណាងជើង គឺថាមានឈ្មោះ ហើយនិយាយថា អ៊ី.ស៊ី.ស៊ី.ស៊ី អូ.ស៊ី.ភី។ តើលោកនៅចាំថាបានធ្វើការកត់ត្រាចម្លើយអ្វីដែលទេ នៅពេលកាលនោះលោកមានថាលោក រ៉ូប៊ឺត ពើទីត ក៏ធ្វើការនៅទីនោះដែរ?

**ឆ៖** បាទ នោះជាបទសម្ភាសន៍នៅពេលដែលខ្ញុំ ដែលសហចៅក្រមស៊ើបអង្កេតបានឲ្យខ្ញុំទៅបម្រើការ។ បានន័យថាឲ្យខ្ញីទៅ អូ.ស៊ី.ភី ខ្ចីដើម្បីផ្តល់សេវានៅក្នុងករណីខ្លះ ដែលថាលោក រ៉ូប៊ឺត ពើទីត បានធ្វើបទសម្ភាសន៍ទាំងអស់នៅពេលដែលដូចដែលបានបញ្ជាក់នេះ។

[១០:៣៧:៣២]

**ស៖** ហើយយើងអាចចូលទៅទំព័រ៦ ដដែលនោះ យើងមានចំណាងជើងថា "បទសម្ភាសន៍ដទៃទៀត"។ គឺថាមានលេខមួយចំនួនខ្ញុំមិនអាចនឹងបញ្ជាក់បាន ថាតើមានចំណាងជើងដូចម្តេចនោះ? បាទសូមពិនិត្យមើលលេខ៨៨។ បាទអ៊ីចឹងយើងទៅមួយលេខម្តង។ បាទ៨៨នេះគឺកាលបរិច្ឆេទថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩០ ឯកសារលេខ E3/390 គឺថាលេខ D គឺ D210/9។

**លោក ឃឹត វេយ៍ន័រ៖**

លោកប្រធានដើម្បីជួយបញ្ជាក់ ខ្ញុំសូមអនុញ្ញាតជូនឯកសារនេះទៅលោក ហេដឌ័រ។

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតជូនឯកសារនេះទៅលោក ហេដឌ័រ។ ខ្ញុំមិនចង់ឲ្យលោកបញ្ជាក់ឈ្មោះសាក្សីនេះទេ គ្រាន់តែឲ្យលោកបញ្ជាក់អំពីកាលៈទេសៈនៃការដែលលោកសម្ភាសនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:៣៩:២៧]

**លោក ស៊្មីរ ហេដឌ័រ៖**

**ឆ៖** បាទ ខ្ញុំបានធ្វើបទសម្ភាសន៍នេះនៅតាម នៅពេលដែលដូចកំណត់នៅក្នុងទីក្រុងភ្នំពេញ ជាមួយបុគ្គលដែលបានបញ្ជាក់ឈ្មោះ។ ហើយឯកសារដែលលោកបានឲ្យមកខ្ញុំនេះ បញ្ជាក់ថាធ្វើបទសម្ភាសន៍ហ្នឹងគឺបានកត់ត្រាដោយខ្សែអាត់។ ការបកប្រែនេះមិនមែនរបស់ខ្ញុំទេ ជាការបកប្រែរបស់តុលាការ បកប្រែមកពីប្រតិចារឹកនៃខ្សែអាត់សំឡេងបទសម្ភាសន៍នោះ ដើម្បីបំភ្លឺនេះគឺនៅពេលដែលខ្ញុំធ្វើការមកផ្នែកមួយនៃកិច្ចការប្រវត្តិសាស្ត្ររបស់សាកលវិទ្យាល័យអូស្ត្រាលី បាទ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា! អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមបញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ យើងដល់ទំព័រ៦ គឺលេខរៀងទី៨៨ ឯកសារ E3/390។ លោកថា លោកសម្ភាសបុគ្គលរូបនេះនៅក្នុងទីក្រុងភ្នំពេញ។ លោកអាចជម្រាបបានទេ អ្នកណាជាអ្នកវាយប្រតិចារឹកនៃកិច្ចសម្ភាសន៍ ក្រោយកិច្ចសម្ភាសន៍អ្នកណាជាអ្នកវាយជាប្រតិចារឹកនោះ?

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** មិនមែនខ្ញុំទេ។ ខ្ញុំគិតថាខ្ញុំមិនបានវាយប្រតិចារឹក ឬក៏បកប្រែដោយខ្លួនខ្ញុំនោះទេ។ ដូច្នេះតាមដែលខ្ញុំដឹងទាំងប្រតិចារឹក គឺវាជាភាសាខ្មែរ ហើយការបកប្រែ បកប្រែជាភាសាអង់គ្លេស។ ដូច្នេះគឺជាប្រតិចារឹកដែលវាយឡើងដោយតុលាការតែម្តង។

**ស៖** ខ្ញុំសូមជំនួយដើម្បីបង្ហាញឯកសារជូនលោកនៅខាងចុងតុនេះ។ សូមឲ្យមន្ត្រីតុលាការយកជូនសាក្សី។

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំសូមបន្តចូលដល់លេខរៀង៨៩ គឺឯកសារ D2/10។ បាទគឺជាឯកសារជាប់ពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍នេះ។ ខ្ញុំសូមពន្យល់ថា ខ្ញុំនឹងមិនលើកពីឈ្មោះបុគ្គលដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ។ សូមការអនុញ្ញាតជូនឯកសារទៅសាក្សី។

[១១:០៣:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ ខ្ញុំឃើញថាលោកកំពុងតែពិនិត្យមើលឯកសារនេះ។ សំណួរដំបូងគឺពេលលោកមើលនោះគឺទំព័រទីនៃកិច្ចសម្ភាសន៍ដោយលោក។ សូមមេត្តាឆ្លើយផងនៅពេលដែលលោកកំពុងតែអានឯកសារនេះ?

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** ហេតុផលដែលខ្ញុំចំណាយពេលវេលាពិនិត្យមើលឯកសារនេះ ទោះណាជាឯកសារនេះមានចំណងជើងនិយាយថាជាកិច្ចសម្ភាសន៍ស្តាប់ចម្លើយដោយរូបខ្ញុំក៏ដោយ ដោយសារតែបុគ្គលនេះខ្ញុំនឹក

ឃើញឈ្មោះនោះទេ គឺខ្ញុំមើលទៅលើខ្លឹមសាររបស់ឯកសារដើម្បីព្យាយាមនឹកមើលថាតើអ្នកណា ដែលខ្ញុំសម្ភាស ខ្ញុំនឹកមិនទាន់ឃើញទេ។

**ស៖** បាទលោកអាចប្រើប្រាស់ពេលវេលាដើម្បីពិនិត្យមើលតាមហ្នឹងចុះ។

[១១:០៦:៣០]

*(សម្រាករយ:ពេលខ្លី)*

[១១:០៨:០៤]

**ឆ៖** ដោយសារមិនមានពេលអានឲ្យបានច្រើន និងស្តាប់ខ្សែអាត់ ខ្ញុំមិនដឹងថាបុគ្គលនេះជាអ្នកណានោះទេ ប៉ុន្តែមិនមែនមនុស្សដែលមានឈ្មោះនៅលើក្បាលទំព័រឯកសារនេះទេ។

**ស៖** ក្រៅពីឈ្មោះ តាមដែលលោកអានឯកសារនេះហើយ តើលោកជាអ្នកធ្វើកិច្ចសម្ភាសន៍នេះតែម្តងឬក៏មិនមែនទេ?

**ឆ៖** បើមើលទៅលើខ្លឹមសារឃ្លាប្រយោគ គឺខ្ញុំយល់ថាជាកិច្ចសម្ភាសន៍ដោយខ្ញុំហើយ។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមស្នើសុំថា ខ្ញុំសុំប្រគល់ឯកសារនេះជូនសាក្សីដើម្បីអាននៅពេលសម្រាកបាយថ្ងៃត្រង់។ ដូច្នេះគាត់អាចជម្រាបជូនអង្គជំនុំជម្រះបាននៅពេលរសៀល។ សូមការអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៩:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែសាក្សីត្រូវតែរក្សាការសម្ងាត់បន្ទាប់ពីការពិនិត្យ និងការអាននូវឯកសារនោះ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមបន្តទៅទៀតលោក ហេដឌ័រ លោកអាចរក្សាឯកសារនេះទុកអានសិនចុះ។ ខ្ញុំសូមសួរលេខរៀងទី៩១ គឺឯកសារ E190.1.72 គឺជាកិច្ចសម្ភាសន៍ជាមួយឈ្មោះ វ៉ាន់ រិទ្ធ។ លោកប្រធានសូមការអនុញ្ញាតជូនឯកសារនេះទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនជម្រះអនុញ្ញាត!

**សួរដោយលោក ឃើត រេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ ឯកសារនេះមានជាអក្សរពុម្ពផង ជាអក្សរសរសេរដោយដៃផង?

[១១:១០:៥៩]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ នេះគឺជាៗកំណត់ត្រាដែលសរសេរដោយដៃ គឺជាអ្វីដែលខ្ញុំធ្លាប់តែធ្វើនៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំរយៈពេលជាច្រើនឆ្នាំមកនោះ។ ខ្ញុំសម្ភាស វ៉ាន់ រិទ្ធ នៅផ្ទះរបស់គាត់នៅខេត្តកណ្ដាល កិច្ចសម្ភាសន៍នេះពេលខ្ញុំធ្វើការនៅ សូអាស ខ្ញុំធ្វើការនៅការិយាល័យមួយរបស់សូអាស ទាក់ទងទៅនឹងផ្នែកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯការវាយអក្សរពុម្ពនោះ គឺដោយតុលាកាយើងនេះតែម្ដង មិនមែនដោយខ្ញុំនោះទេ។

**ស៖** បាទ សូមមេត្តាជូនឯកសារនេះត្រឡប់មកវិញ ដើម្បីយើងដាក់ចូលទៅក្នុងសំណុំរឿង។

**លោក ឃើត រេយ៍ន័រ៖**

លោកប្រធាន ភាគីទាំងអស់ គឺមានឧសម្ព័ន្ធនៃឯកសារនេះហើយ ថាតើក្នុងកិច្ចដំណើរការនីតិវិធីជាមួយនីតិវិធីនេះ គឺដើម្បីឲ្យខាងផ្នែកប្រតិចារឹកអាចជួយយកឯកសារនេះទៅដើម្បីជួយដល់កិច្ចការរបស់ពួកគាត់នៅថ្ងៃខាងមុខនេះ។ សំណើសុំ គឺថាសូមភ្ជាប់ជាមួយទៅនឹងប្រតិចារឹកប្រចាំថ្ងៃដែលវាយឡើងដោយក្រឡាបញ្ជី។

[១១:១២:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក ឃើត រេយ៍ន័រ៖**

សូមអរគុណ។

**សួរដោយលោក ឃើត រេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ អ្វីដែលខ្ញុំបន្តទៅទៀត គឺខ្ញុំចង់បង្ហាញលោកដោយជ្រើសរើសនៅផ្នែកខ្លះនៃសៀវភៅរបស់លោក និយាយពាក្យដោយខ្លី គឺឯកសារ E3/22 និយាយពីកុម្មុយនីស្តកម្ពុជា។ តាមការអនុវត្តកន្លងមកជាមួយ ដេវីដ ឆេនល័រ និងហ្វីលីព ស្ប៊ត នេះគឺសូមការអនុញ្ញាតជូនផ្នែកមួយនៃសៀវភៅរបស់គាត់ ដើម្បីឲ្យគាត់ជួយដល់តុលាការ។

**លោក ឃីត វេយ៉ន៍រ៖**

លោកប្រធាន សុំការអនុញ្ញាតជូនផ្នែកនៃសៀវភៅរបស់លោក ហេងឌ័រ ជូនទៅគាត់។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:១៤:១៥]

**សួរដោយលោក ឃីត វេយ៉ន៍រ៖**

**ស៖** លោក ហេងឌ័រ ឯកសាររបស់ -- នៅទំព័រទី១ ឯកសារលេខ១ គឺកុម្មុយនីស្តកម្ពុជា និងគំរូវៀតណាម ហើយបន្ទាប់មកលោកមានលេខយោងជើងទំព័រ បើលោកចង់យោងជើងទំព័រ ហើយសុំរៀបរាប់ម្តងមួយជំពូក។ លោកមានឧសម្ព័ន្ធនៅផ្នែកខាងស្តាំនៃឯកសាររបស់លោក និយាយអំពីជំពូក ហើយខ្ញុំបង្ហាញលោកទៅទំព័រជាក់លាក់ណាមួយដោយសារថា ខ្ញុំត្រូវការជ្រើសរើសទំព័រខ្លះតែម្តង។ តើក្នុងការសរសេរសៀវភៅហ្នឹង តើវាមានកត្តាអ្វីដែលជំរុញឲ្យលោកសរសេរសៀវភៅនេះ?

**ឆ៖** ការសិក្សាស្រាវជ្រាវត្រូវ គឺថាត្រូវតែមានការជំរុញអ្វីមួយអ៊ីចឹងហើយ។ វាត្រូវតែចេញពីបេះដូងរបស់យើង។ ជួនកាលដោយសារតែព្រឹត្តិការណ៍កាលៈទេសៈពិសេសៗ ចម្លែកណាមួយនោះ ឲ្យយើងធ្វើដូច្នេះ។ វាជាផ្នែកមួយនៃប្រវត្តិសាស្ត្រដែលនាំឲ្យយើងធ្វើការងារនេះឡើង។ វាជាផ្នែកមួយនៃសេចក្តីផ្តើមពាក់ព័ន្ធទៅនឹងជំពូកត្រង់ណា -- ពេលនោះគឺថាវាជំពូកនានាវាពាក់ព័ន្ធទៅនឹង*តែស្លា*នៃបណ្ឌិតរបស់ខ្ញុំផង។ កាលណាលោកនិយាយថា តើមានចលករអ្វី ឬក៏មានកត្តាអ្វីដែលជំរុញឲ្យខ្ញុំសរសេរនូវសៀវភៅនេះ គឺថាខ្ញុំសរសេរដើម្បីទទួលយកសញ្ញាបត្របណ្ឌិតរបស់ខ្ញុំ វាជាការសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយ។ អ៊ីចឹងឯងបានជាខ្ញុំទទួលបានងារជាបណ្ឌិតនេះឯង។

[១១:១៦:៤១]

**ស៖** តើ -- ខ្ញុំនិយាយចម្លើយរបស់ខ្ញុំជូនចៅក្រម ខាតរ៉ាយថ៍ ឡើងវិញ គឺថាមិនមានឯកសារនេះជាភាសាបារាំងទេ។ មានដកសម្រង់ -- បកប្រែសម្រង់ខ្លះៗជាភាសាខ្មែរ ហើយខ្ញុំស្នើសុំឲ្យបកប្រែគ្រប់ផ្នែកទាំងអស់ ក្រោយពីការពិភាក្សាដេញដោលលើឯកសារនេះហើយនោះ។ ទំព័រ២៦ គឺនៅជំពូក១នៃសៀវភៅរបស់លោកនេះ ERN ជាភាសាអង់គ្លេស 00393689។ ត្រង់ទំព័រនេះលោកសរសេរអំពីព្រឹត្តិការណ៍នៅទសវត្សរ៍១៩៥០ នៅក្បាលទំព័រ ក្រោយមកទំព័រ -- ឆ្នាំ៥១ ហើយបានក្រោយមកទៀត

១៩៥៤ និយាយអំពីកុម្មុយនីស្តកម្ពុជានៅកម្ពុជា។ សម្រង់ដែលខ្ញុំចង់លើកឡើង គឺដូចខាងក្រោមនេះ សូមដកស្រង់ “ទោះប្រជាជនកម្ពុជាមានប្រជាជនប៉ុន្មានក៏ដោយ គឺថាវៀតណាម គឺថាដាក់បញ្ចូលរបស់គេនូវអត្តចរិតនៃភាពកាចសាហាវចំពោះខ្មាំងរបស់បដិវត្តន៍ ទាំងបរទេស ទាំងអ្នកក្នុងស្រុក។ ស៊ីវ បានប្រកាសថាក្នុងពេលទស្សនកិច្ចទៅវៀតណាម មធ្យោបាយសម្រាប់កម្ពុជារស់នៅដោយមានសេរីភាពនោះគឺត្រូវសម្លាប់ពួកឈ្មានពាន ចក្រពត្តិឈ្លានពានទាំងអស់។ គឺជាប្រមូលផ្តុំនៃក្រុមឆ្កែឆ្កួតដែលត្រូវតែកម្ចាត់ចោល”។ គឺលេខយោងជើងទំព័រត្រង់៨០ បាទ គឺជាសុន្ទរកថាដែលផ្តល់ឡើង ធ្វើឡើងដោយ ស៊ីវ ហេង នៅក្នុងសមាជលើកទី១។ វី.អ៊ិន.អេស.អ័រ-ធូ ខែធ្នូ ១៩៥០។

[១១:១៨:៥៥]

ប្រភពនៃលេខយោងជើងទំព័រនោះគឺ វី.អ៊ិន.អេស ខ្ញុំមិនដឹងថាតើ វី.អ៊ិន.អេស យោងទៅអ្វីនោះទេ។ តើលោកឃើញសុន្ទរកថាដែលធ្វើឡើងដោយលោក ស៊ីវ ហេង នេះដោយប្រើពាក្យ វី.អ៊ិន.អេស នេះ លោកអាចជួយបញ្ជាក់បានទេ?

**ឆ៖** នេះគឺមានន័យថា សេវាថ្មីៗរបស់វៀតណាម សារព័ត៌មានថ្មីៗរបស់វៀតណាម របស់សាធារណសង្គមនិយមវៀតណាម ដែលធ្វើឡើងជាច្រើនភាសា មានភាសាអង់គ្លេស។ បើខ្ញុំចាំមិនច្រឡំទេ វាមានសេវាព័ត៌មានវៀតណាមថ្មីៗពេញទាំងស្រុងតែម្តង នៅសាកលវិទ្យាល័យខូណែល។

**ស៖** នៅផ្នែកមួយទៀត គឺសម្រង់ដែលខ្ញុំសូមដកស្រង់ដូចតទៅ៖ “នៅពេលដូចគ្នានេះ កម្ពុជាត្រូវតែអនុវត្តការសម្លាប់ពួកក្បត់នៅក្នុងភូមិភាគដែលគេបានរំដោះ និងដោះស្រាយជាមួយនឹងភ្នាក់ងារសម្ងាត់ជាច្រើនដែលជ្រាបចូលមកក្នុងចលនាដើម្បីព្យាយាមបង្កវិទ្ធង្សនាដល់បដិវត្តន៍ និងបំផ្លិចបំផ្លាញអង្គការបដិវត្តន៍”។ ហើយលេខយោងទំព័រគឺលេខ៨២ យោងទៅលើគណៈកម្មាធិការសន្តិភាពខ្មែរចលនាតស៊ូខ្មែរ ខែតុលា ១៩៥២។ វាជាខិត្តប័ណ្ណដែលផ្សព្វផ្សាយដោយផ្នែក វ៉ង់ហ្គូន នៃសេវាព័ត៌មានវៀត-ណាម។ តើប្រភពនេះ គឺជាប្រភពតែមួយដែលលោកបានលើកឡើងអម្បាញ់មិញ គឺ វី.អ៊ិន.អេស ហ្នឹងឬយ៉ាងណា?

[១១:២១:២១]

**ឆ៖** ប្រភពពីមុននោះ វាជាសារព័ត៌មានផ្សព្វផ្សាយដោយសេវាព័ត៌មានវៀតណាមប្រចាំថ្ងៃ។ វាជាសារព័ត៌មានពិសេស។ ជាការបោះពុម្ពពិសេសជាភាសាអង់គ្លេស ហើយក៏មានតម្កល់នៅសាកលវិទ្យាល័យខូណែលនោះផងដែរ នៅបណ្ណាល័យនៃសាកលវិទ្យាល័យខូណែល។

**ស៖** ខ្ញុំសូមចូលទៅទំព័រ៣ ត្រង់ជំពូក៣ ត្រង់ទំព័រ៥២ ERN ជាភាសាអង់គ្លេស 00393715, លោកនិយាយអំពីព្រឹត្តការណ៍ក្នុងឆ្នាំ១៩៦០។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ “នៅក្នុងខែមករា ១៩៦០ ថ្នាក់ដឹកនាំបង្កឲ្យមានការបេះបោរជាយុទ្ធសាស្ត្រ ដើម្បីឈានទៅដល់សកម្មភាពយោធា។ ដោយសារត្រូវតែយកការតស៊ូនយោបាយរួមជាមួយនឹងការតស៊ូអាវុធ។ បើមិនដូច្នេះ គឺថាមិនខ្លាំងគ្រប់គ្រាន់ដើម្បីគ្រប់គ្រងមូលដ្ឋានបដិវត្តន៍”។ ហើយក៏ -- ដូច្នេះត្រូវតែប្រើអាវុធដើម្បីទប់ស្កាត់ជាមួយអំពើសាហាវយង់ឃ្នងរបស់ខ្មាំង។ សូមដកស្រង់ “គឺទាំងការតស៊ូនយោបាយ និងប្រដាប់អាវុធត្រូវតែរួមបញ្ចូលគ្នាទាំងពីរនេះ គឺថាត្រូវដើរតួយ៉ាងសំខាន់នៅក្នុងចលនាបដិវត្តន៍។ មានន័យថាជា -- មានន័យថាទាំងផ្នែកនយោបាយ និងអាវុធ គឺថាត្រូវតែរួមជាមួយគ្នា”។ គឺលេខយោងទំព័រ១៧ សង្គ្រាមវៀតណាម ទំព័រ៤០។ តើលោកអាចជម្រាបជូនបានទេចំពោះប្រភពនេះ ឬក៏លោកអាចពន្យល់បន្ថែមទៀតក៏បានដែរ? សូមអរគុណ។

[១១:២៣:៤០]

**ឆ៖** អ្នកនិពន្ធ តាមដែលខ្ញុំដឹងគឺជាអ្នកនិពន្ធមកទសវត្សរ៍១៩៦០ មកពីវៀតណាមខាងត្បូង។ តាមបទពិសោធន៍របស់គាត់ គាត់ជាភ្នាក់ងារសម្ងាត់ផ្នែកខាងយោធា។ ហើយក្រោយមកគាត់ធ្វើការសិក្សាស្រាវជ្រាវជាន់ខ្ពស់។ នេះគឺជាសៀវភៅដែលគេបានបោះពុម្ពផ្សាយនៅក្នុងបរិបទនេះ គឺវាយោងទៅកុម្មុយនីស្តនៅវៀតណាមខាងត្បូង។ មិនមែនកុម្មុយនីស្តនៅកម្ពុជានោះទេ។ ដូច្នេះវាពាក់ -- បើសិនណាជាយល់ស្របទៅនឹងទឡ្ហីករណ៍របស់ខ្ញុំក្នុងសៀវភៅរបស់ខ្ញុំ គឺវាដោយសារឥទ្ធិពលកុម្មុយនីស្តវៀតណាមខាងត្បូងនេះឯង។

**ស៖** លោកបានឆ្លើយទៅនឹងសំណួរបន្ទាប់របស់ខ្ញុំរួចទៅហើយ។ បាទ នៅជំពូក៣ដដែលទំព័រ៥៩, ERN ជាភាសាអង់គ្លេស 00393722 គឺផ្នែកដែលពាក់ព័ន្ធទៅនឹង ខៀវ សំផន ពេលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ។ ឃ្លាចុងក្រោយមុនលេខជើងទំព័រ៦៥ បាទ សូមកែតម្រូវផង គឺកន្លែងនេះគឺនិយាយសំដៅទៅលើ ខៀវ សំផន។ សូមដកស្រង់៖ “គាត់មិនបានក្លាយទៅជាសមាជិកបក្សកម្ពុជានោះទេ ក្រោយពីគាត់ត្រឡប់មកវិញ ប៉ុន្តែគេហាក់បីដូចជាធ្វើបន្ទន់ឥរិយាបថរបស់គាត់ជាង ហ៊ូ យន់ និង ហ៊ូ នឹម”។ គឺយោងទៅលើ អ៊ិន សុភាព និង ខៀវ សំផន នេះត្រង់លេខយោងទី៦៥។ ចំពោះ អ៊ិន សុភាព នេះលោកអាចជម្រាបឲ្យច្បាស់បន្តិចបានទេ?

[១១:២៦:០៧]

**ឆ៖** ខ្ញុំអត់មានហ្វូតណូតនៅចំពោះមុខខ្ញុំទេ។ នេះគឺជាព័ត៌មានដែរសរសេរឡើង “អ៊ិន សុភាព

ជាអ្នកឆ្វេងនិយមកម្ពុជា" ហើយក្រោយមក គាត់បានសរសេរ និងបោះពុម្ពផ្សាយនូវប្រវត្តិរបស់ ខៀវ សំផន ហើយអត្ថបទដែលខ្ញុំទទួលបានយកមកនោះ គឺជាសេចក្តីព្រាងដើមនៃប្រវត្តិរូបនោះ ដែលបោះពុម្ពផ្សាយនោះ។ តាមដែលខ្ញុំចាំ ប្រហែលជាក្នុងពាក់កណ្តាលឆ្នាំ១៩៩០ ពេលដែលខ្ញុំជួបជាមួយនឹង អ៊ិន សុភាព។

**ស៖** ក្នុងការនិយាយទៅកាន់ អ៊ិន សុភាព ហើយលោកក៏បានទទួលបាននូវសេចក្តីព្រាងនូវសៀវភៅដំបូង ឬក៏ខ្ញុំច្រឡំសូមបញ្ជាក់ផង។

**ឆ៖** ខ្ញុំជួបគាត់ គឺនៅក្នុងប្រទេសកម្ពុជា ប្រហែលជាដើម ឬពាក់កណ្តាលទសវត្សរ៍៩០។ គាត់បានសេចក្តីព្រាងនៃឯកសារនេះមកខ្ញុំ។ បើខ្ញុំចាំមិនច្រឡំទេ គឺជាភាសាបារាំង។

[១១:២៨:០៧]

**ស៖** សូមអរគុណ។ ជំពូក៤ ត្រង់ទំព័រ៦៩ ERN ជាភាសាអង់គ្លេស 00393726 និយាយពីសមាជឆ្នាំ១៩៦០។ សូមដកស្រង់ដូចតទៅ៖ "នៅក្រោមមនោគមន៍វិជ្ជាដែលមាន ដែលបើកសញ្ញាពណ៌លឿងនោះ សមាជបក្សកម្ពុជាធ្វើឡើងពីថ្ងៃទី២៨ ដល់ទី៣០ កញ្ញា ១៩៦០ ដែលចូលរួមដោយ --, ជំពូក៤ ត្រង់ទំព័រ៦៣។ ខ្ញុំសូមចាប់ផ្តើមម្តងទៀត៖ "ដោយមានមនោគន៍វិជ្ជាភ្លើងលឿងនោះ សមាជបក្សកម្ពុជាត្រូវបានធ្វើឡើងយ៉ាងស្ងាត់នៅទីក្រុងភ្នំពេញពីថ្ងៃ២៨-៣០ ខែកញ្ញា ១៩៦០ ដែលចូលរួមដោយសមាជិកប្រាំពីរនាក់នៃអង្គការបក្សនៅជនបទ ហើយនិង១៤នាក់ទៀតមកពីសាខានៅជនបទ។ ឯកសារបីសំខាន់ត្រូវបានព្រៀងដោយ ស ហើយយល់ព្រមឲ្យយល់ព្រមទទួលយកដោយ នួន។ វាជាមាគ៌ាយុត្តិ-សាស្ត្រ និងមាគ៌ាយុទ្ធវិធី"។ គឺលេខយោងនោះនិយាយអំពីប្រវត្តិរឿងរ៉ាវរបស់ នួន ជា។ ប្រវត្តិនៃការចលនាតស៊ូរបស់កសិករកម្ពុជាយើងពី១៩៥៤ ទៅដល់១៩៧០ គឺបានផ្តល់ទៅឲ្យ នេត ថាយ័រ នៅក្នុងឆ្នាំ១៩៦០គឺឯកសារ E3/131។ លោក ហេដឌ័រ ខ្ញុំសូមសួរអំពីប្រភពនៃឯកសារនេះម្តងទៀត សូមលោកជួយបញ្ជាក់។

[១១:៣០:៣៤]

**ឆ៖** បើសិនជាខ្ញុំចាំមិនច្រឡំទេ នៃគឺជាសំណេរដោយដៃជាភាសាខ្មែរ។ ឯកសារនេះបានផ្តល់ទៅឲ្យ នេត ថាយ័រ ដោយមនុស្សម្នាក់ឈ្មោះ ខឹម ងុន ខ្ញុំដឹងថាគាត់ឥឡូវនេះជាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជា។ ខឹម ងុន គឺនិយាយយោងទៅលើអ្វីដែល នួន ជា ខ្លួនឯងបានសរសេរ ឬការកត់ត្រាដែលដោយ ខឹម ងុន ដែលសរសេរចេញពីអ្វីដែលបានព្រាងឡើងដោយ នួន ជា។ នៅត្រង់ជំពូក៤ដដែល

គឺទំព័រ៦៩ ERNជាភាសាអង់គ្លេស 00393732។ ចំណុចនេះនិយាយអំពីទំនាស់ គឺសូមដកស្រង់ដូចតទៅ៖ "ទំនាស់នៅក្នុងសង្គមកម្ពុជាក្នុងចំណោមវណ្ណៈទាំងប្រាំដែលវៀតណាមថា មានអត្ថិភាពនៅក្នុងប្រទេសកម្ពុជានៅដើមទសវត្សរ៍១៩៥០ (មានកសិករ ពលករ ពួកមូលធន ពួកសក្តិភូមិត្រូវបានគេយល់ថាគឺតែមួយទេ គឺបក្សពលករវៀតណាមយល់ថា មានអត្ថិភាពនៅវៀតណាមខាងត្បូងនៅក្នុងឆ្នាំ១៩៦០)។ សមាជរបស់បក្សពលករកម្ពុជាបានប្រកាសថា ភាពស្មុគស្មាញជាច្រើន និងភាព-- និងទំនាស់ចម្រូងចម្រាស់ត្រូវតែរកឲ្យឃើញរវាងពលករហើយនិងពួកអនុធន។ ជាពិសេសវណ្ណៈស្លាប់រស់រវាងកសិករ និងពួកម្ចាស់ដី។ ដូច្នេះ ការតស៊ូនៅក្នុងទីជនបទរបស់កម្ពុជា គឺដើម្បីបុព្វហេតុបដិវត្តន៍ដែលតម្រូវឲ្យមានការប្រមូលកសិករដែលមានចំនួន ៨៥ភាគរយនៃប្រជាជននៅក្នុងប្រទេសទាំងមូល។ ហើយដោយសារតែពួកគេជាជនរងគ្រោះដោយពួកម្ចាស់ដី ពួកគេត្រូវបានវណ្ណៈទាំងនេះ កេងប្រវ័ញ្ចក្រេបជញ្ជក់។ ដូច្នេះ អ្នកទាំងនេះគឺជាប្រភពនៃចលនារបស់កម្ពុជា។ ហេតុដូច្នេះ ត្រូវតែរំដោះប្រជាកសិករ៨៥ភាគរយពីពួកម្ចាស់ដី"។ បញ្ចប់ការដកស្រង់។

[១១:៣៤:០៥]

លេខជើងទំព័រ២៥ យោងប្រភពចំនួនពីរ ជយោ ប៉ុលពត! ដែលមានចំណងជើងពេញតែម្តងថា ៖ "ជយោ! ខួបលើកទី១៧ នៃបក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧ ទំព័រ៣០"។ ឯកសារនេះគឺ E3/145 ដែលមាននៅក្នុងសំណុំរឿង។ ហើយប្រភពទីពីរ គឺសេចក្តីថ្លែងការណ៍របស់ នួន ជា គឺ E3/196។ លោក ហេដឌ័រ ខ្ញុំសូមសួរលោកអំពីប្រភពទី១ ដែលសរសេរថា "ជយោ ប៉ុល ពត!" តើលោកជម្រាបបានទេ? ហើយលេខយោងជើងទំព័រនេះក៏អាចជួយទៅដល់លោកផងដែរ សូមអរគុណ។

**ឆ៖** ខ្ញុំជឿថាអ្វីដែលខ្ញុំប្រើនោះ គឺអត្ថបទជាភាសាខ្មែររបស់សុន្ទរកថាដែលធ្វើឡើងដោយ ប៉ុល ពត នៅក្នុងឱកាសមួយដែលមានការប្រកាសអំពីការតស៊ូរបស់បក្សនៅខែកញ្ញា ឆ្នាំ១៩៧៧ អត្ថបទភាសាខ្មែរដែលយើងទទួលបាននៅសហរដ្ឋអាមេរិកផងដែរនោះ ពីព្រោះនៅពេលនោះ ខ្ញុំនៅសាកលវិទ្យាល័យខូណែល។ អង្គការមួយគេហៅថា ជី.ខេ.រ៉ាម ជាក្រុមតូចមួយនៃកម្ពុជាដែលបានរស់នៅសហរដ្ឋអាមេរិកកាលនោះ ហើយយល់ខ្លួនគេថាជាអ្នកគាំទ្រដែលគេជឿជាក់ថា មានចលនាដែលគេជឿនៅពេលនោះ។ ក្រៅពីការដែលថា ជឿជាក់ទុកចិត្តលើឯកសារដែលធ្វើឡើងដោយសេវាផ្សាយព័ត៌មានបរទេសនោះ អ្វីដែលខ្ញុំព្យាយាមប្រើហ្នឹងដែលខ្ញុំយល់ថាជាអត្ថបទខ្មែរជាភាសាដើម។ ហើយខ្ញុំធ្វើការបកប្រែ ហើយនិងបកប្រែសម្រួលចេញជាភាសាពីខ្មែរទៅជាអង់គ្លេស។

[១១:៣៧:០៣]

**ស៖** ឥឡូវនេះ បន្ទាប់ទៅជាឯកសារយោងនៅក្នុងជើងទំព័រហ្នឹង គឺចម្លើយរបស់ នួន ជា គឺទំព័រ ១៩ ហើយនិង២០ តើលោកអាចពន្យល់អ្វីបន្ថែមបានទេ?

**ឆ៖** ចម្លើយខ្ញុំយល់ច្បាស់ថា មានកំណត់ត្រាអំពីការសិក្សាតូចមួយ ដែលបោះពុម្ពនៅក្នុងការសិក្សាជាកម្រិតខ្ពស់ដោយ ឡូវ៉ា សាំមើរ ផ្អែកតាម--

**ស៖** ខ្ញុំកាត់បន្តិច ខ្ញុំអាចជួយលោកបាន។ ខ្ញុំឃើញនៅក្នុងអេក្រង់ហើយឥឡូវនេះ។ សេចក្ដីប្រកាសរបស់បក្សកុម្មុយនីស្តកម្ពុជាទៅបក្សកុម្មុយនីស្តដេនម៉ាក ក្នុងឆ្នាំ១៩៧៨ ដោយលោក នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារនោះ គឺនៅក្នុងប្រព័ន្ធរបស់យើងគឺ E3/196, និយាយថាសេចក្ដីប្រកាសនេះបានធ្វើឡើងដោយផ្ទាល់មាត់នៅថ្ងៃទី៣០ និង៣១ ខែកក្កដា ឆ្នាំ១៩៧៨។ តើអាចជួយបានបន្ថែមទេនៅលើឯកសារនេះបាទ?

**ឆ៖** ខ្ញុំគិតថា ទោះបីជាការសិក្សាបាន -- ដែលមានឈ្មោះថា អ្នកសិក្សាឈ្មោះ ឡូវ៉ាសាំមើរ នោះគឺបានប្រតិចារឹក បាទ ឡូវ៉ាសាំមើរ នោះប្រតិចារឹកយកមកពីគណៈប្រតិភូដេនម៉ាក បក្សពលករដេនម៉ាកហ្នឹងដែលធ្វើទស្សនកិច្ចនោះឯង។ ហើយនៅលើឯកសារនេះ ការកែប្រែអត្ថបទបកប្រែនោះ គឺថាវាមានបញ្ហា គឺថា នួន -- លោក នួន ជា និយាយភាសាខ្មែរ គេបកប្រែទៅជាភាសាបារាំង ឬទៅជាអង់គ្លេស គឺមិនបកប្រែទៅជាភាសាដេនម៉ាកទេ ហើយមិនដឹងថាកំណត់ហេតុគេកត់ជាភាសាអង់គ្លេស ឬក៏ជាភាសាបារាំងទេកាលនោះ គេអាចកត់ត្រាជាភាសាដេនម៉ាក ហើយក្រោយមកគេមានការបកប្រែជាភាសាដែលបោះពុម្ពផ្សាយហ្នឹងទៅជាភាសាមួយទៀត។ ក្នុងឋានៈជាអ្នកសិក្សាកម្រិតខ្ពស់ ខ្ញុំអាចនិយាយថាមិនគួរឲ្យជឿជាក់ក្នុងកម្រិតខ្ពស់ទេ។ បើអាចគឺថាទាល់តែពីខ្មែរទៅភាសាអង់គ្លេសបានយើងអាចនិយាយបាន។

[១១:៤០:00]

**ស៖** ទំព័រ ជំពូកទី៤ នៅទំព័រ៧៥ អង់គ្លេស ERN 00393738 យើងនិយាយអំពីសន្និបាតឆ្នាំ ១៩៦០ ខ្ញុំសូមដកស្រង់៖ “សន្និបាទគឺទទួលស្គាល់អំពីការតស៊ូពីរ គឺការតស៊ូនយោបាយ និងប្រដាប់អាវុធដែលដាក់បញ្ចូល គឺថាបក្សពលករកម្ពុជាត្រូវតែធ្វើសង្គ្រាមប្រជាជនដើម្បីជម្នះលើឧបសគ្គ។ លះបង់ធ្វើពលិកម្មឲ្យឈ្នះជោគជ័យជាដាច់ខាត”។ ជើងទំព័រ៥១ និយាយអំពីសម្ដីរបស់លោក នួន ជា៖ “ដោយហេតុថាចក្រពត្តិអាមេរិក ហើយនិងបរិវាររបស់គេ ហើយនិងវណ្ណៈជិះជាន់ អ្នកផ្ដាច់ការ ហើយប្រើ

កម្លាំងដើម្បីសម្លាប់និងបំភិតបំភ័យប្រជាជន។ នយោបាយតែឯងមិនជោគជ័យក្នុងការប្តូរខ្នាំងទាំងអស់នេះរបស់បដិវត្តន៍ទេ។ នេះតម្រូវឲ្យមានការប្តូរកងកម្លាំងប្រដាប់អាវុធឲ្យទៅជាកងកម្លាំងបដិវត្តន៍វិញ"។

ជើងទំព័រ៥២ គឺនិយាយអំពីសុន្ទរកថារបស់ នួន ជា គឺថ្ងៃទី១៦ មករា ឆ្នាំ១៩៧៧ ហើយបានផ្សាយនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ដោយវិទ្យុភ្នំពេញ ដែលអបអរសាទរខួបទី៩ នៃការបង្កើតនៃកងកម្លាំងបដិវត្តន៍កម្ពុជា។ តើលោកសាក្សីអាចនឹងជួយបំភ្លឺបន្ថែមបានទេ អំពីប្រភពនេះ?

[១១:៤២:២៤]

**ឆ៖** បាទ នេះគឺជាសេវាប្រចាំថ្ងៃបកប្រែរបស់ព័ត៌មានបរទេស របស់សហរដ្ឋអាមេរិក គឺថានៅពេលនោះអត្ថបទភាសាខ្មែរច្បាស់ដើម គឺបោះពុម្ពជាឯកសារទង់បដិវត្តន៍ ដែលខ្ញុំមិនមានទេ។

**ស៖** នៅក្នុងទំព័រដដែល ហើយនិងដកស្រង់ បក្សពលករកម្ពុជាត្រូវតែរៀបចំជាឲ្យស្រេចដើម្បីប្រើទម្រង់ការតស៊ូ នយោបាយ សេដ្ឋកិច្ច ហើយនិងប្រដាប់អាវុធ។ គឺជើងទំព័រ៥៣ និយាយអំពីប្រវត្តិរបស់ នួន ជា។ គឺថាលោកបាននិយាយរួចហើយ។ ប្រយោគបន្ទាប់ អនុលោកតាមសម្តីរបស់ សាឡុត ស -- សូមដកស្រង់។ "ទម្រង់នៃការតស៊ូនោះត្រូវតែការប្រើប្រាស់ហិង្សាបដិវត្តន៍តាមរយៈនយោបាយ" បិទសេចក្តីដកស្រង់។ ប៉ុន្តែជម្លោះហិង្សាបដិវត្តន៍ប្រដាប់អាវុធនឹងត្រូវធ្វើបន្ទាប់ពីជម្លោះហិង្សាប្រដាប់អាវុធ។ នៅក្នុងជើងទំព័រ៥៤ "ជយោ ប៉ុល ពត!" យើងបាននិយាយគឺថាឯកសារ E3/145។

លោក ហេដឌ័រ នៅជំពូកដដែល ជំពូក៤ ទំព័រ៧៨, អង់គ្លេស ERN 00393741 បាទនិយាយអំពីមហាសន្និបាតឆ្នាំ១៩៦០។ សូមដកស្រង់៖ "សមាជឆ្នាំ១៩៦០ ក៏បានដោះស្រាយក្នុងការបង្កើតនូវគណ:មជ្ឈិមបក្សដែលមានសមាជិកប្រាំបីរូប ហើយនិយាយអំពី ទូ សាមុត ជាលេខា, ហើយនួន ជាអនុលេខា ជាមួយ ស បង្កើតបានជាគណ:អចិន្ត្រៃយ៍នៃគណ:មជ្ឈិមបក្ស។ សមាជិកផ្សេងៗទៀតដែលរាប់បញ្ចូលទាំង អៀង សារី, កែវ មាស មកពីអង្គការក្រុង, កម្មាភិបាលពីរមកពីមូលដ្ឋាន, សោ ភឹម មកពីបូព៌ា"។ នៅជើងទំព័រ៧២ ដែលនិយាយអំពីប្រវត្តិរបស់ នួន ដែលលោកបាននិយាយហើយ។ កែវ មាស តើគាត់ជាអ្នកណា? ហើយគាត់មានជោគវាសនាដូចម្តេចដែរ?

[១១:៤៥:៣២]

**ឆ៖** គាត់ គឺអ្នកដែលគេហៅថា-- ដែល ស្ទីវ ហេដឌ័រ បញ្ជាក់ថាគាត់ជាមនុស្សគេយល់ច្រឡំពីគាត់ ដែលៗអាចប្រើពាក្យច្បាស់ ខ្មែរថា ខេ.អ៊ី.អូ ដែលថា អ៊ឹម.អ៊ី.អេ.អេស – ដែលថា កែវ មាស។ គាត់ជាអតីតអ្នកកុម្មុយនីស្តចុងឆ្នាំ -- ទសវត្សរ៍ឆ្នាំ១៩៤០ ដល់ ១៩៥០ ដែលបន្ទាប់មកបន្ទាប់ពីសន្និសញ្ញា

ក្រុងហ្សឺណែវ ហើយគាត់ចូលក្នុងការតស៊ូ ហើយគាត់នៅក្នុងផ្នែកដែលអ្នកនិយាយច្រើននៅក្នុងបក្សនៅកាលនោះ បន្ទាប់មកគាត់បន្ត -- គាត់ធ្វើការងារជាសម្ងាត់បាទ។ ហើយគេយល់ថាមិនអាចនឹងបន្តបាន ហើយគាត់ធ្វើដំណើរបន្តិចជាមួយ ប៉ុល ពត ប៉ុន្តែដោយសារមានការពេញចិត្តនយោបាយបន្ទាប់ពី -- ប្រហែលជាខែមេសា ១៩៧៥ នោះគឺថា គេបានដាក់គាត់ គំហាត់លំនៅ បានឃាត់ឲ្យនៅក្នុងផ្ទះ ហើយនៅពេលដែលមានសេចក្ដីសម្រេចនៅក្នុងបក្ស គឺជាវិបត្តិដ៏ធំដែលចេញពីមេដឹកនាំជាន់ខ្ពស់ហ្នឹងគឺថា គេបញ្ជូនគាត់ចេញពីឃុំខ្លួនក្នុងផ្ទះ និងទៅស-២១ ដើម្បីឲ្យសួរយកចម្លើយសារភាព។ ក្រោយមកគេក៏សម្លាប់គាត់។

[១១:៤៧:២២]

**ស៖** បន្ទាប់ពីសំណួរដែលខ្ញុំសួរទាំងអស់ទៅលោកនេះ ខ្ញុំច្បាស់ មេធាវីការពារក្ដីត្រូវកែខ្ញុំបើខ្ញុំខុស។ ខ្ញុំមិនសួរសំណួរលោកផ្អែកទៅលើចម្លើយសារភាពទេ។ ប៉ុន្តែនិយាយអំពីទំព័រ៧៧ -- ៧៨ នៅក្នុងសៀវភៅនិយាយពីលទ្ធិកុម្មុយនីស្តកម្ពុជា។ សេចក្ដីដកស្រង់គឺនៅខាងក្រោម៖ "ពាក្យសម្ដីដែលប្រឆាំងនឹងចក្រពត្តិដែលនិយាយឡើងដោយ ហ៊ូ យន់ និង ហ៊ូ នឹម ជាបុព្វហេតុធ្វើឲ្យអ្នកទាំងអស់នោះអាចនឹងប្រមូលកម្លាំងបក្សពលករកម្ពុជា ដែលធ្វើឲ្យគេក្លាយទៅជាជ្រុលនិយម ឲ្យពួកគេរៀបខ្លួនជាស្រេច ដើម្បីគេអនុវត្តសកម្មភាពបដិវត្តន៍ប្រឆាំងនឹងរដ្ឋាភិបាលដែលមិនទម្រង់ឲ្យមាន មិននាំឲ្យមានទម្រង់អ្វីដែលអាចនឹងយល់ស្របបាន។ គឺថាជាពិសេសការលំបាកដែលកើតចេញមកពីអ្នកមានចំណូលទាប ហើយនិងនិស្សិតដែលនៅក្នុងរបបនោះ ហើយនិងគេចោទថាជាមានអំពើពុករលួយ"។ ហើយជើងទំព័រលេខ៧៤ សៀវភៅ ឆេនល័រ គឺឯកសារ E3/168 ដែលនិយាយអំពីសោកនាដកម្មនៃរបបនោះ។ សំណួររបស់ខ្ញុំ គឺសួរមួយផ្នែកនៃប្រយោគមួយអំពី ហ៊ូ យន់, ហ៊ូ នឹម, និង ខៀវ សំផន។ ដែលក្លាយជាបុព្វហេតុនៃប្រមូលផ្ដុំនៃបក្សពលករកម្ពុជានោះ។ តើលោកអាចពន្យល់អ្វីបន្ថែមទេ?

[១១:៤៩:២៤]

**ឆ៖** ដោយមិនបានមើលសៀវភៅច្បាប់ដើមរបស់ ឆេនល័រ ខ្ញុំមិនអាចឆ្លើយបានទេ។

**ស៖** សូមអរគុណ។ ឥឡូវទំព័រ៨៣, អង់គ្លេស ERN 00393746, ប្រធានបទទូទៅ ខៀវ សំផន, ហ៊ូ នឹម, ហើយនិង ហ៊ូ យន់។ សូមដកស្រង់៖ "បក្សពលករកម្ពុជាចាត់ទុកអ្នកទាំងនេះថាជាអ្នកស្នេហាជាតិដែលបក្សនេះផ្សាយឃោសនាការផ្អែកទៅលើរណសិរ្សរួបរួមជាតិ ដើម្បីប្រឆាំងអ្នកនិយមអាមេរិក យុត្តិធម៌សង្គម ហើយសេរីភាពសម្រាប់ពលករ កសិករ ហើយនិងបញ្ញវន្ត"។ កំណត់ជើងទំព័រ

៩៦ យោងទៅរកចម្លើយរបស់ នួន ជា យើងបាននិយាយរួចទៅហើយ។ នួន--

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាផ្អាកបន្តិចសិន។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួនជា លោកវិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដថា តើសហព្រះរាជអាជ្ញាធ្វើអ្វីទេនៅដំណាក់កាលនេះនោះ។ គាត់អានសេចក្តីដកស្រង់ពីសៀវភៅរបស់សាក្សី ហើយសួរគាត់ឲ្យបញ្ជាក់ទៅលើខ្លឹមសារនៃជើងទំព័រ បាទ ហើយគាត់សួរសំណួរអំពីលេខជើងទំព័រ។ យើងយល់ឃើញថា សៀវភៅនេះនៅក្នុងឯកសារសំណុំរឿងយើងបានអាន គោលបំណងនៃការសួរដេញដោលគ្រាន់តែអានសម្រង់ហើយសុំឲ្យគាត់បញ្ជាក់ ហើយសួរសំណួរមួយចំនួនអំពីជើងទំព័រគឺថាអាចនឹងខ្ជះខ្ជាយពេលវេលារបស់តុលាការ។ ការជំទាស់របស់យើងខ្ញុំមិនមែនជាចាំបាច់ថា មានន័យទាំងស្រុងទាំងអស់ទេដែលថាយើងត្រូវបើកសវនាការថ្ងៃនេះ។ ខ្ញុំយល់ហើយថាលោក ហេដឌ័រ គាត់មិនចង់បង្ហាញខ្លួនជាអ្នកជំនាញនោះទេ ប៉ុន្តែយើងអាច -- យើងបានអានសៀវភៅរបស់គាត់ ហើយសៀវភៅនេះនៅក្នុងសំណុំរឿង ប៉ុន្តែបើព្រះរាជអាជ្ញាមិនច្បាស់ពីលេខយោងទំព័រ សួរតែពីរចំណុចនោះទៅបានហើយ។

[១១:៥២:១១]

**លោក ឃីត រេយ៍ន័រ៖**

ជាបឋមគឺថា នេះមិនមែនជាការជំទាស់នោះទេ ប៉ុន្តែខ្ញុំសូមឆ្លើយតបទៅដែរ។

អង្គជំនុំជម្រះបានសម្រេចទៅលើសក្ខីកម្មរបស់លោក ហេដឌ័រ គឺថាគាត់ជាសាក្សីទៅលើអង្គហេតុដែលសៀវភៅ គឺតាមអ៊ីម៉ែលថ្ងៃទី០១ ខែកក្កដា ឆ្នាំនេះ គឺសួរជាបឋមទៅលើភស្តុតាងដែលសាក្សីប្រមូលបទសម្ភាសន៍ ឬក៏ភស្តុតាងដែលគាត់ប្រមូលបានក្នុងការសិក្សាស្រាវជ្រាវដែលបង្កើតបានជាមូលដ្ឋាននៃសៀវភៅនៃអត្ថបទសារព័ត៌មានដែលគាត់និពន្ធ។ នេះហើយជាការងារដែលខ្ញុំធ្វើស្របតាមការណែនាំរបស់អង្គជំនុំជម្រះ។ ខ្ញុំសួរគាត់អំពីសៀវភៅរបស់គាត់ អំពីសេចក្តីដកស្រង់អំពីសៀវភៅនោះ ហើយនិងប្រភពនៃសៀវភៅនោះ។

[១១:៥៣:១២]

ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា អំពីសក្ខីកម្ម អំពីលោក ហ្វីលីព ស្សូត និងលោក ឆេនល័រ គឺនីតិវិធី

ដដែល ដូចគ្នានោះឯងដែលត្រូវបានអនុម័ត មិនមានការជំទាស់ ហើយក៏គ្មានសេចក្ដីសង្កេតអីពីមេធាវីការពារក្ដីដែរ។ ដូច្នេះខ្ញុំសូមអនុញ្ញាតបន្ត។

**ស៖** លោក ហេងឌ័រ ទំព័រ៨៣ ដកស្រង់បន្ត៖ "នួន ជាពិសេសគឺមានការចាប់អារម្មណ៍ដោយស្វាមីភក្ដិរបស់លោក ខៀវ សំផន ទៅនឹងអ្នកទាំងអស់នេះនូវខ្លឹមសារនេះ ហើយគាត់ជាអ្នកមានប្រសិទ្ធភាពក្នុងការប្រមូលកម្លាំងដើម្បីឱ្យគេជ្រើសរើសចូលក្នុងបក្សបាន ដើម្បីធានាថាអ្នកទាំងឡាយដែលនៅក្រៅបក្ស មិនអាចរកថាតើអ្នកណាជាអ្នកដឹកនាំបដិវត្តន៍បានទេ។ ដើម្បីធ្វើឱ្យគេយល់ច្រឡំនោះថា ហ៊ូ យន់ ហើយនិង ហ៊ូ នឹម គឺជាមេដឹកនាំពិត"។ លេខជើងទំព័រ៩៧ គឺជាចម្លើយរបស់ នួន ជា ទំព័រ២១, ហើយសូមបន្តទៅទៀត៖ "អៀង សារី ក៏យកអត្ថប្រយោជន៍ពីលោក ខៀវ សំផន ដើម្បីប្រមូលនូវការគាំទ្រប្រឆាំងនឹងចក្រពត្តិនិយម ហើយនិងបញ្ញវន្តក្រុង ហើយនិងមន្ត្រីរាជការ ហើយនិងគហបតីជាតិ ហើយនិងមន្ត្រីយោធាសង្គមរាស្ត្រនិយម ហើយប្រកាន់ -- ទទួលបានផលពីលោក ខៀវ សំផន តាមរយៈកម្រិតសិក្សារបស់គាត់ខ្ពស់"។ គឺលេខជើងទំព័រ៩៨ លេខ៣៤៧ គឺឯកសារ E3/3708។ សំណួររបស់ខ្ញុំ លោក ហេងឌ័រ គឺថាខ្ញុំសួរបែបនេះ។ នៅពេលដែលយើងនិយាយអំពីការប្រមូលកម្លាំងគាំទ្រដើម្បីប្រឆាំងចក្រពត្តិនោះ គឺឱ្យមានមន្ត្រីរាជការ មានគហបតីជាតិ សង្គម មន្ត្រីយោធារបស់សង្គមហ្នឹងប្រមូលផ្ដុំឱ្យចូលរួមនោះ។ តើសូមឱ្យលោកពន្យល់ថាតើមន្ត្រីយោធាសង្គមរាស្ត្រនិយមហ្នឹងគឺសំដៅលើអ្វី?

**ឆ៖** សង្គមហ្នឹង--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១១:៥៦:០៥]

**លោក អាកឡូវ វ៉ែកគែន៖**

ខ្ញុំសូមជំទាស់ដូចគ្នាទៅនឹងការជំទាស់មេធាវីការពារក្ដីលោក នួន ជា។ យើងមើលឃើញច្បាស់ណាស់ថាការបង្ហាញខ្លួនរបស់លោក ហេងឌ័រ នេះត្រូវបានបង្វែរដោយខាងសហព្រះរាជអាជ្ញា ដើម្បីនាំឱ្យអង្គជំនុំជម្រះ និងភាគីទាំងអស់ពិនិត្យមើលទៅលើសម្រង់នៃសៀវភៅទាំងអស់នោះ យើងបានឃើញនូវសម្រង់យ៉ាងវែងរបស់លោក ហេងឌ័រ ហើយបន្ទាប់មកទៀត គាត់សួរចំណុចលម្អិតដែលមិនមាន

ភាពពាក់ព័ន្ធគ្នាជាមួយនឹងវិសាលភាពនៃសក្ខីកម្មរបស់សាក្សីរូបនេះ ដូចដែលអង្គជំនុំជម្រះបានកំណត់នោះទេ។ ដូច្នេះ ខ្ញុំជំទាស់នេះ ដើម្បីគាំទ្របន្ថែមទៅលើការជំទាស់របស់មេធាវីការពារក្តី នួន ជា ដើម្បីឲ្យសហព្រះរាជអាជ្ញាសួរសាក្សីក្នុងទម្រង់របៀបផ្សេង ដើម្បីឲ្យគោរពទៅតាមវិសាលភាពនៃសក្ខីកម្មរបស់គាត់។

**លោក ឃីត វេយ៍ន័រ៖**

ម្តងទៀត ក៏មិនមែនជាការជំទាស់ដែរ។ អ្វីដែលខ្ញុំធ្វើគឺការដកស្រង់ចេញពីសៀវភៅរបស់លោកសាក្សី ហើយខ្ញុំឲ្យគាត់បំភ្លឺ គឺមិនមែនជាអ្នកជំនាញ មតិអ្នកជំនាញទេ ថាតើគឺជាបញ្ហានៃអង្គហេតុ មិនមែនជាមតិយោបល់ទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៧:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ចំពោះករណីនេះមិនសមស្របទេ។ ដូច្នេះ សេចក្តីជំទាស់នេះមិនមានប្រសិទ្ធភាពទេ។ តំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះតទៅទៀត។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** និយាយពីមន្ត្រីយោធាសង្គម សង្គមរាស្ត្រនិយមនោះ តើលោកអាចពន្យល់អ្វីបាន?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** សាមញ្ញគឺជាពាក្យខ្លីដែលយោងទៅរកហៅថា "សង្គមរាស្ត្រនិយម" ជារបបមួយដែលជារបបនៅក្នុងសម័យដែលដឹកនាំដោយសម្តេច នរោត្តម សីហនុ កាលណោះ។

[១១:៥៨:៥១]

**ស៖** សូមអរគុណ។ ប្រភពអំពីលោក អៀង សារី ដែលថាឯកសាររបស់វៀតណាមនោះ គឺថាជាកាសែត តើលោកអាចបញ្ជាក់បានទេនៅកន្លែងនេះ?

**ឆ៖** មិនប្រាកដទេ មិនមែនជាកាសែតទេ គឺជាទស្សនាវដ្តីតាមកាលវិវត្តន៍ គឺថាជាបោះពុម្ពជាបារាំង និងអង់គ្លេស ដោយរដ្ឋាភិបាល កាលណោះគេហៅថា សាធារណរដ្ឋប្រជាមានិតវៀតណាម។

**ស៖** អ៊ីចឹងយើងចូលទៅដល់ជំពូកទី៦ ទំព័រ១០២ អង់គ្លេស ERN 00--

**ប្រធានអង្គជំនុំ៖**

បាទ តំណាងសហព្រះរាជអាជ្ញា ពេលវេលាដល់សមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ត្រឹមនេះ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសឹមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬកន្លែងណាមួយសមស្របនៅជិតសាលសវនាការនេះ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួម មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយសាមសិនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឃីត វេយ៍នរ័៖**

សូមអរគុណលោកប្រធាន។ លោកប្រធានមកដល់ពេលនេះ នៅថ្ងៃនេះ ខ្ញុំបានពិភាក្សាសៀវ-ភៅនេះប៉ុន្តែយើងមិនបានបង្ហាញនៅលើអេក្រង់ទេ គឺថាអាចនឹងជួយដល់លោកស្រីចៅក្រម និងភាគីទាំងអស់។ បើសិនជាខាងប្រព័ន្ធសោតទស្សន៍អាចបង្ហាញនូវឯកសារទាំងអស់នោះ អាចនឹងប្រើបង្ហាញ

បាន។ ដូច្នេះ ខ្ញុំសូមស្នើតាមរយៈលោកប្រធាន ដើម្បីឲ្យបង្ហាញបែបនោះ។ សូមអរគុណ។

[១៣:៣៤:០៤]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍អាចបង្ហាញឯកសារតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាបានដែរឬទេនៅលើអេក្រង់ទូរទស្សន៍?

**លោក ឃីត រេយ៉ន័រ៖**

យើងមានលេខឯកសាររួចហើយ គឺថាខាងប្រព័ន្ធសោតទស្សន៍គ្រាន់តែប្តូរលេខកូដឯកសារអាចនឹងបង្ហាញបានហើយបាទ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបង្គាប់ផ្នែកខាងសោតទស្សន៍ដាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាក្នុងការពិភាក្សាដេញដោលនេះ។

[១៣:៣៤:៥២]

**លោក ឃីត រេយ៉ន័រ៖**

**ស៖** ដើម្បីជួយដល់ប្រព័ន្ធសោតទស្សន៍គឺឯកសារ E3/22 ទំព័របន្ទាប់ខ្ញុំចូលទៅអង់គ្លេស ERN 00393765។ លោក ហេដឌ័រ ទំព័រ១០២ បាទ។ យើងនៅឆ្នាំ១៩៦០នៅឡើយទេ និយាយពីសន្និបាតនៅខាងក្រោមទំព័រនេះបាននិយាយថា "ដូច្នេះការបះបោលកសិករ ហើយនិងអ្នកជាងក្រុងប្រឆាំងនឹងសង្គមរាស្ត្រនិយមបានកើតឡើងនៅឆ្នាំ១៩៦៦ ហើយកាន់តែធ្ងន់ធ្ងរនៅដើមឆ្នាំ១៩៦៧។ ហេតុការណ៍នេះបង្កលទ្ធភាពឲ្យបក្សកុម្មុយនីស្តពលករ បក្សពលករកម្ពុជារៀបចំនូវការជំទាស់ដោយផ្ទាល់ ឬតាមរយៈលោក ខៀវ សំផន ហើយនិងបញ្ញវន្តដែលផ្សេងទៀតដែលយល់ពីទស្សនៈនេះ ដែលតាមរយៈនោះបក្សផ្សាយឥទ្ធិពលនេះ ហើយនិងរូបភាពនៃបដិវត្តន៍កម្ពុជាដែលដឹកនាំដោយបណ្ឌិត ដែលទទួលការអប់រំពីប្រទេសបារាំង"។

បាទ លេខយោង១៤ គឺថានិយាយអំពីបទខុទ្ទេសនាមរបស់ ប៉ុល ពត គឺបក្ស -- បទពិសោធន៍ទាក់ទងទៅនឹង ខាំ ផាន់ ជាគឺជាអគ្គលេខារបស់បក្សកុម្មុយនីស្តថៃនៅក្នុងការពិភាក្សានៅថ្ងៃ ខែសីហា ឆ្នាំ១៩៧៧ ឯកសារមកពីបណ្ណសារប្រទេសវៀតណាមបកប្រែទៅជាភាសាអង់គ្លេសដោយ ថូម៉ាស បកមកពីអត្ថបទ -- បកប្រែជាវៀតណាមមកពីភាសាខ្មែរ។ ហើយខ្ញុំសួរទៅលោក ហេដឌ័រ ថាតើ

លោកបានទទួលឯកសារទាំងអស់ហ្នឹងដែរឬទេកាលពីមុនមកនោះ?

[១៣:៣៧:១១]

**លោក ស្មីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំទទួលពីលោក គ្រីស្តូហ្វ័រ។ ខ្ញុំសូមនិយាយពីឯកសារជាអាថ៌កំបាំងនេះគឺថា គឺជាបទសម្ភាសន៍ក្នុងពេលសមស្របដែលទាក់ទងទៅនឹងបញ្ហាដែលលើកពីខាងដើមនោះ។

**ស៖** តើអ្នកនោះជាអ្នកណាដែលផ្តល់បទសម្ភាសន៍?

**ឆ៖** នេះជាបទសម្ភាសន៍ជាមួយបុគ្គលម្នាក់ -- តើខ្ញុំអាចថាឈ្មោះបានទេលោកប្រធាន តើខ្ញុំត្រូវធ្វើម៉េច? ខ្ញុំស្គាល់អ្នកនោះជាអ្នកណា ប៉ុន្តែតើថាជាវេទិកាដែលខ្ញុំអាចថាឈ្មោះគាត់ដែរឬអត់បាទ?

**ស៖** តើគាត់នៅរស់ ឬក៏ស្លាប់?

**ឆ៖** តាមពិតគឺមិនទេ។ អ្នកដែលមានឈ្មោះលើឯកសារនេះស្លាប់ហើយ ប៉ុន្តែម្នាក់ទៀតដែលនៅលើឯកសារមួយទៀតគឺយើងមិនបានបញ្ជាក់ ឈ្មោះនោះក៏ស្លាប់ដែរ។ គឺថាៗជននេះ នោះគឺជាបទសម្ភាសន៍នេះឯងដែលយើងមាន។

[១៣:៣៨:៣៨]

**ស៖** សូមឲ្យគាត់សរសេរឈ្មោះ ហើយនិងបញ្ជូនទៅៗក្រឡាបញ្ជី ហើយបន្ទាប់មកហុចមកឲ្យយើងខ្ញុំវិញ។ បាទ សូមការអនុញ្ញាតបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ លោកសាក្សីសរសេរឈ្មោះជូនមកក្រឡាបញ្ជី។ ក្រឡាបញ្ជីចាំទទួលយក! មន្ត្រីរដ្ឋបាលតុលាការទៅទទួលយកនូវបញ្ជីឈ្មោះពីលោកសាក្សី!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

អ្វីដែលខ្ញុំនឹងចង់ជម្រាបនោះ គឺយើងមានអ៊ីម៉ែលភាគីទាំងអស់ដើម្បីឲ្យពួកគាត់មានឈ្មោះនេះ។

**ស៖** ខ្ញុំសូមលោក ហេដឌ័រ តើបុគ្គលនេះមានមុខតំណែងអ្វីគ្រាន់តែព័ត៌មានបន្ថែមបន្តិចទៀតពីបុគ្គលនេះ?

**ឆ៖** នៅក្នុងបទសម្ភាសន៍នោះ គាត់ជាអនុ -- ជាលេខាស្រុកនៅភូមិភាគបូព៌ា។

**ស៖** តើលោកអាចពន្យល់បន្ថែមទៀតបានដែរឬទេ មានអ្វីពាក់ព័ន្ធ? អ៊ីចឹង ខ្ញុំទៅមើលជើងទំព័រលេខ១៤ "តាមមាគ៌ាយុទ្ធសាស្ត្របក្សពលករកម្ពុជាគឺបណ្តាញសម្ងាត់របស់បក្សពលករ គឺធានាឲ្យ

លោក ខៀវ សំផន បានជាប់ឆ្នោតជាលើកទី២ នៅខែកញ្ញា ឆ្នាំ១៩៦៦។ បក្សក៏ជួយ ហ៊ូ នឹម ប៉ុន្តែមិនជួយ ហ៊ូ យន់ ក្នុងយុទ្ធនាការដែលអ្នកទាំងបីនេះ ត្រូវប្រកួតប្រជែងប្រឆាំងគ្នានៅក្នុងបក្ស។ បេក្ខជនសង្គមនិយមដែលគាំទ្រដោយសម្តេច សីហនុ”។

ជើងលេខ១៥ ខ្ញុំសូមអាន៖ “អ៊ិន សុភាព, ខៀវ សំផន” ទំព័រ៧២ ដល់៧៣ បានដកស្រង់លោក ខៀវ សំផន នោះថា “គាត់ពឹងផ្អែកទៅលើទស្សនៈនេះ ហើយ ហ៊ូ នឹម គឺជាយុទ្ធនាការសកម្ម។ មណ្ឌលលោក ខៀវ សំផន គឺនៅខាងភូមិភាគខាងត្បូងនៃខេត្តកណ្តាល នៅភូមិភាគបូព៌ា ហើយជាពិសេសមានផ្នែកទៀតនៅភូមិភាគបូព៌ា នៅខាងខេត្តតាកែវ គឺបណ្តាញសម្ងាត់។ តំបន់ទាំងពីរគាំទ្រយុទ្ធនាការរបស់គាត់”។ ហើយពាក្យទាំងអស់នេះ បទសម្ភាសន៍ជាមួយសមាជិកអតីត -- សមាជិកកុម្មុយនីស្តមកពីព្រែកប្បាស នៅភូមិភាគនិរតី តំបន់លេខ១៣។ តើលោកបានព័ត៌មានអំពីការសម្ភាសជាមួយអតីតសមាជិកបក្សកុម្មុយនីស្ត តើបានសម្ភាសបែបនោះដែរឬទេ?

[១៣:៤២:៣២]

**ឆ៖** អត់ទេ ដោយមិនបានមើលឯកសារទេ ពីព្រោះឯកសារនោះ នៅចក្រភពអង់គ្លេសឯណោះ។

**ស៖** សំណួរបន្ទាប់ ខ្ញុំនឹងចូលដល់ជំពូកថ្មីមួយទៀតនៅ -- បាទគឺឯកសារមួយទៀត គឺ ស៊ី.អូ.អ៊ិន.ស៊ី ដែលនិយាយអំពីសេចក្តីសន្និដ្ឋាន។ តើលោកមានជំពូកនៅនោះ តើទំព័រទី១៥៩ មែនឬទេ? គឺចំណងជើងទំព័រនោះ គឺសេចក្តីសន្និដ្ឋានសង្គ្រាមប្រជាជនបដិវត្តន៍ ហើយនិងប្រជាប្រិយភាព ឆ្នាំ១៩៧០ ដល់១៩៧៥។ ទំព័រទី១ ដែលខ្ញុំចង់សួរលោកអំពីទំព័រនេះ គឺទំព័រ១៦២។ ERN ភាសាអង់គ្លេសនោះចង់ឲ្យ អេ.វី បង្ហាញនោះគឺ 00393825, ដែលនិយាយអំពីរយៈកាលក្រោយរដ្ឋប្រហារក្នុងឆ្នាំ១៩៧០។ ខ្ញុំសូមដកស្រង់៖ “ក្នុងរយៈ១ខែ ក្នុងការរដ្ឋប្រហារ គឺបក្សពលករវៀតណាម គឺកាន់កាប់ដែនដី៦០គីឡូ-ម៉ែត្រក្នុងប្រទេសកម្ពុជា នៅក្នុងតំបន់ដែលរដ្ឋបាល លន់ នល់ បានគាំងទៅហើយនោះ ដែលបង្កើតនៅជាតំបន់រំដោះ ដែលមានប្រជាជន១លាននាក់។ បក្សពលករវៀតណាមយល់ថា ជំហររបស់ សីហនុ ប្រឆាំងនឹងរដ្ឋប្រហារ មានន័យថាបដិវត្តកម្ពុជាធ្វើមហាលោតផ្លោះទៅមុខ ហើយនិងបង្កើត ដើម្បីបង្កើតនូវរដ្ឋាភិបាលបដិវត្ត”។ ជើងទំព័រ២៧ ឯកសារបង្ហាញអំពីវិទ្ធង្សនាកុម្មុយនីស្តវៀតណាមនៅកម្ពុជា។ ឯកសារ គឺនិយាយការប្រជុំមូលដ្ឋាន គឺវរសេនីយ៍ទោ ឈ្មោះ វ៉ាន់។ វ៉ាន់ វ៉ាង – វី-អេ-អិន-ជី។ គឺថាឯកសារ V1701924 ដែលជាឯកសារប្រមូលផ្តុំចងក្រង ដោយស្ថាប័ននេះ។ សូមលោកពន្យល់អំពីប្រភពម្តងទៀតបាទ។

[១៣:៤៥:៣៨]

**ឆ៖** នេះគឺឯកសារច្បាប់ដើមនោះ គឺជាក់ស្តែងគឺបកប្រែមកពីភាសាវៀតណាម។ គឺជាឯកសារបកប្រែជាភាសាអង់គ្លេស។ ខ្ញុំគិតថា ខ្ញុំទទួលបានពីពីរកន្លែង។ មួយនៅក្នុងកម្រងឯកសារដែលផ្តល់មកឲ្យខ្ញុំដោយអ្នកណែនាំសិក្សាកម្រិតខ្ពស់របស់ខ្ញុំនៅសកលវិទ្យាល័យ ខូណែល គឺអតីតសាស្ត្រាចារ្យម្នាក់បានផ្តល់មកឲ្យខ្ញុំ។ មួយទៀតគឺស្ថានទូតអាមេរិកនៅ សៃហ្គន ប្រហែលជានៅក្នុងឆ្នាំ១៩៧០ ឬ៧១។ ប្រភពទីពីរដែលយើងអាចបើកមើកបានស្រួលគឺកម្រង ឯកសារសង្គ្រាមវៀតណាមគឺនៅសកលវិទ្យា-ល័យមួយ ដែលប្រៀបធៀបឯកសារមួយចំនួន ដែលរៀបចងក្រងឡើងដោយ ដូក្លាស ផាយ ដែលជាអ្នកសារព័ត៌មានវៀតណាមនៅសង្គ្រាមវៀតណាមខាងត្បូង ហើយគាត់មានឯកសារជាច្រើន។ នៅពេលដែលគាត់ស្លាប់ទៅគាត់បានប្រគល់ទៅឲ្យកម្រងឯកសារមួយរបស់សកលវិទ្យាល័យ។

**ស៖** ទំព័រ១៦៣ អង់គ្លេស ERNដែលត្រូវបង្ហាញនោះ គឺ 00393826 និយាយអំពីឆ្នាំ១៩៧០។ សេចក្តីប្រកាសរបស់ ខៀវ សំផន មិនបាននិយាយអំពីវៀតណាមដែលប្រកាសថាការតស៊ូរបស់ប្រជាជនកម្ពុជាដើម្បីបង្កើតអំណាចប្រជាជនត្រូវបានរីកទូលាយយ៉ាងខ្លាំងនោះទេដែលថា កងកម្លាំងប្រដាប់អាវុធកម្ពុជា គឺថាវាយប្រហារលើទីរួមខេត្តចំនួន១២ ហើយរំដោះបានបួន, ទីរួមស្រុកជាច្រើនហើយនិងភូមិរាប់រយឯណោះ។ ជើងទំព័រ៣២ “នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧០ គឺក្រសួងការពារជាតិនៃ វី.អិន.អេ ២៩ មិថុនា ១៩៧០”។ អ៊ីចឹង វី.អេន.អេ នេះជាប្រភពតើលោកបានទទួលតាមរបៀបណាដែរ?

[១៣:៤៨:២៣]

**ឆ៖** វី.អេន.អេ គឺថាទីភ្នាក់ងារវៀតណាមនោះ គឺជាទីភ្នាក់ងារព័ត៌មានរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែលប្រមូលផ្តុំ ហើយបានរក្សាទុកនៅសកលវិទ្យាល័យខូណែលផងដែរ។

**ស៖** បន្តពីជើងទំព័រលេខ៣២ “នៅក្នុងខែសីហា ឆ្នាំ១៩៧០ រណសិរ្សរួបរួមជាតិកម្ពុជាបានប្រកាសថា បានបង្ក្រាបទាហាន លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក៨០.០០០ ហើយនិងកងកម្លាំងខ្មាំងសៃហ្គនរំដោះបានទាំងស្រុងនៅខេត្តចំនួនប្រាំ ជើងទំព័រលេខ ៣៣។ ឥឡូវនេះសូមលោកបំភ្លឺបន្តិចអំពីភ្នាក់ងារទីព័ត៌មានចិន។

**ឆ៖** ទីភ្នាក់ងារព័ត៌មានចិននេះគឺថា ជាទីភ្នាក់ងារព័ត៌មានផ្លូវការរបស់ចិន។

**ស៖** សំណួរបន្តទៅប្រយោគមួយទៀត។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០គេបាននិយាយថា គេកាន់កាប់ជិតស្មើរតែបីភាគនៃប្រជាជន៧លានរបស់កម្ពុជា។ អ៊ីចឹងហើយគឺជាអ៊ិន.យូ.អេហ្វ.ខេ គឺទីភ្នាក់ងារ

ចិន ថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៧០ និយាយបែបនេះ “គឺជាការិយាល័យនយោបាយអំពីគណៈមជ្ឈិមបក្សរបស់ប្រទេសចិន”។ តើលោកអាចបំភ្លឺបន្ថែមពីបញ្ហានេះបានទេ?

**ឆ៖** បាទ និយាយជាផ្លូវការ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បើនិយាយដោយច្បាស់ទៅតាមពិតនោះ ជាអង្គការមិនមែនកុម្មុយនីស្តមួយគាំទ្ររាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលដឹកនាំដោយគណៈមជ្ឈិម ហើយនៅលើគណៈមជ្ឈិមនេះ គឺក្រុមអ្នកនយោបាយដែលរៀបចំតាមបន្ទាត់នៃកុម្មុយនីស្ត តែកាលណោះគេមិនទាន់ជាកុម្មុយនីស្តទេ។

[១៣:៥១:២៧]

**ស៖** ទំព័រ១៦៤, អង់គ្លេស ERN 00393827, សូមដកស្រង់សម្ដីក្នុងសៀវភៅ៖ “បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្ដើមនៅក្នុងឆ្នាំ១៩៧១ ដើម្បីទាមទារជាផ្លូវការឲ្យរដ្ឋ -- ឲ្យវៀតណាមរំលាយហើយប្រគល់រចនាសម្ព័ន្ធមកឲ្យកម្ពុជាហ្នឹងមកវិញ ជាពិសេសនៅភូមិភាគបូព៌ា ហើយនិងនិរតី នៅពេលដែលគេមាន -- ទទួលកាន់កាប់ភាគច្រើន គឺជើងទំព័រ៤៥ គឺឯកសារសៀវភៅខ្មៅនិយាយអំពីអំពើរបស់វៀត-ណាមនៅក្នុងកម្ពុជា គឺក្រសួងការបរទេសកម្ពុជា ខែកញ្ញា ឆ្នាំ១៩៧៨ តើលោកអាចពន្យល់បន្ថែមអំពីសៀវភៅខ្មៅនៅក្នុងពេលនោះបានទេ?

**ឆ៖** ក្នុងគំនិតនេះ គឺថាមានការយោងទៅរកការសិក្សាកម្រិតខ្ពស់ទាក់ទងទៅនឹងការបោះពុម្ពផ្សាយនេះ ដែលអត្ថបទជាភាសាអង់គ្លេសនោះ គឺបានចែកផ្សាយនៅសហរដ្ឋអាមេរិក ដោយអង្គការមួយដែលខ្ញុំបានលើកឡើងពីមុននោះ គឺ ជី.ខេ.រ៉ាម។

**ស៖** តើលោកដឹងថាមានការបោះពុម្ពផ្សាយនោះម៉េចទេ?

**ឆ៖** វាហាក់ដូចជាអត្ថបទមកដល់ខ្ញុំនោះ បានបោះពុម្ពនៅប្រទេសកម្ពុជា។

[១៣:៥៣:១៨]

**ស៖** បន្តទៅទៀតអាចនៅខាងក្រោមទំព័រ១៦៥ ខាងក្រោមចូលទៅដល់ទំព័រ១៦៦, ERN ជាភាសាអង់គ្លេស 00393828។ “នៅចុងឆ្នាំ១៩៧២ បក្សកុម្មុយនីស្តកម្ពុជាក៏បានធ្លាក់ចូលទៅក្នុងដៃវៀតណាមដើម្បីវាយប្រហារលើទាហាន លន់ នល់”។ ជើងទំព័រ៥៧ ហើយចុងឆ្នាំ -- ចុងខែសីហា ឆ្នាំ១៩៧៣ អាវុធពិសេស កងអាវុធពិសេសជួយដល់បក្សកុម្មុយកម្ពុជាក្នុងការវាយប្រហារ”។ ជើងទំព័រលេខ៥៨ សូមលោកជួយបំភ្លឺ?

**ឆ៖** បាទ នេះជាការបោះពុម្ពនៅអត្ថបទកម្រិតសិក្សា -- សិក្សាកម្រិតខ្ពស់។

**សៈ** ហើយនៅទំព័រដដែលនោះដែរ នៅចុងខែសីហា ឆ្នាំ១៩៧៣ គឺកងកម្លាំងអាវុធពិសេស បានជួយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការវាយប្រហារ ជើងទំព័រ៥៨ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក្នុង រវាងឆ្នាំ១៩៧២ ដល់ ១៩៧៣ កុម្មុយនីស្តកម្ពុជាបន្តគោលបំណងរបស់ខ្លួនឲ្យកងទ័ពវៀតណាមជម្លៀស ចេញពីតំបន់រំដោះរបស់ខ្លួន។ នៅក្នុងកន្លែងខ្លះ គឺគេរៀបចំចរចាឲ្យពួកគេចាកចេញ ប៉ុន្តែការចរចានោះ ខកខាន គេបានរៀបចំប្រជាជនឲ្យធ្វើបាតុកម្មប្រឆាំងពួកគេ ឬក៏ធ្វើការវាយប្រហារយោធាប្រឆាំងនឹង ពួកគេ។ នៅចុងឆ្នាំ១៩៧៣ ពួកគេបានចាកចេញពីភាគច្រើននៃតំបន់ដែលបក្សកុម្មុយនីស្តកម្ពុជាបាន ត្រួតត្រា។ ជើងទំព័រលេខ៥៩ ,ម៉ាស៊ុស៊ីតា, លេខ១៥, ១៨, ២៣ ហើយនិង៣០ ដែលរៀបរាប់អំពី ហេតុការណ៍នៅក្នុងបូព៌ា ហើយនិងនៅនិរតី ហើយនិងភូមិភាគពិសេស។ យើងនឹងនិយាយអំពីបទ សម្ភាសន៍ជនភៀសខ្លួនដែលលោកបាននិយាយខ្លះហើយជាមួយ ម៉ាស៊ុស៊ីតា នោះ?

**ឆៈ** បាទ គឺដកស្រង់មកពីឯកសារមួយចំនួន ប្រហែលជាក្នុងខែកុម្ភៈ ខែមីនា ក្នុងឆ្នាំ១៩៨០ ពី អត្ថបទសារព័ត៌មានក្បូតូនោះឯង។

[១៣:៥៦:៣១]

**សៈ** ដែលលោកថា កងទ័ពវៀតណាមដកចេញពីកម្ពុជាក្នុងឆ្នាំ១៩៧៣ ក្រៅពីបទសម្ភាសន៍ឆ្នាំ ១៩៨៣ របស់ ម៉ាស៊ុស៊ីតា នោះតើលោកបានឃើញ បានពិចារណា មើលបទសម្ភាសន៍ណាផ្សេងទៀត ដែលគាំទ្រអង្គហេតុនៃការដកកងទ័ពវៀតណាមនៅពេលនោះដែរឬទេ នៅក្នុងកាលៈទេសៈស្រដៀងគ្នា បែបនេះនោះ?

**ឆៈ** បាទ ជាចម្លើយខ្លី។

**សៈ** សូមឲ្យពន្យល់បំភ្លឺ ប៉ុន្តែឲ្យខ្លី?

**ឆៈ** មានបទសម្ភាសន៍ផ្សេងទៀតដែលខ្ញុំបានធ្វើនៅក្នុងអំឡុងពេលឆ្នាំ១៩៧៨ និងឆ្នាំ១៩៨៤។ ខ្ញុំប្រាកដថាមានបទសម្ភាសន៍បន្ថែមទៀតនៅក្នុងសម័យកាលហ្នឹង គឺក្នុងអំឡុងពេលហ្នឹង ដែលនិយាយ អំពីបញ្ហានេះ។ ប៉ុន្តែខ្ញុំមិនគិតឃើញថា ឯកសារទាំងអស់នោះបានដាក់នៅក្នុងឯកសារនោះទេតាមដែល ខ្ញុំដឹង។ ជាពិសេសទៅទៀត ប្រភពដ៏គួរឲ្យជឿជាក់បានដ៏ច្រើន បាទដែលមានឯកសារច្រើនដែលមាន អត្ថបទ មេម៉័រ មានប្លុក មានអ្វីទៀតហ្នឹង ដែលជាឯកសារបានបោះពុម្ពផ្សព្វផ្សាយដែលបានចែកផ្សាយ ដែលឯកសារទាំងនោះសរសេរដោយជាអតីតកងទ័ពវៀតណាមដែលបានបម្រើការ -- ដែលមកកម្ពុជា នៅក្នុងសម័យនោះ ហើយគេបាននិយាយនៅក្នុងមេម៉័រ ឯកសារជំនួយស្មារតីទាំងអស់នោះ ហើយពី

ហេតុការណ៍ផ្សេងៗជាដើមនោះឯង។

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកផ្តោតអារម្មណ៍ទៅលើការសម្ភាសដែលលោកបានធ្វើ។ សំណួរទី១ តើលោកចាំដែរឬទេប្រភពដែលមកពីមនុស្ស ឬក៏សំណួរនោះសាមញ្ញពេកដែលលោកបានសម្ភាសអ្នកដែលផ្តល់ព័ត៌មានអំពីបញ្ហានេះ ពីប្រធានបទនេះនោះ?

[១៣:៥៩:៣៣]

**ឆ៖** បាទ ជាចម្លើយខ្លី។ ជាការពន្យល់បន្ថែមខ្លីនោះ មានបទសម្ភាសន៍គិតទៅលើបរិមាណពីឆ្នាំ១៩៨០ ដល់១៩៨១ តាមដែលខ្ញុំចាំនោះ ដែលនាំឲ្យយើងឈានទៅដល់ស្ថិតិ ដូចជាទិន្នន័យ ដែលជាផ្នែកមួយនៃមូលដ្ឋាននៃការប៉ាន់ប្រមាណអំពីចំនួនមនុស្សដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ដែលប្រើដោយ ប៉ែន ឃៀរនិន, ដោយ ភេទ្រិក ហ៊ើរវឺឡាញ ជាដើមហ្នឹង។ តាមដែលខ្ញុំចាំត្រឹមត្រូវប្រហែលជាបទសម្ភាសន៍១៥០០ គឺថាអាចនឹងមានប្រវត្តិរូបប្រហែលជាមួយចំនួនបន្ថែមទៀត ដែលយើង -- ពេលខ្លះខ្ញុំគិតខ្លួនឯងថា បុគ្គលទាំងនោះអាចនឹងមានការចាប់អារម្មណ៍ឲ្យយើងពិភាក្សាលម្អិតជាងទៀត។ តាមធម្មតាអ្វីដែលមានអត្ថន័យនោះគឺថានឹងមានការចង្អុលបង្ហាញ ដែលខ្ញុំឃើញថាបុគ្គលនោះអាចជាកម្មាភិបាលដែលមានអំណាចកាលនោះ ដែលមានការយល់ដឹងផ្ទៃក្នុងស៊ីជម្រៅនៅថ្នាក់ខ្ពស់គ្រាន់បើនូវពីអ្វីដែលបានកើតឡើងនោះ។

[១៤:០១:១៩]

**ស៖** ប្រសិនបើខ្ញុំសូមឲ្យលោកមើលអ៊ីនធឺណេត ធ្វើការស្រាវជ្រាវនោះ តើមានលទ្ធភាពណាមួយ ហើយខ្ញុំអាចវិលត្រឡប់សួរអំពីព្រឹត្តិការណ៍ឆ្នាំ១៩៧០ ដែលវៀតណាមដកចេញដែរឬទេ? ហើយលោកអាចបញ្ជាក់អំពីកិច្ចសម្ភាសន៍នេះដែលលោកបានធ្វើឡើងនោះដែរឬទេ? ខ្ញុំឃើញថាលោកងក់ក្បាល។ ដូច្នេះបានលោកអាចធ្វើទៅបាន។

នៅពេលនេះ ខ្ញុំសូមចូលទៅដល់ទំព័រ១៦៧, ERN ជាភាសាអង់គ្លេសគឺ 00393830។ ចំណុចនៅពាក់កណ្តាលទំព័រនេះ ខ្ញុំសូមលើកឡើងដកស្រង់៖ "នៅក្នុងប្រទេសកម្ពុជា បក្សកុម្មុយនីស្តកម្ពុជារក្សាទុករដ្ឋមន្ត្រីឃោសនាការនៃរដ្ឋាភិបាលរួបរួមជាតិ ហ៊ូ នឹម និងរដ្ឋាភិបាល -- និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហ៊ូ យន់ នៅក្រោមការឃុំខ្លួននៅផ្ទះ ដោយនៅពេលនោះប្រើប្រាស់ឈ្មោះពួកគេក្នុងការឃោសនាថាពួកគេនេះជាអ្នកសរសេរដោយខ្លួនឯង។ ហើយវាជាការបង្ហាញថា អ្នកទាំងពីរនោះគឺជាមេដឹកនាំបដិវត្តន៍។ ក្រៅផ្លូវការទៅ ហ៊ូ យន់ បានរិះគន់ជាចំហលើបក្សកុម្មុយនីស្តកម្ពុជា ថ្នាក់ដឹកនាំ

របស់បក្ស និងគោលនយោបាយរបស់បក្ស។ ហ៊ូ នឹម ឯកភាពជាមួយនឹង ហ៊ូ យន់ ក៏ប៉ុន្តែគឺគាត់មានលក្ខណ:សម្ផតិកម្មជាង”។

[១៤:០៣:០០]

លេខយោងទំព័រ ជើងទំព័រ៦៩ កិច្ចសម្ភាសន៍របស់ ហ្វុង និងកិច្ចសម្ភាសន៍ ស្ទីវ ជាមួយនឹង ពុង សែ ភ្នំពេញ ខែកក្កដា ឆ្នាំ១៩៧៩។ ដើម្បីបញ្ជាក់ប្រភពនេះឡើងវិញ ហើយនិងកិច្ចសម្ភាសន៍ជាមួយនឹង ពុង សែ ហើយនិងការរៀបរាប់តួនាទីរបស់គាត់ ហើយគាត់ហ្នឹងត្រូវយ៉ាងម៉េចទៅនឹងរូបភាពដែលលោកបានរៀបរាប់នៅក្នុងនេះ?

**ឆ៖** ពុង សែ គឺជាអ្នកជំនាន់ទី១នៃជនកុម្មុយនីស្ត គឺនៅជាមួយនឹងក្រុម ប៉ុល ពត និង អៀង សារី គឺក្រុមតែមួយទេ ក្រុមជំនាន់ទី១។ ខ្ញុំនៅចាំថាគាត់គឺជាទាហានដែលបានអប់រំនៅបារាំង ហើយគាត់ត្រឡប់មកវិញចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងប្រទេសកម្ពុជា។ ទំនងជាមុន ឬក៏ក្រោយអនុសញ្ញាកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ៥៤ បន្តិច។ ហើយគឺគាត់ស្ថិតនៅក្នុងជួររបស់បក្សសម្ងាត់ នៅដំណាក់កាលក្រោយមកទៀតរហូតមកដល់ចុងឆ្នាំ ទសវត្សរ៍ឆ្នាំ១៩៥០ បន្ទាប់មកគឺគាត់ចេញ គឺគាត់ផុតលែងក្លាយជា -- ផុតអាណត្តិជាសមាជិក ហើយគាត់ក្លាយជាអ្នកនយោបាយ។ ក្រោយពីការផ្លាស់ប្តូររដ្ឋាភិបាលឆ្នាំ៧០ គាត់ចូលព្រៃម៉ាគីដែរ។ ហើយគាត់ស្ថិតនៅក្នុងទីតាំងដែលជាទីតាំងមូលដ្ឋានចម្បងរបស់ម៉ាគីនៅទីនោះ ហើយគាត់បានជួបជាមួយនឹងមិត្តចាស់ៗរបស់គាត់ និងកម្មាភិបាលចាស់ដែលធ្លាប់ធ្វើការជាមួយ។ ក្រោយឆ្នាំ៧៥ គាត់ធ្វើការនៅក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់ក៏បានចំណាយពេលធ្វើការនៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រោយឆ្នាំ៧៩ ហើយគាត់ធ្លាប់ធ្វើការងារនៅក្នុងឧត្តមស្នងការសិទ្ធិមនុស្សផងដែរ។

[១៤:០៥:៤០]

**ស៖** ខ្ញុំដឹងថា ខ្ញុំសួរលោកទៅ លោកបានឆ្លើយច្រើនទៅលើចំណុចហ្នឹង។ ខ្ញុំសូមចូលទៅដល់ចំណុចនៃចំណុចនេះ។ ហ៊ូ យន់ គឺរិះគន់ជាចំហទៅដល់បក្សកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំ និងគោលនយោបាយរបស់បក្ស។ តើជាប្រភពចេញមក ពុង សែ ឬក៏លោកផ្អែកលើប្រភពផ្សេងទៀតដែលលោកបានយកមកធ្វើជាមូលដ្ឋាននៅក្នុងអង្គហេតុ ហេតុការណ៍នេះ ដែលថា ហ៊ូ យន់ នេះរិះគន់ជាចំហទៅដល់បក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** បាទគឺខ្ញុំដូចជាអត់ចាំទេ។ ខ្ញុំអាចនិយាយបានថា វាក្នុងចំណោមនោះហើយ ដែលគេនិយាយ

ជាទូទៅ គេអះអាងដូច្នេះជាទូទៅ។ ក៏ប៉ុន្តែបើស្វែងរកថាអ្នកណាគេជាអ្នកស្តាប់ឮប្រភពព័ត៌មានហ្នឹង គឺខ្ញុំគិតមិនឃើញនោះទេ ហើយខ្ញុំនឹកមិនឃើញទេភ្លាមៗនេះ។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត ទំព័រដដែល ក្រោយលេខយោងជើងទំព័រ៦៩ "សូម្បីឧបនាយករដ្ឋមន្ត្រី ខៀវ សំផន នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺជាបុរសមួយចម្លែក។ គឺគាត់ត្រូវបានគេតែងតាំងដំឡើងទៅជាសមាជិកគណៈមជ្ឈិម"។

លេខយោងជើងទំព័រទី៧០ ដែលនៅក្នុងនេះយោងទៅលើលិខិតចំហទៅដល់ជនស្នេហាជាតិ ថ្ងៃ១៦ ខែសីហា ឆ្នាំ២០០១។ ហើយនៅក្នុងហ្នឹង គឺក៏មានយោងទៅលើកិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌ័រ ផងដែរ។ ពាក់ព័ន្ធទៅនឹងអំឡុងឆ្នាំដែលលោកធ្វើការស្រាវជ្រាវ ឬក៏លោកធ្វើកិច្ចសម្ភាសន៍ឯកសារទាំងឡាយនោះ តើលោកអាចជម្រាប តើលោកយល់យ៉ាងម៉េចដែរ ឆ្នាំណាដែរ ដែលលោក ខៀវ សំផន ត្រូវបានគេដំឡើងតំណែងចូលទៅធ្វើជាសមាជិកនៅក្នុងគណៈមជ្ឈិមនោះ?

[១៤:០៨:០៤]

**ឆ៖** គឺពាក្យថា តើជាសមាជិកពេញសិទ្ធិ ឬក៏បម្រុង។ ខ្ញុំចាំទៅ គឺនៅក្នុងឆ្នាំ៧១ ក្លាយទៅជាសមាជិកបម្រុង។

**ស៖** ពាក់ព័ន្ធទៅនឹងចំណុចដកស្រង់ដដែលនោះ មុខតំណែងជា -- ហើយក្រោយមកគាត់ក៏ធ្វើការងារជាលេខាផ្ទាល់ នួន ជា។ ទោះបីជាគាត់នោះ មិនមានអំណាចឯករាជ្យក្នុងការធ្វើសេចក្តីសម្រេចក៏ដោយ។ លេខយោង៧១ លើកឡើងថា "យោងទៅលើកិច្ចសម្ភាសន៍របស់លោក ជួន ប្រសិទ្ធិ ឆ្នាំ៧៧ ថ្ងៃ០៨ ខែកញ្ញា"។ ចំណុចទី១ ដែលសួរអំពីកិច្ចសម្ភាសន៍ដែលលោកសម្ភាសជាមួយនឹង ជួន ប្រសិទ្ធិ។

**ឆ៖** បាទ ខ្ញុំពិតជាយោងទៅលើកិច្ចសម្ភាសន៍នោះមែន។

**ស៖** នៅពេលនេះ ខ្ញុំចាប់អារម្មណ៍លើឃ្លាមួយឃ្លាដែលថា មុខតំណែងធ្វើការងារជាលេខផ្ទាល់របស់ នួន ជា។ តើលោកលើកឡើងបន្តិចមើល ឃ្លាហ្នឹងគឺជាពាក្យសម្តីរបស់ ជួន ប្រសិទ្ធិ ជាអ្នកនិយាយផ្ទាល់ ឬក៏លោកមិនចាំទេ ដោយសារតែហេតុការណ៍ហ្នឹងលោកសម្ភាសយូរមកហើយ?

**ឆ៖** នៅពេលដែលខ្ញុំមិនទាន់បានមើលកំណត់ហេតុរបស់ខ្ញុំនោះ ខ្ញុំមិនប្រាកដទេ ថាតើខ្ញុំសរសេរតាមពាក្យរបស់គាត់នោះ យកប៉ុន្មានភាគរយ។ គឺថាខ្ញុំមិនស្បថថាពាក្យហ្នឹងគឺជាពាក្យរបស់គាត់ផ្ទាល់តែម្តងនោះទេ។

[១៤:១០:០០]

**ស៖** ត្រង់ទំព័រដដែល ទំព័រ១៦៧ ខ្ញុំសូមដកស្រង់៖ "ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាភាគច្រើនបដិសេធជាហូរហែក៏ដោយជ័យជំនះរបស់បក្សនេះ គឺដោយសារតែមានការជួយជ្រោមជ្រែងរបស់វៀតណាមនៅក្នុងឆ្នាំ៧០ ដល់ ៧២។ កិច្ចអន្តរាគមន៍កងទ័ពវៀតណាម និងអង្គការឃោធានឃោបាយ និងការបណ្ដុះបណ្ដាលរបស់វៀតណាមនេះ គឺបានប្រើប្រាស់ផ្ដល់ជារបាំងឲ្យបក្សកុម្មុយនីស្តកម្ពុជាបង្កើតនូវកម្លាំងរបស់ខ្លួន។ ដូច្នេះហើយកម្មាភិបាលភាគច្រើន និងកងកម្លាំងភាគច្រើនបានក្លាយចូលរួមជាមួយកងកម្លាំងនេះនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានក្ដោបក្ដាប់"។

លេខយោងជើងទំព័រ៧២, ខានី, "ជ័យជម្នះដែលមិនរំពឹងទុក" នេះគឺជាប្រភពដែលដកស្រង់មកចេញពីឯកសារសិក្សាស្រាវជ្រាវ។ សូមឲ្យលោកជួយពន្យល់ទៅលើចំណុចនេះ។

[១៤:១១:១៣]

**ឆ៖** វាជាឯកសារបោះពុម្ពផ្សាយតាមរយៈការសិក្សាស្រាវជ្រាវដោយរដ្ឋាភិបាលអាមេរិក ក្រសួងការបរទេសអាមេរិក ពាក់ព័ន្ធទៅនឹងមន្ត្រីនៅក្នុងប្រទេសកម្ពុជាឆ្នាំ៧១ ដល់ ៧៥ ហើយគឺអ្នកដែលគាត់បានរៀបចំឡើងនៅក្រៅប្រទេសក្រោយឆ្នាំ៧៥។

ទំព័រ១៦៨, ERN ជាភាសាអង់គ្លេសសូមមើលទៅលើអេក្រង់គឺមានលេខ 00393831 "នៅចុងឆ្នាំ១៩៧០ ដើមឆ្នាំ១៩៧១ បក្សពលករវៀតណាមក្នុងខណៈដែលមានឧត្ដមានុភាពនោះ ហើយនិងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងខណៈពេលដែលបក្សនេះកាន់កាប់ -- បានបង្កើនពឹងផ្អែកទៅលើការដាក់សម្ពាធលើកម្លាំងយោធាដើម្បីរក្សានិងពង្រីកការគ្រប់គ្រងរបស់ពួកគេ។ ក្នុងខណៈយោធាវៀតណាមប្រតិបត្តិការនៅក្នុងកងកម្លាំងមួយធំធេង គឺយោធាបានបិទតំបន់ភូមិភាគរំដោះនេះពីតំបន់ផ្សេងៗនៅក្នុងប្រទេស។

លេខយោងជើងទំព័រ៧៥ គឺរបស់ ដេវីដ ប្រោន លើកឡើងក្នុងឆ្នាំ១៩៧១ តើលោកអាចលើកឡើងបញ្ជាក់អំពីប្រភពនៃឯកសារនេះបានដែរឬទេ?

[១៤:១២:៥៨]

**ឆ៖** ខ្ញុំជឿថាឯកសារមួយច្បាប់ចាប់តាំងពីវៀតណាមបានប្រមូលនោះ គឺជាសំណុំឯកសារដែលវាបានប្រមូលឡើងក្នុងលក្ខណៈហ្នឹងឯង។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តទៅលើប្រយោគដែលបានសរសេរនៅក្នុងនេះ ជាពិសេសអំពីបញ្ហាយោធាវៀតណាម "អនុវត្តការដាក់ហាមឃាត់ទៅលើការដើរហើររបស់ប្រជាជនរវាងតំបន់រំដោះលេខយោង" ជើងទំព័រលេខ ៧៦។ សេចក្ដីសម្រេចខែកក្កដា ដែលធ្វើឡើងដោយ ស៊ី.អិល.ធូ និងស្ដីការ

សិក្សាក្នុងខែកក្កដា ឆ្នាំ១៩-- ទសវត្សរ៍ឆ្នាំ៧០ ដែលជាប្រភេទប្រមូលឯកសារតាមរយៈបណ្ដុំសំណុំឯកសារអម្បាញ់មិញនេះ។ ប្រជាជនជាច្រើនជាប់នៅក្នុងតំបន់រំដោះនោះ ហើយគេមិនដឹងថាតើតំបន់នោះវៀតណាម ជាអ្នកគ្រប់គ្រងឬក៏វៀតណាម ឬក៏កម្ពុជាជាអ្នកគ្រប់គ្រង។

លេខយោង ៧៧ របស់ ដេវីដ ប្រោន។ ចំណុចទីពីរ “អ្នកដែលជាជនកម្ពុជាត្រូវបានចាប់ខ្លួន។ កាសែតញូវយ៉កថាមស៍ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧២”។ តើលោកបានមើលឃើញនៅក្នុងឯកសារកាសែតញូវយ៉កថាមស៍ ហើយលោកយកមកធ្វើជាចំណុចយោងឬក៏យ៉ាងម៉េច?

**ឆ៖** ជាការពិតដូច្នោះមែន។

[១៤:១៥:០០]

**ស៖** “ពួកគេរត់គេចនៅពេលដែលពួកគេអាចធ្វើទៅបាន”, លេខយោង ៧៧ គឺឯកសារដដែលដូចដែលយើងខ្ញុំបានលើកឡើងដកស្រង់ចេញពីកាសែត ញូវយ៉កថែមស៍ -- សូមអធ្យាស្រ័យ កាសែតឡូសអាន់ជឺលេសថែមស៍ ថ្ងៃទី០៣ ឆ្នាំ៧៩ ខែមករា ហើយនិង អ្នកម៉ុងតាញ៉ា ឆ្នាំ១៩៧១។ តើនេះជាចំណុចយោងត្រឹមត្រូវដែរឬទេនៅក្នុងលេខយោងជើងទំព័រដែលលោកបានបញ្ជាក់នេះ?

**ឆ៖** ខ្ញុំសន្មតថា វាត្រឹមត្រូវ។ ឯកសារសម្ភារៈទាំងអស់នេះត្រូវបានប្រមូលដោយអ្នកដែលនៅក្នុងបណ្ណាល័យខូណែល នៅក្នុងសាកលវិទ្យាល័យនោះឯង។

**ស៖** និយាយអំពីប្រជាជនរត់គេចខ្លួន ខ្ញុំសូមបន្តអានចំណុចដកស្រង់នេះតទៅទៀត “ពួកគាត់បានរត់ចេកចេញពីបដិវត្តន៍ដែលទទួលការគាំទ្រពីប្រជាជនតិចតួច ជាងបដិវត្តន៍នៅក្នុងប្រទេសវៀត-ណាមខាងត្បូង” លេខយោង៧៩។ ចំណុចយោង “ហេតុអ្វីបានជាប្រទេសកម្ពុជាមិនទាន់បែក នៅកាសែតរបស់គ្រីស្ទៀន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ៧០”។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចម្លើយដែលនោះទេ គឺត្រឹមត្រូវ ហើយទំនងសន្មតថាចេញមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យខូណែល។

[១៤:១៦:៤២]

**ស៖** ចូលទៅដល់ទំព័រ១៦៩, ERN ជាភាសាអង់គ្លេស 00393832, សូមដកស្រង់៖ “នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាកាន់តែមានស្វ័យភាពលើបក្សពលករវៀតណាម ឆ្នាំ៧១-៧២ ប្រជាជនភាគីច្រើននៅតែមានការភ័យខ្លាច និងមិនជឿជាក់ទៅលើបដិវត្តន៍ដែលនៅតែរក្សាជំហររបស់ខ្លួនតាមរយៈការគំរាមកំហែង និងការកាប់សម្លាប់”។

លេខយោង៨៣ យោងទៅរកភ្នាក់ងារស៊ើបការណ៍អាមេរិក របាយការណ៍របស់ភ្នាក់ងារស៊ើបការណ៍អាមេរិក "ការអប់រំខ្មែរកុម្មុយនីស្ត និងសកម្មភាពបំពាក់ប៉ននៅស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ខ្មែរ -- ការឃុំខ្លួនខ្មែរកុម្មុយនីស្ត -- ជំរំឃុំខ្លួនខ្មែរកុម្មុយនីស្តនៅរលួស ខេត្តសៀមរាប។ ចំពោះអ្នកដែលជនជាតិ -- ដែលជាជនស៊ីវិល នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៧២"។ តើលោកបានទទួលឯកសារទាំងអស់នេះដោយរបៀបណា?

[១៤:១៨:៣១]

**ឆ៖** មិននិយាយអាក្រក់ចំពោះអ្នកដែល -- មិនជាការដាក់បណ្តាសាចំពោះអ្នកដែលស្លាប់នោះទេ គឺខ្ញុំទទួលចេញមកពីក្រុមបណ្តុំឯកសារដែលវាជាប្រភេទដែលគេលាតត្រដាងជាសាធារណៈ ហើយគេកាត់ខាងលើ កាត់ខាងក្រោម ដើម្បីយកមកផ្តុំគ្នាយើងមើលបាន។ ឯកសារទាំងអស់ គឺជាឯកសារអត្ថបទដែលប្រមូលមកចេញពីពេលដែលក្រោយពីសង្គ្រាមវៀតណាម។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត។ "នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានបណ្តេញកងកម្លាំងវៀតណាមចេញនៅក្នុងឆ្នាំ១៩៧២-៧៣ បក្សកុម្មុយនីស្តកម្ពុជាបានជំនួសការក្តោបក្តាប់យោធារបស់ខ្លួនដោយកាន់តែបង្កើននូវការបង្ខិតបង្ខំខ្លាំងឡើង ដើម្បីកសិករគោរពទៅតាមការចង់បានរបស់ខ្លួន។ បក្សកុម្មុយនីស្តកម្ពុជាកាន់តែមានភាពហិង្សា និងកាន់តែគាបសង្កត់ឡើងក្រោយពាក់កណ្តាលឆ្នាំ១៩៧៣"។ ខ្ញុំសូមអានតទៅមុខ "នៅពេលដែលបក្សនេះបានធ្វើការកែប្រែគោលនយោបាយរបស់ខ្លួន ដោយចង់ឲ្យមានការបង្កើតសហករណ៍កសិកម្មនៅតាមភូមិភាគដែលខ្លួនគ្រប់គ្រង ហើយបានកាត់បន្ថយការអនុវត្តការគោរពសាសនា ហើយបានដាក់ការហាមឃាត់កាន់តែតឹងរ៉ឹងឡើងមិនឲ្យអ្នកភូមិដើរហើរ ហើយប្រមូលប្រជាជនដើម្បីធ្វើការវាយប្រហារក្រុងភ្នំពេញ។

[១៤:២០:២៥]

លេខយោង៨៤ និយាយអំពី "ការបង្ខិតបង្ខំ"។ យោងទៅរក ដូណាល ឃើគ។ អំពើហិង្សាបដិវត្តន៍និងនយោបាយនៅក្នុងប្រទេសកម្ពុជាឆ្នាំ៧៤-៧៥ -- ឆ្នាំ៧០, ៧៤។ ឯកសារ ម៉ាកឃើណឺលប្រោន *(តាមសូរស័ព្ទ)* ទាក់ទងទៅនឹងទស្សនវិស័យថ្មី។ ខ្ញុំសូមសួរ តើនរណាគេជា ដូណាល ឃើគ?

**ឆ៖** ដូណាល ឃើគ គឺជាអ្នកឆ្លើយឆ្លង ធ្វើការនៅឥណ្ឌូចិន ក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកទី២ គឺនៅក្នុងរហូតដល់ចុងឆ្នាំ៧៥។ នៅពេលនេះគឺថាគាត់ជាអ្នកឆ្លើយឆ្លងនៅប្រទេសកូរ៉េ។

**ស៖** ចំណុចដកស្រង់នៅក្នុងទំព័រដដែល ខ្ញុំសូមអានបន្តៈ "បក្សកុម្មុយនីស្តកម្ពុជាមិនដែលឲ្យ

ប្រជាជនភាគច្រើនជឿជាក់ថាបដិវត្តន៍នេះ គឺនឹងបោះជំហានទៅមុខ ដើម្បីផលប្រយោជន៍របស់ពួកគេនោះទេ។ ការបង្ខិតបង្ខំ ការគំរាមកំហែង គឺជាសញ្ញានៃការគាំទ្ររបស់មហាជន ហើយនិងគឺជាការជោគជ័យរបស់មហាជននៅលើបដិវត្តន៍ប្រជាធិបតេយ្យជាតិ”។

លេខយោង៨៦ “*វីវើល្វសិន* – បដិវត្តន៍” ឯកសារដែលពាក់ព័ន្ធទៅនឹងបញ្ហាបដិវត្តន៍។ សូមឲ្យលោកបញ្ជាក់លើឯកសារនេះ។

**ឆ៖** គឺ ខេត ហ្វ្រីអេសិន ដែលគាត់សិក្សាក្រោយអនុបណ្ឌិតនេះ ហើយគាត់ក៏មានឯកសារបោះពុម្ពផ្សាយមួយក្នុងពេលដែលគាត់សិក្សាថ្នាក់ក្រោយអនុបណ្ឌិត។

**ស៖** សូមសួរបន្តទៀត។ ទំនងខ្ញុំនៅចន្លោះប្រហោង មិនទាន់សួរអំពីលេខយោង៨៥ ដែលពាក់-ព័ន្ធនឹងការប្រមូលកម្លាំងប្រជាជនវាយប្រហារភ្នំពេញ។ ប្រភពដែលលោកសរសេរគឺ “កេណ្ណេត អឹម ឃ្វីន “ការផ្លាស់ប្តូរនយោបាយក្នុងពេលសង្គ្រាម។ បដិវត្តន៍ខ្មែរក្រហមនៅក្នុងនិរតី ភូមិភាគនិរតីឆ្នាំ១៩៧៩ ក្នុងខែ *ស្ត្រីង* ឆ្នាំ១៩៧៦”, ឯកសារ យៀរនិន “តើប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា?” ហ្វ្រីអេសិន “បដិវត្តន៍ និងការឆ្លើយតបទៅនឹងបដិវត្តន៍”។ លោកបានពន្យល់ ហ្វ្រីអេសិន រួចហើយយើងស្គាល់ដែរ យៀរនិន។ ចុះអ្នកណាគេដែលជា កេណ្ណេត អឹម ឃ្វីន នេះ?

[១៤:២៣:២៩]

**ឆ៖** កេណ្ណេត ឃ្វីន គឺជាមន្ត្រីយោធាកងទ័ពរបស់អាមេរិក។ តាមខ្ញុំចាំមិនខុសនោះ គាត់ស្ថិតនៅក្នុងស្ថានបេសសកម្មនៅ “ខុនធើ”– វៀតណាម ដែលគាត់ធ្វើការវាយការណ៍លើព័ត៌មានដែលប្រជាជនកម្ពុជានោះបានវាយការណ៍ប្រាប់គាត់នៅពេលដែលពួកគេឆ្លងចូលវៀតណាម។ ហើយអត្ថបទរបាយការណ៍នេះ គឺគាត់ផ្អែកទៅលើសាទូរលេខតាមអាកាស ដែលគាត់ធ្វើការបញ្ជូន។ ហើយគឺគាត់មានការទទួលសិទ្ធិអនុញ្ញាតឲ្យបោះពុម្ពផ្សាយទៅលើចំណុចឯកសាររបាយការណ៍ទាំងអស់នេះ។

**ស៖** ចំណុចយោងមួយគឺមានសរសេរដាក់ថា “ប៉ែន យៀរនិន: តើប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា?” ទំព័រ៣៦៨ ទៅដល់ ៣៩៣។ នៅក្នុងឯកសាររបស់លោក តារាងដែលលោកមាននោះគឺថាលោកនឹងឃើញ គឺមានឯកសារដកស្រង់ចេញពីសៀវភៅ ប៉ែន យៀរនិន។ តើលោកអាចបញ្ជាក់ទេ តើអ៊ីចឹងមែនដែរឬទេ ដែលលោកយកមកពី ប៉ែន យៀរនិន?

លោកប្រធានខ្ញុំសូមពន្យល់លោក លោកស្រីចៅក្រម។ ឯកសារនេះគឺត្រូវបានបង្ហាញជូនអង្គជំនុំជម្រះរួចមកហើយដោយខ្ញុំ នៅពេលដែលខ្ញុំបានបង្ហាញឯកសារ។ ឯកសារដកស្រង់ចេញពី E3/1815។

ខ្ញុំសូមសង្ខេប ហើយសួរទៅកាន់លោកសាក្សីនូវសំណួរមួយចំនួន។ លោក ហេដឌ័រ នៅពេលនេះគឺខ្ញុំសូមឲ្យលោកមើលទំព័រទី២ ដែលមាននៅក្នុងសំណុំឯកសាររបស់លោក គឺទំព័រ៣៦៩នៃសៀវ-ភៅរបស់លោក ឃៀរនិន -- 00487489, ខ្មែរ ERN គឺ 00104869។ ត្រង់ផ្នែកនេះគឺថាមិនមានការបកប្រែជាភាសាបារាំងនោះទេ។ ខ្ញុំនឹងព្យាយាមសង្ខេប។ នៅក្នុងនេះនិយាយអំពីឆ្នាំ១៩៧៣ ហើយនិងការជម្លៀសក្រចេះ ការជម្លៀសខេត្តក្រចេះ។ តាមការស្រាវជ្រាវរបស់លោក ក្រោយពីលោកសិក្សាទៅលើឯកសារកិច្ចសម្ភាសន៍ដែលលោកបានធ្វើឡើង តើលោកមានព័ត៌មាន ឬក៏អង្គហេតុទាំងឡាយដែលអាចជួយបំភ្លឺតុលាការអំពីការជម្លៀសនៅក្នុងខេត្តក្រចេះ ឆ្នាំ១៩៧៣ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

[១៤:២៦:៤៣]

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថាលោក ហេដឌ័រ គាត់ដឹងឬក៏អត់នោះទេ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាកំពុងតែសួរចេញពីជាពីសាក្សីទៅជាអ្នកជំនាញហើយ។ ច្បាស់ណាស់ថា សំណួរដែលសួរដោយសហព្រះរាជអាជ្ញានេះ ទោះបីជាមានការលម្អបន្ថែមពីលើក៏ដោយ គឺថាគាត់ធ្វើហាក់ដូចជាគាត់យោងទៅលើឯកសារផ្សេងៗ ក៏ប៉ុន្តែសំណួរបែបនេះគឺជាសំណួរដែលសួរទៅកាន់អ្នកជំនាញហើយ មិនមែនសួរទៅកាន់សាក្សីទេ។ ទោះបីជាយើងម្នាក់ៗគិតយ៉ាងម៉េចក៏ដោយ ក៏យើងដឹងហើយថាលោក ស្ទីវ ហេដឌ័រ នេះមិនមែមកបង្ហាញខ្លួនជាអ្នកជំនាញនោះទេ ឬក៏ក្នុងឋានៈជាអ្នកជំនាញនោះទេ។ គាត់មកក្នុងឋានៈជាសាក្សី។ ហើយគាត់ត្រូវតែផ្តល់នូវសេចក្តីចង្អុលបង្ហាញអំពីរបៀបដែលគាត់ប្រមូលព័ត៌មានមុននិងកំពុងពេលដែលគាត់ធ្វើការឲ្យតុលាការ។ ដូច្នេះសំណួរបែបនេះនោះ គឺថាជាការសួរទៅកាន់អ្នកជំនាញហើយ មិនមែនសួរទៅកាន់សាក្សីនោះទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការសួររបស់សហព្រះរាជអាជ្ញា។

[១៤:២៨:២៥]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំសួរសំណួរ -- ខ្ញុំមិនសួរសំណួរអំពីការឲ្យផ្តល់មតិយោបល់នោះទេ ដោយសារអង្គជំនុំជម្រះផ្តល់ការណែនាំរួចមកហើយ។ ខ្ញុំមិនមែនសួរសាក្សីឲ្យផ្តល់មតិយោបល់លើការជម្លៀសក្រចេះនោះទេ

ក៏ប៉ុន្តែខ្ញុំសួរគាត់ថាតាមការស្រាវជ្រាវ និងការសម្ភាសដែលគាត់បានធ្វើឡើង និងឯកសារដែលគាត់មាននោះ ថាតើគាត់ដឹងដែរឬទេ? ខ្ញុំមិនមែនសួរឲ្យគាត់ផ្តល់យោបល់មតិនោះឡើយ។

ខ្ញុំសូមបន្ថែមដូច្នេះថា លោក ហេងឌ័រ គឺគាត់បានបញ្ជាក់រួចមកហើយ បញ្ជាក់យ៉ាងច្បាស់ថា គាត់បានធ្វើការសម្ភាសជាច្រើន ក៏ប៉ុន្តែកំណត់ហេតុកិច្ចសម្ភាសន៍ទាំងអស់នោះ មិនមាននៅក្នុងសំណុំរឿងរបស់យើងនោះទេ។ ដូច្នេះ ខ្ញុំសូមស្នើដោយគោរពថា ខ្ញុំមានសិទ្ធិសួរអំពីការដឹងឮរបស់គាត់ដោយផ្ទាល់ ការសម្ភាសដែលគាត់បានធ្វើឡើង យោងតាមអនុស្សរណៈដែលអង្គជំនុំជម្រះបានណែនាំនោះ។ ដូច្នេះសូមអនុញ្ញាតពីអង្គជំនុំជម្រះឲ្យខ្ញុំបន្តទៅមុខទៀត។

[១៤:២៩:៣០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ចំពោះសំណួររបស់ -- សំណួរចុងក្រោយនេះរបស់តំណាងសហព្រះរាជអាជ្ញាគឺមិនមានមូលដ្ឋានសមស្របទេ។ សំណួរនេះ គឺសមស្របហើយក្នុងនាមលោក ស្ទីវ ហេងឌ័រ ជាសាក្សី។ ដូច្នេះ សូមលោកសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំសូមសួរសំណួរឡើងវិញ។ នៅពេលនេះ លោក យៀរនិន និយាយអំពីការជម្លៀសខេត្តក្រចេះឆ្នាំ៧៣។ លោកបានបញ្ជាក់រួចមកហើយ។ ខ្ញុំគិតថា នៅក្នុងឆ្នាំ៧៣ ដល់៧៥ លោកនៅក្នុងប្រទេសកម្ពុជា ដូច្នេះហើយខ្ញុំគួរតែសួរសំណួរបន្ថែម។ តើពិតដែរឬទេ គឺលោកមានវត្តមាននៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ៧៣ ដល់៧៥?

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំនៅក្នុងប្រទេសកម្ពុជា គឺតាមចាំមិនខុស គឺខ្ញុំនៅក្នុងខែឧសភា ឆ្នាំ៧៣ រហូតដល់ថ្ងៃ១១ ខែមេសា ឆ្នាំ៧៥ គឺខ្ញុំនៅក្នុងប្រទេសកម្ពុជា។

**ស៖** ខេត្តក្រចេះ ឆ្នាំ៧៣ -- ការជម្លៀសខេត្តក្រចេះ ឆ្នាំ៧៣ ថាតើមានការកើតឡើងដែរឬទេនៅពេលនោះ?

[១៤:៣១:០១]

**ឆ៖** ឆ្លើយដោយស្មោះត្រង់ គឺថាមិនមានអ្វីធ្វើឲ្យខ្ញុំដឹងភ្ញាមទេ បើសិនជាខ្ញុំមើលកំណត់ហេតុចាស់របស់ខ្ញុំ ខ្ញុំនឹងអាចឃើញអ្វីៗ ប៉ុន្តែឥឡូវនេះ ខ្ញុំមិននឹកឃើញនៅក្នុងគំនិតខ្ញុំភ្លាមនោះទេ ដែលខ្ញុំអាចឆ្លើយពីភាពប្រាកដ ដែលថាធ្វើឲ្យខ្ញុំឆ្លើយថា "បាទ ប្រាកដនោះទេ"។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ទំព័រពី ប៊ែន ឃៀរនិន, ៣៧១។ អង់គ្លេស 00487491, ខ្មែរ 00104870, អត់មានអត្ថបទជាភាសាបារាំងទេ។ ឃៀរនិន "ឆ្នាំ១៩៧៣ កំពង់ធំ យោងអង្គការដែលដឹកនាំដោយមនុស្សដែលម៉ឺងម៉ាត់ខ្លាំង វិន័យតឹងណាស់ ហើយមានការសម្លាប់ជាច្រើន"។ តើលោកអាចពន្យល់អ្វីបានពីកាប់សម្លាប់នៅខេត្តកំពង់ធំ ឆ្នាំ១៩៧៣?

[១៤:៣២:២៤]

**ឆ៖** នៅក្នុងគំនិតខ្ញុំ ឥឡូវនេះ ខ្ញុំមិននឹកឃើញទេ។ ខ្ញុំអាចឃើញរកអ្វីដែលនៅក្នុងឯកសារដូណល ឃើគ ជាស្នាដៃដែលគាត់បានធ្វើសម្ភាសនៅក្នុងខេត្តកំពង់ធំ ក្នុងឆ្នាំ១៩៧៤ គឺអាចដាក់នៅក្នុងអត្ថបទសារព័ត៌មានដែលលោកយោងទៅ ឬក៏នៅក្នុងអត្ថបទកាសែតដែលចុះនៅពេលនោះក៏មិនដឹង។

**ស៖** សូមអរគុណ។ និយាយពី ប៊ែន ឃៀរនិន, ទំព័រ៣៨៤, អង់គ្លេស 00487504, ខ្មែរ 0010487 -- ខ្ញុំគិតថា 89។ សូមលោកបើកទំព័រនេះ និយាយអំពី ប៊ែន ឃៀរនិន ទំព័រ៣៨៤។ "និយាយពីឧដុង្គ ខែមីនា ឆ្នាំ១៩៧៤" និយាយអំពី ដូណល ឃើគ ដែលធ្វើការអង្កេតអំពីក្រោយហេតុ-ការណ៍កើតឡើង ហើយខ្ញុំមិនចង់ដឹកមុខនោះទេ។ និយាយពីបទសម្ភាសន៍របស់លោក ការសិក្សារបស់លោក សៀវភៅរបស់លោក ការដឹងឮរបស់លោក។ ឧដុង្គឆ្នាំ១៩៧៤ តើមានអ្វីកើតឡើង? តើលោកអាចជួយពន្យល់បានឬទេ?

[១៤:៣៤:៣៣]

**ឆ៖** ខ្ញុំអាចពិនិត្យមើលថា ខ្ញុំបានទៅឧដុង្គ បន្ទាប់ពីកើតការវាយប្រហារនោះ។ ខ្ញុំសម្ភាសមនុស្សមួយចំនួនដែលនិយាយអំពីការដកប្រជាជនចេញទៅជនបទ។ ហើយខ្ញុំក៏បានសម្ភាសមនុស្សមួយចំនួនដែលនិយាយថា មានការកាប់សម្លាប់នៅកន្លែងកើតហេតុនោះ មានមនុស្សប្រភេទខ្លះ គឺដូនជីព្រះពុទ្ធសាសនា ហើយខ្ញុំចាំច្បាស់ណាស់ថាអំពីស្ថានភាពសាកសពនោះ។ ខ្ញុំបានឃើញសាកសពនោះនៅចាំប្រហែលជា ប្រាំមួយប្រាំពីរគឺជាសាកសពស្ត្រីដែលស្លៀកពាក់ជាដូនជីពុទ្ធសាសនាដែលស្លាប់នៅទីនោះ។

**ស៖** តើលោកបានឃើញអ្នកណាស្លាប់ដែលមានឯកសណ្ឋានអ្វីមួយទេ ជាកងទ័ពឬអ្វី? តើបាន

ឃើញសាកសព ឬអ្នកណាជាទាហាន លន់ នល់ ទេកាលនោះ?

**ឆ៖** ខ្ញុំមិនចាំអ្វីជាក់លាក់ដូចដែលលោកសួរនោះទេ ខ្ញុំមិនបានឃើញមិនចាំថាបានឃើញសាកសពអតីតទាហាន លន់ នល់ ឬក៏សាធារណរដ្ឋខ្មែរទេ។ ប៉ុន្តែខ្ញុំចាំដូចដែលខ្ញុំឆ្លើយខាងដើម។

**ស៖** និយាយពីការដែលគេប្រាប់លោកពីការកាប់សម្លាប់នៅឧដុង្គនោះ លោកបាននិយាយថាលោកបានសម្ភាសមនុស្សមួយចំនួន។ លោកនិយាយថាដូនជីពុទ្ធសាសនានោះ -- សំណួរទី១ខ្ញុំសួរតើអ្នកដែលលោកសម្ភាសហ្នឹងបានប្រាប់លោកទេ ថាអ្នកណាជាអ្នកសម្លាប់អ្នកទាំងនោះ?

**ឆ៖** មិនមានអ្វីសង្ស័យទេ គឺក្នុងចិត្តមនុស្សគឺអ្នកនោះដឹង ការកាប់សម្លាប់ហ្នឹងគឺថាធ្វើឡើងដោយកងកម្លាំងខ្មែរក្រហមដែលចូលកាន់កាប់ឧដុង្គ មកដកប្រជាជនចេញ ប្រជាជនទាំងអស់ទៅជនបទ គឺអ្នកនោះហើយដែលសម្លាប់។ នេះខ្ញុំឮពីពួកគេ។

[១៤:៣៦:៥៧]

**ស៖** តើរយៈពេលប៉ុន្មានបន្ទាប់ពីខែមីនា ឆ្នាំ១៩៧៤ នោះជាសប្តាហ៍ ឬក៏ខែ ក្រោយពីហេតុ-ការណ៍ហ្នឹងដែលលោកទៅឧដុង្គហ្នឹង?

**ឆ៖** ខ្ញុំសង្ស័យថាប្រហែលថ្ងៃ១៩ គឺថ្ងៃបន្ទាប់ ពីព្រោះខ្ញុំនៅភ្នំពេញខ្ញុំទៅភ្លាម ហើយខ្ញុំទៅឃើញសាកសពហ្នឹងគឺថានៅថ្មីៗនៅឡើយទេ គឺខ្ញុំទៅ១ថ្ងៃបន្ទាប់ពីហេតុការណ៍។

**ស៖** ប្រជាជនមុនការជម្លៀស ហើយប្រជាជនក្រោយការជម្លៀសចេញពីឧដុង្គហ្នឹង តើលោកអាចពន្យល់តុលាការដូចម្តេចបាន?

**ឆ៖** ខ្ញុំមិនមានតួលេខនៅក្នុងខួរក្បាលខ្ញុំទេថ្ងៃនេះ ក្នុងចិត្តខ្ញុំ។

**ស៖** តើឧដុង្គមើលទៅដូចម្តេច ជាទីប្រជុំជន អគារមានការបំផ្លាញ ឬក៏ធម្មតា? សូមលោកប្រាប់ជាទិដ្ឋភាពទូទៅគឺថាក្រុងឧដុង្គខែមីនា ឆ្នាំ១៩៧៤។

[១៤:៣៨:១៣]

**ឆ៖** តាមការចងចាំរបស់ខ្ញុំ គឺទីក្រុងនោះត្រូវបានបំផ្លិចបំផ្លាញជាច្រើន។ អ្វីៗបិទទ្វារទាំងអស់ខ្ញុំឡើងទៅលើកំពូលភ្នំនោះ ខ្ញុំឃើញមានការខ្មេចខ្ទី ហើយសាកសពដូនជីគឺនៅជើងភ្នំនោះ។ ពេលដែលយើងឡើងពីខាងក្រោមទៅលើនោះ នៅក្បែរវិហារនោះ។ នៅពេលដែលយើងទៅដល់នោះគឺថា ទាហានសាធារណរដ្ឋខ្មែរបានទៅទីនោះកាលពីមុន។ ប៉ុន្តែក្រោយមកមិនឃើញមានប្រជាជននៅកន្លែងនោះទេ គឺថាមានមនុស្សមួយចំនួនដែលខ្ញុំសួរនោះគឺអ្នកហ្នឹងបានគេចខ្លួនពីការជម្លៀសថ្ងៃនោះ។ យើងនិយាយ

អំពីហេតុការណ៍ហ្នឹងគឺថាមនុស្សមួយចំនួន គឺមិនដល់ទៅពាន់ទេ គឺថាមួយចំនួនតូចទេដែលនៅសេសសល់នោះ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យច្បាស់ទេថាតើមានការជម្លៀសប្រជាជនពីឧដុង្គទៅកន្លែងណាដែរឬទេ?

**ឆ៖** តាមដែលខ្ញុំចាំ គឺថាគេជម្លៀសទៅខាងលិច។

**ស៖** តើលោកអាចពន្យល់បានទេ លោកដឹងថាអ្នកណាជាអ្នកបញ្ជាឲ្យជម្លៀស កងកម្លាំងខ្មែរក្រហមឈ្មោះអ្វី? ភូមិភាគណា? អ្នកណាជាអ្នកអនុវត្ត សកម្មភាពហ្នឹងនៅក្នុងឧដុង្គ ខែមីនា ឆ្នាំ១៩៧៤ នោះ តើលោកបានដឹងអ្វីខ្លះពីរឿងហ្នឹង?

[១៤:៤០:០០]

**ឆ៖** អាចថា ភូមិភាគពិសេសតំបន់១៣--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ឥឡូវនេះៗគឺថាសហព្រះរាជអាជ្ញាសួរឆ្លងព្រំដែនពីសាក្សីទៅអ្នកជំនាញហើយសួរថាហេតុអ្វីបានជាលោកទៅទីនោះ ហើយឲ្យលោកធ្វើការ -- បានឃើញអ្វី? តើលោកឮអ្វី? តើលោកយល់ឃើញដូចម្ដេច? ប៉ុន្តែសំណួរហ្នឹងសួរថាអ្នកណាជាមេដឹកនាំខ្មែរក្រហម? អ្នកទទួលបន្ទុកកន្លែងហ្នឹង? អានេះមានតែអ្នកជំនាញទេដែលអាចឲ្យយោបល់បាន ដែលសហព្រះរាជអាជ្ញាឆ្ពោះផុតពីព្រំដែននេះ។ ខ្ញុំសូមជំទាស់ហើយ ពីព្រោះគាត់បានរុញសាក្សីឲ្យទៅជាអ្នកជំនាញ។

[១៤:៤១:១១]

**លោក ឃីត វេយ៍ន័រ៖**

ឥឡូវខ្ញុំយល់ស្របអ៊ីចឹង។ ប៉ុន្តែឥឡូវខ្ញុំសួរម្យ៉ាងវិញទៀត។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកសាក្សី តើលោកបាននិយាយជាមួយអ្នកណាម្នាក់ -- សូមលោកកុំនិយាយស្មាន។ តើលោកបាននិយាយជាមួយអ្នកណាម្នាក់ ឬក៏ពិភាក្សាជាមួយអ្នកណាម្នាក់ ទទួលព័ត៌មាន ឬក៏ភស្តុតាង

ជាក់ស្ដែងពីពួកគាត់អំពីកងកម្លាំងណាដែលចូលមក ហើយរំដោះ ឬក៏ជម្លៀសក្រុងឧដុង្គ? លោកកុំនិយាយស្មាន បើឮយ៉ាងម៉េច លោកថាតាមបែបហ្នឹង?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ចម្លើយហ្នឹងគឺថា គឺមិនមានចម្លើយហ្នឹងទេនៅពេលនោះៗ។ ម្យ៉ាងទៀត សន្មតថាខ្ញុំថាត្រូវគឺខ្ញុំទៅថ្ងៃទី១៩ ខែមីនា ឆ្នាំ៧៤ហ្នឹង គឺថាខ្ញុំទៅទីនោះគឺក្នុង មានតួនាទីទៅសួរសំណួរ ហើយនិងទៅចង់ឲ្យដឹងពីហេតុការណ៍ទាំងអស់នោះឯង។ មូលដ្ឋានដែលខ្ញុំរៀបឃ្លារបស់ខ្ញុំ អ្វីដែលខ្ញុំដឹងពីបទសម្ភាសន៍ផ្សេងទៀតដែលខ្ញុំបានដឹងពេលក្រោយមកថា អ្នកណាជាអ្នកអនុវត្តប្រតិបត្តិការនៅទីនោះ ដោយដាក់បញ្ចូលគ្នាពីទីតាំង ហើយនិងព័ត៌មាន ពីបទសម្ភាសន៍ក្រោយៗនោះ ខ្ញុំអាចទានសេចក្ដីបញ្ជាក់ថាបទសម្ភាសន៍ជាបន្តបន្ទាប់ក្រោយអាចមានអត្ថន័យឲ្យច្បាស់ទាក់ទងឲ្យបានចម្លើយឲ្យច្បាស់លាស់ហ្នឹងគឺ-- ប៉ុន្តែជាថ្មីម្តងទៀតដែលខ្ញុំមិនអាចឆ្លើយច្បាស់ពេលនេះទេ ខ្ញុំនឹងមើលកំណត់ដៃ ហើយនិងរកមកឆ្លើយ។

[១៤:៤៣:០៥]

**ស៖** តាមទស្សនៈរបស់ខ្ញុំ នេះជាចំណុចសំខាន់ណាស់។ យើងបាននិយាយរួចហើយថា បទសម្ភាសន៍ជាច្រើនរបស់លោកនោះមិនទាន់បានដាក់ចូលសំណុំរឿងនោះទេ។ ហើយវាមានផ្សាភ្ជាប់ទៅនឹងទិដ្ឋភាពផ្សេងទៀត។ តើមានវិធីណាមួយដែរឬទេ ដែលលោកអាចកំណត់អត្តសញ្ញាណឯកសារដែលអាចជួយបំភ្លឺតុលាការ ថាតើកងកម្លាំងណាដែលអ្នកអនុវត្តប្រតិបត្តិការនេះ គឺថាអាចនឹងស្អែក ឬក៏ខានស្អែក។ តើលោកអាចរកឃើញទេ តើអាចទៅរួចទេ បាទរកឯកសារហ្នឹងឲ្យឃើញ?

**ឆ៖** ខ្ញុំសូមព្យាយាមពន្យល់អំពីបទសម្ភាសន៍ឆ្នាំ១៩៧៨ និងលើសពីហ្នឹង គឺថាកាលណោះយើងមិនមានឯកសារជាឌីជីថលទេ។ របៀបដែលយើងកត់ត្រាបទសម្ភាសន៍ទាំងអស់នោះ ដូចដែលខ្ញុំបានរៀបរាប់ខាងដើមនោះឯង គឺយើងមើលពីបទសម្ភាសន៍ បរិមាណដែលនិយាយអំពីទិន្នន័យជីវប្រវត្តិខ្ញុំតាមរកថយក្រោយវិញទៅតាមព័ត៌មានដែលពាក់ព័ន្ធនេះ។ ខ្ញុំសូមជម្រាបថា ឯកសារទាំងអស់នេះគឺថាវា គឺថាមានផ្ដល់ជូនមកតុលាការមួយចំនួនជាបន្តបន្ទាប់។ ដំបូង ខ្ញុំធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនៅការិយាល័យសហព្រះរាជអាជ្ញា។ ខ្លះនោះគឺយើងមិនមានការចាប់អារម្មណ៍ខ្លាំងទេទៅទាក់ទងទៅនឹងសេចក្ដីសង្ខេប។ មូលហេតុដែលខ្ញុំលើកនេះគឺថា ការវាយតម្លៃនោះ គឺថា -- ខ្ញុំសុំត្រូវតែនិយាយថា គឺថាមិនមានតម្លៃជាភស្តុតាងច្រើនទេ គឺមានតិចតួចតែប៉ុណ្ណោះ។

[១៤:៤៥:០៧]

**ស៖** សូមកាត់លោកត្រឹមនេះសិន!

**ឆ៖** ចម្លើយសាមញ្ញគឺថាទេ គឺមិនងាយស្រួលក្នុងការរកទេ។

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី។ ឥឡូវដល់ពេលសមរម្យនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី-ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញឲ្យគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍។ លោកស្រីមានបំណងចង់និយាយអ្វី? សូមអញ្ជើញលោកស្រី!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក ហេងឌ័រ លោកប្រធានចង់ឲ្យខ្ញុំលើកឡើងចំណុចមួយចំនួនទៅកាន់លោក។ ទី១ ភស្តុតាងនៅចំពោះមុខសាលាក្តីនេះ គឺមានវិធានជាក់លាក់ដែលត្រូវបាន -- ដែលបានសម្រេចរួចមកហើយ។

[១៥:០៧:២៩]

វិធានទាំងអស់នោះ គឺយើងមិនមើលទៅលើការស៊ើបអង្កេតនោះទេ។ ដូច្នេះប្រសិនបើបញ្ហានេះលេចឡើងសាជាថ្មី អង្គជំនុំជម្រះសូមឲ្យលោកកុំមើលបញ្ហាស៊ើបអង្កេតនេះ។ ចំណុចទី២ យើងខ្ញុំសូមអរគុណលោក ដោយសារតែពេលវេលា សូមឲ្យលោកព្យាយាមបង្រួមចម្លើយរបស់លោក។ ខ្ញុំដឹងថាលោកមានព័ត៌មានច្រើនណាស់ ក៏ប៉ុន្តែសូមឲ្យលោកស្តាប់ការសួរសំណួររបស់សហព្រះរាជអាជ្ញា ហើយសង្ខេបចម្លើយរបស់លោកឲ្យបានខ្លីតាមទៅតាមសំណួរ។ ហើយចំណុចទី៣ លោកសហព្រះរាជអាជ្ញាស្នើសុំឲ្យលោកសរសេរឈ្មោះអ្នកដែលលោកបានសម្ភាស។ លោកឯកភាពរួចហើយ។ នៅពេលនេះលោកប្រធានស្នើសុំឲ្យខ្ញុំនេះ សួរទៅកាន់លោក បង្ហាញបញ្ជាក់ឈ្មោះទាំងនោះជាសាធារណៈ។ ដោយសារតែអ្នកទាំងអស់នោះមិនមានឈ្មោះរហស្សនាមសម្រាប់ពួកគេនោះទេ។ ហេតុដូច្នេះហើយ យើងត្រូវតែគិតថា វាមានការត្រឹមត្រូវប្រសិនបើលោកលើកឡើងឈ្មោះនេះបញ្ជាក់ជាសាធារណៈឲ្យយើងបានស្គាល់។

លោកប្រធានតើខ្ញុំបានរៀបរាប់គ្រប់ចំណុចអស់ហើយឬនៅលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:០៩:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំមិនចង់ដណ្តើមមីក្រូនិយាយទេ គ្រាន់តែចង់បំភ្លឺបន្តិច ពីព្រោះថានៅពេលដែលគេសួរលោកអំពីប្រភពមួយចំនួនដែលបានបញ្ជាក់នៅក្នុងសៀវភៅរបស់លោក គឺនិយាយអំពីសៀវភៅមួយដែលសរសេរអំពី អ៊ិន សុភាព។ អ៊ីចឹងតើលោកគិតសរសេរ -- សៀវភៅហ្នឹងថាជាសៀវភៅដែលវ៉ៃអង្គុលីលេខជាភាសាបារាំង ហើយតើលោកធ្លាប់ស្គាល់ចំណងជើងសៀវភៅហ្នឹងទេ? "ខៀវ សំផន *អាហ្គង់ឌី អេ រេអែល*" នេះជាប្រវត្តិរូបសរសេរដោយ អ៊ិន សុភាព។ តើឯកសារហ្នឹងលោកមានបានយោងទៅដល់ទេ?

**លោក ស៊ីវ ហេងឆ័រ៖**

ខ្ញុំគិតថាជាគឺជាចំណងជើងដែលមាននៅក្នុងចំណុចដែលគេរើជាអង្គុយលើលេខនៅខាងលើនោះឯង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកអាចបញ្ជាក់បាននៅថ្ងៃនេះ ឬក៏ថ្ងៃស្អែកបានដែរឬទេ បើក្នុងករណីអាចបាន ខ្ញុំសូមជម្រាបជូនភាគីពាក់ព័ន្ធទៅនឹងចំណុចនេះ គឺថាឯកសារនេះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ហើយត្រូវបានដាក់ឲ្យជជែកពិភាក្សាដេញដោលដោយមានឯកសារE236/4/2។ ដូច្នេះឯកសារហ្នឹងនឹងទទួលបានលេខកូដ E3 នៅពេលឆាប់ៗនេះ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក ហេងឆ័រ សូមឲ្យលោកអានឈ្មោះ បញ្ជាក់ឈ្មោះដែលបានស្នើសុំអម្បាញ់មិញនេះ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ឈ្មោះគឺ ដោក សំអុល។

[១៥:១១:២៩]

**ស៖** តើលោកអាចបញ្ជាក់លេខឯកសារដែរឬទេ ប្រសិនបើមាន? ខ្ញុំមិនចាំថាតើមានលេខ E ឬក៏ D នោះទេ។ សូមឲ្យលោកជួយបញ្ជាក់។

**ឆ៖** គឺ D លេខនោះគឺ D210/10។

**ស៖** សូមអរគុណ។ តើខ្ញុំសុំឯកសារនេះមកវិញបានទេ ដើម្បីបង្ហាញ? លោក ហេងឆ័រ នៅពេលនេះ ខ្ញុំសួរអំពីឧដុង្គ ឆ្នាំ៧៤។ តើហេតុការណ៍នៃពេលវេលានោះ បានន័យថាខ្មែរក្រហមគ្រប់គ្រងឧដុង្គ ហើយខ្មែរក្រហមបានចូលមកវាយ -- ដូចដែលលោកបានរៀបរាប់ ហើយលោកលើកឡើងអំពីការជម្លៀសនៅពេលដែលលោកទៅថ្ងៃនោះ គឺសាធារណរដ្ឋខ្មែរគឺឈរទីតាំងនៅទីនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើលោកអាចបញ្ជាក់ទេ ការវាយប្រហារនោះកើតឡើងរយៈពេលប៉ុន្មានដែរនៅឧដុង្គនោះ គឺការវាយប្រហារដោយខ្មែរក្រហមនោះ ប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃដែរ នៅឧដុង្គ?

**ឆ៖** តាមខ្ញុំចាំ គឺជាង២៤ ឬក៏៣៦ម៉ោង។

**ស៖** តើខ្មែរក្រហមគ្រប់គ្រងកន្លែងនោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** កាលចងចាំរបស់ខ្ញុំគឺប្រហែលជា១ថ្ងៃ។ ខ្ញុំមិនច្បាស់ទេ និយាយដោយស្មោះតែម្តង។

**ស៖** ពាក់ព័ន្ធទៅនឹងការកាប់សម្លាប់ ថាលោកថាអត់មានទេ ក៏ប៉ុន្តែលោកប្រើពាក្យមួយឃ្លានៅក្នុងនោះ។ សូមឲ្យលោកបញ្ជាក់អំពីការសង្កេតមើលក្រោយពីការសម្ភាសរបស់លោក តើពាក្យដែលប្រភេទដែលៗលោកបានលើកឡើងក្នុងនោះៗគឺយ៉ាងម៉េច?

**ឆ៖** ការចងចាំរបស់ខ្ញុំ គឺគេបានរៀបរាប់អំពីការសម្លាប់យោធា មន្ត្រីរដ្ឋការ។ ហើយមាន -- មិនមានការលើកឡើងអំពី -- មានការលើកឡើងអំពីដូនជី ហើយខ្ញុំបានទៅមើលដែរ។

**ស៖** ទាហាន និងមន្ត្រីរដ្ឋការរបស់ខាងណាដែរ?

**ឆ៖** គឺខាងខ្មែរ -- សាធារណរដ្ឋខ្មែរ គឺយោធាខាងសាធារណរដ្ឋខ្មែរ។

[១៥:១៤:២០]

**ស៖** តាមការចងចាំរបស់លោក តាមការសម្ភាសដែលលោកបានធ្វើឡើង ឬក៏តាមប្រភពព័ត៌មានផ្ទាល់ដោយលោកកុំស្មានឲ្យសោះ តើលោកបានទទួលព័ត៌មានណាផ្សេងទៀតដែរឬទេ អំពីអ្វីដែលវានាំទៅដល់ការជម្លៀសនោះ? ហើយៗហេតុការណ៍ក្រោយពីការជម្លៀសពេលនោះ គឺវាយ៉ាងម៉េចដែរ? គឺការជម្លៀសកើតឡើងដោយសារតែការទម្លាក់គ្រាប់បែក ឬក៏ស្ថានភាពអ្វីដែរ?

**ឆ៖** ខ្ញុំមិនចាំអំពីចំណុចពន្យល់នេះទេ ហេតុអ្វីបានជាការជម្លៀសនោះវាកើតឡើង? ខ្ញុំមិនដឹងថាមូលហេតុអ្វីឡើយ។

**ស៖** ពាក់ព័ន្ធទៅនឹងប្រភពនៅក្នុងចន្លោះឆ្នាំ១៩៧១ ដល់ ៧៥ ខែមេសា គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ចន្លោះពេលហ្នឹង តើលោកមានព័ត៌មានអំពីការជម្លៀសណាមួយតាមតំបន់នៅក្នុងប្រទេសដែរឬទេ ក្រៅពីតំបន់ឧដុង្គដែលលោកបានលើកឡើង?

**ឆ៖** ជាការពិត ខ្ញុំបានទទួលព័ត៌មាន។ ខ្ញុំបានធ្វើកិច្ចសម្ភាសន៍ក្រោយពីការគ្រប់គ្រង ក្រោយកងកម្លាំងខ្មែរក្រហមនៅខេត្តកំពង់ចាម ទីរួមខេត្តកំពង់ចាម។ តាមខ្ញុំចងចាំកិច្ចសម្ភាសន៍នោះ គឺគេប្រាប់ខ្ញុំថា ប្រជាជនត្រូវបានគេជម្លៀសទៅប៉ែកបស្ចិម។ ប្រជាជនខ្លះត្រូវបានគេសម្លាប់នៅនឹងកន្លែងតែម្តង មុនពេលដែលគេជម្លៀសទៅភូមិភាគបស្ចិមនោះ។ ហើយខ្ញុំបើសិនចាំនោះ គឺថាកងទ័ពជើងទឹករបស់សាធារណរដ្ឋខ្មែរនោះ គឺថាមានឈរនៅទីតាំងនោះ ហើយមានការដេញចេញនៅពេលដែលគ្រប់គ្រងនោះ។ ខ្ញុំចាំថាឆ្នាំ៧២ ដូចជាឆ្នាំ -- និងឆ្នាំ៧៣ បើសិនជាខ្ញុំចាំមិនខុសនោះទេ។

[១៥:១៦:៣៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក អាកខ្វូរ វែកគែន៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ព្រោះខ្ញុំយល់ឃើញថា យើងស្ថិតនៅក្នុងស្ថានភាពវៀងលំបាកបន្តិច។ សហព្រះរាជអាជ្ញា គាត់សួរសំណួរពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើង ហើយចម្លើយរបស់លោក ហេងឆ័រ ដោយសុច្ឆន្ទៈនោះគឺគាត់ថា៖ "បាទ ពិតណាស់ ខ្ញុំបានស្តាប់ឮគេនិយាយអំពីហេតុការណ៍ហ្នឹង តាមរយៈការសម្ភាស"។ នេះជាតុលាការយើងមានឯកសាររាប់ម៉ឺន រាប់ពាន់ដែលត្រូវបានដាក់ ហើយត្រូវបានប្រកាសទទួលស្គាល់ដោយអង្គជំនុំជម្រះ។ ហើយប្រសិនបើមានការសម្ភាស ហើយដែលស្ថិតនៅក្នុងសំណុំនៃភស្តុតាងដែលអាចត្រូវបានពិនិត្យដោយអង្គជំនុំជម្រះនោះ គឺថាវាស្ថិតនៅក្នុងសំណុំនៃភស្តុតាង។ ហើយលោក ហេងឆ័រ គាត់មកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីអំពីរបៀបដែលគាត់ប្រមូលភស្តុតាងសម្រាប់តុលាការ។ ដូច្នេះ វត្តមានរបស់គាត់នៅឧដុង្គនោះ គឺថាវាស្ថិតនៅក្នុងការស៊ើបអង្កេត ហើយមានវាសារៈសំខាន់ដល់ការរៀបរាប់អំពីព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រនេះ។ ក៏ប៉ុន្តែនៅពេលដែលគេសួរសំណួរជាលក្ខណៈទូទៅ ទៅកាន់សាក្សី ហើយសាក្សីគាត់ឆ្លើយថា "បាទ ខ្ញុំបានឮគេប្រាប់ខ្ញុំថាអ៊ីចេះ ថាអ៊ីចុះ"។

[១៥:១៨:៤៣]

ខ្ញុំសូមរំឭកម្តងទៀត យើងនៅ -- យើងកំពុងតែសួរសំណួរទៅកាន់អ្នកជំនាញហើយ ដែលទាមទារឲ្យគាត់ឆ្លើយឲ្យច្បាស់។ ហើយសហព្រះរាជអាជ្ញាគាត់បានចាត់ទុកថា សាក្សីនេះមានសមត្ថ-ភាពក្នុងការរៀបរាប់ហេតុការណ៍ដោយមិនចាំបាច់ផ្តល់សេចក្តីលម្អិត។ ដូច្នេះ លោក ហេងឆ័រ ជាច្រើនលើច្រើនសា គាត់យោងទៅលើកំណត់ត្រារបស់គាត់ដែលគាត់ត្រូវតែពិនិត្យមើលឡើងវិញ ហើយយើងមិនដឹងថាតើគាត់មាននៅជាមួយគាត់ ឬក៏នៅផ្ទះគាត់ ឬក៏នៅកន្លែងផ្សេង កំណត់ត្រារបស់គាត់នោះ។ ដូច្នេះ ធ្វើឲ្យខ្ញុំរំឭកទៅសក្ខីកម្មរបស់លោក ឆេនដ័ល័រ។ លោក ឆេនដ័ល័រ ក៏អ៊ីចឹងដែរ គាត់ឲ្យតែនិយាយអី គាត់ថាទាល់តែគាត់មើលកំណត់ត្រារបស់គាត់សិន ដែលគាត់ទុកនៅកន្លែងនេះ ទុកកន្លែងនោះ គាត់អាចពិនិត្យនៅពេលល្ងាច ហើយព្រឹកឡើងក៏មកផ្តល់ព័ត៌មានដល់តុលាការ។ ក៏ប៉ុន្តែករណីនេះ វាខុសគ្នាព្រោះថាលោក ឆេនដ័ល័រ គាត់មកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ។ ហើយលោក ហេងឆ័រ គាត់បដិសេធមិនព្រមមកបង្ហាញខ្លួនជាអ្នកជំនាញទេ គាត់ព្រមធ្វើតែសាក្សី។

ដូច្នេះ ខ្ញុំគិតថាជាថ្មីម្តងទៀតហើយ គឺយើងចេញពីសំណួរដែលសួរទៅកាន់សាក្សីគឺជាសួរទៅកាន់អ្នកជំនាញទៅវិញទេ នៅពេលដែលយើងនិយាយថាគាត់មានសមត្ថភាព និងអាចជឿជាក់បានក្នុងការរៀបរាប់អំពីរឿងហេតុការណ៍ដែលគាត់ទទួលបានតាមរយៈពាក្យចចាមអារ៉ាម ហើយអត់មានឯកសារយោងច្បាស់លាស់នោះ។ ដូច្នេះហើយ ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរនេះរបស់សហព្រះរាជអាជ្ញា។

[១៥:២០:៣៤]

**លោក ឃីត រេយ៉ន័រ៖**

អនុស្សរណៈអ៊ីម៉ែល ថ្ងៃទី០៣ ខែកក្កដា ភាគី ជូនទៅដល់ភាគីទាំងអស់៖ "សំណួរទាំងឡាយគួរតែសួរឡើងគោលបំណងចម្បង គឺដើម្បីសួរទៅលើភស្តុតាងដែលសាក្សីបានប្រមូលបាន រួមទាំងក្នុងពេលសម្ភាស...។ល។"។ សំណួរដែលខ្ញុំសួរនេះគឺអំពីការសម្ភាសដែលសាក្សីនេះបានធ្វើឡើង។ គាត់ឆ្លើយក៏ឆ្លើយអំពីការសម្ភាសដែលគាត់បានធ្វើឡើងផងដែរ។

ការសន្និដ្ឋានលើកឡើងពីខាងមេធាវីការពារក្តីទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងទម្ងន់នៃភស្តុតាងមិនមែនភាពអាចទទួលយកបាននោះទេ។ មេធាវីការពារក្តី អាចសួរដេញដោលទៅកាន់លោក ស្ទីវហ្វិន ហេដឌ័រ បានដូចដែលគាត់ធ្លាប់ធ្វើឡើងចំពោះលោក ស្ពេនបឺក ដែលសួរទៅលើប្រធានបទស្រដៀងគ្នា។

ខ្ញុំនៅក្នុងថ្ងៃនេះបានមិនសួរសំណួរទាំងឡាយដែលវាមិនពាក់ព័ន្ធទៅនឹងការដឹងដោយផ្ទាល់របស់គាត់នោះទេ។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះ សុំបន្តសួរសំណួរទៅមុខទៀត។

[១៥:២២:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ឃើញថា សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ចំពោះរបៀបតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាក្នុងការសួរសាក្សីរូបនេះ គឺមិនមាន មិនសមស្របទេ។ តំណាងសហព្រះរាជអាជ្ញាគឺការតាំងសំណួរនេះគឺសមស្របទៅនឹងការណែនាំរបស់អង្គជំនុំជម្រះហើយ។ ដូច្នេះ សេចក្តីជំទាស់ហ្នឹងមិនមានប្រសិទ្ធភាព តំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលបន្តទៀតចំពោះសាក្សីរូបនេះ។

**លោក ឃីត រេយ៉ន័រ៖**

**ស៖** សូមអរគុណច្រើនលោកប្រធាន។ លោក ហេដឌ័រ ទីរួមខេត្តកំពង់ចាម ខែកញ្ញាឆ្នាំ១៩៧៣

លោកបានសម្ភាសប្រជាជនហើយពួកគេប្រាប់លោកអំពីការកាប់សម្លាប់នៅនឹងកន្លែងនោះតែម្តង។ តើអ្នកណាគេជាអ្នកធ្វើការកាប់សម្លាប់នៅកន្លែងនោះ?

**ឆ៖** គឺខ្មែរក្រហមដែលកងកម្លាំងខ្មែរក្រហមដែលចូលមកដល់កន្លែងនោះជាអ្នកកាប់សម្លាប់។

**ស៖** ទីរួមខេត្តកំពង់ចាម ខែកញ្ញា ឆ្នាំ៧៣ កិច្ចសម្ភាសន៍របស់លោកប្រាប់ថា "ប្រជាជនត្រូវបានគេជម្លៀសទៅខាងបស្ចិម"។ តើលោកអាចប្រាប់អំពីចំនួនប្រជាជនដែលគេជម្លៀសដែរឬទេ ឬក៏វិសាលភាពនៃប្រជាជននៅខេត្តកំពង់ចាមដែលត្រូវគេជម្លៀសនោះក្នុងឆ្នាំ៧៣ ប៉ុន្មាន?

[១៥:២៣:៥៣]

**ឆ៖** ខ្ញុំមិនមានតួលេខទេ ក៏ប៉ុន្តែដូចដែលខ្ញុំលើកឡើង ស្ថានភាពដែលរៀបរាប់ប្រាប់ខ្ញុំនោះគឺក្រោយហេតុការណ៍កើតឡើងគឺពាក់កណ្តាលទីរួមខេត្តតែប៉ុណ្ណោះដែលគ្រប់គ្រងដោយខ្មែរក្រហម។ ផ្នែកដែលខ្មែរក្រហមគ្រប់គ្រងនោះគឺត្រូវបានជម្លៀស។ អ្នកដែលខ្លះរត់គេចពីកន្លែងផ្សេង ក៏ប៉ុន្តែដូចខ្ញុំបញ្ជាក់អ៊ីចឹងមិនមែនថាប្រជាជនក្នុងទីរួមខេត្តទាំងមូលនោះត្រូវបានគេជម្លៀសទៅនោះទេ មិនមែនថាប្រជាជនទាំងមូលក្នុងខេត្តនោះត្រូវបានគេជម្លៀសឡើយ។

**ស៖** លោកបានឆ្លើយអំពីហេតុការណ៍ឧដុង្គ ឬក៏ប្រភេទមួយចំនួនផ្សេងទៀត។ តើមានអ្នកដែលត្រូវបានសម្ភាសនោះបាននិយាយអំពីប្រភេទមនុស្សផ្សេងទៀតដែលត្រូវបានគេជម្លៀស ឬក៏សម្លាប់ចោលនៅក្នុងខេត្តកំពង់ចាមក្នុងខែកញ្ញា ឆ្នាំ៧៣ ដែរឬទេ?

**ឆ៖** ការចងចាំទូទៅរបស់ខ្ញុំគឺ គឺដូចទៅនឹងប្រភេទដែលខ្ញុំបានលើកឡើងពីមុនអ៊ីចឹង គឺមន្ត្រីយោធា រួមទាំងមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរត្រូវបានគេសម្លាប់ចោល។ ប្រភេទផ្សេងសំដៅលើដូចអ្នកដូច្នេះ។

[១៥:២៥:១៩]

**ស៖** សូមអរគុណ។ លោកអាចបិទនូវឯកសារដែលខ្ញុំបានផ្តល់ឲ្យលោក ដែលហៅថា *អ៊ីនឌិច* នោះបានហើយពេលនេះ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំបានរៀបចំសំណុំឯកសារមួយច្បាប់សម្រាប់លោក ហេដឌ័រ យើងហៅថាជា *អ៊ីនឌិច* ឬក៏ឧបសម្ព័ន្ធផងដែរ ឯកសារនេះ។ តើខ្ញុំអាចផ្តល់ឯកសារនេះមួយច្បាប់ – *អ៊ីនឌិច* នេះមួយច្បាប់ទៅដល់សាក្សីដែរឬទេ? ដើម្បីឲ្យគាត់ដឹងថា តើមានអ្វីខ្លះនៅក្នុងនេះ? រួមទាំងខ្ញុំសូមផ្តល់ជូនទៅ

កាន់ភាគីនិងក្រុមប្រឹក្សាជំនុំជម្រះផងដែរ ដើម្បីឲ្យបានដឹងទាំងអស់គ្នា។ គឺខ្ញុំឲ្យជាសំណុំតែម្តង ជៀសវាងកុំឲ្យខ្ញុំឲ្យម្តងមួយៗ ឬក៏សុំដកចុះដកឡើងទៅវិញទៅមក។ ដូច្នេះហើយសូមអនុញ្ញាតពីអង្គជំនុំជម្រះចែកចាយនូវសំណុំឯកសារនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសទៅចែកចាយជូនសាក្សី ហើយនិងភាគី និងអង្គជំនុំជម្រះផង។

[១៥:២៨:២១]

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ដោយសារតែនៅពេលនេះភាគី និងក្រុមប្រឹក្សាជំនុំជម្រះមាន *អ៊ីនឌិច* នេះហើយ ដូច្នេះ ខ្ញុំសូមឲ្យលោក សួរបញ្ហានេះទៅកាន់លោក ស៊ីវ ហេងឌ័រ។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ មានសំណុំឯកសារបីបន្ថែមជូនលោក។ ហើយចំពោះឯកសារនៅក្នុងបណ្តុំហ្នឹងគឺថាមានលេខវា គឺលេខ១, លេខ២, លេខ៣ និងលេខ៤។ សូមឲ្យលោកនៅពេលនេះ បើកមើលសំណុំឯកសារលេខ២ ត្រង់ថេប៧។ ឯកសារ D210/10 នេះ ឯកសារនេះគឺជាសេចក្តីថ្លែងការណ៍របស់បុគ្គលម្នាក់ដែលលោកបានបញ្ជាក់ឈ្មោះជូនអង្គជំនុំជម្រះមុននេះ។ ដើម្បីឲ្យលោកងាយស្រួល សូមឲ្យលោកបើកមើលទំព័រ៦, ERN ជាភាសាអង់គ្លេស 00436882, ខ្មែរ 00392113, បារាំង 00463018។ នេះគឺជាការសម្ភាសដែលលោកធ្វើឡើងជាមួយនឹងបុរសរូបនោះ។ សំណួរនៅទំព័រខាងលើ ដែលលោកលើកឡើងពាក់ព័ន្ធទៅនឹងភូមិភាគបូព៌ា។ ដូច្នេះសូមឲ្យលោកពិនិត្យមើលហើយជារួមមកចាប់ពីឆ្នាំ៧៣ គឺវាអាចមានបញ្ហាផ្ទៃក្នុងលើជួរដឹកនាំ។ ឆ្លើយពីអ្នកដែលលោកបានសម្ភាសនោះគឺដូចតទៅ៖ “ជារួមចាប់ផ្តើមពី៧៣ ខ្ញុំចាប់ផ្តើមមានភាពសង្ស័យដោយសារតែឃើញសកម្មភាពវានៅឆ្នាំ៧៣ និង៧៤។ វាបោសសម្អាតកម្មាភិបាលផ្ទៃក្នុង និងចាប់កម្មាភិបាលធម្មតា ហើយចោទថាពួកនោះពុករលួយ ពាលាអាវាសែ។ ក្នុងពេលនោះគេចោទធំតែបញ្ហាពីរទេ គឺទី១ សីលធម៌រស់នៅជាមួយស្រីញី, ទី២ គឺគេចាត់ទុកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង”។ តើលោកអាចបញ្ជាក់បានដែរឬទេ នេះ

ចំណុចទាំងអស់នេះហើយ គឺអ្នកដែលលោកសម្ភាសនោះគឺឆ្លើយប្រាប់លោកអ៊ីចឹង?

**ឆ៖** បាទ គាត់ឆ្លើយប្រាប់ខ្ញុំដូច្នេះមែន។

**ស៖** ដើម្បីរំឭកយើងទាំងអស់គ្នា អ្នកដែលលោកត្រូវបានសម្ភាសនេះ តើអ្នកហ្នឹងធ្វើអីនៅក្នុងតំបន់ភូមិភាគហ្នឹង? គាត់មានតួនាទីអ្វីដែរ?

[១៥:៣២:២២]

**ឆ៖** គាត់ហ្នឹងគឺជា -- គឺគាត់ផ្លាស់ប្តូរពីតួនាទីមួយទៅតួនាទីមួយនៅក្នុងភូមិភាគបូព៌ា ហើយគាត់ក៏ធ្វើការនៅតាមតំបន់មួយចំនួននៅក្នុងនោះផងដែរ។ ក៏ប៉ុន្តែចុងក្រោយគាត់ធ្វើជាលេខានៅភូមិភាគកណ្តាល តំបន់២២។

**ស៖** សូមអរគុណ។ នៅពេលនេះខ្ញុំសូមសួរអំពីខ្មែរហាណូយ។ សំណួរទី១ ដែលខ្ញុំសួរនោះ គឺថានៅក្នុងកំណត់ហេតុនេះដដែល។ សូមឲ្យលោកបើកត្រឡប់ក្រោយមួយទំព័រ ទំព័រ៥។ អង់គ្លេសគឺ 00436881, បារាំងមានលេខ 00463017, ខ្មែរមានលេខ 00392112។ "សំណួរ៖ ឆ្នាំ៧៣? ឆ្លើយ៖ គឺតាំងពីឆ្នាំ៧៣ ព្រោះពេលនោះមកខ្ញុំឃើញស្ថានភាពប្រែប្រួល។ បញ្ហាទី១ ចម្បងគឺឃើញគេបណ្តេញវៀតណាម។ បណ្តេញកងទ័ពវៀតណាមឲ្យចេញពីព្រំដែនកម្ពុជាវៀតណាម និងឲ្យចេញពីទឹកដីរបស់យើង មិនឲ្យនៅក្នុងឆ្នាំ៧៣ អំឡុងខែកក្កដា ខែសីហា។ ខ្ញុំអត់ចាំខែទេ ក៏ប៉ុន្តែព្រឹត្តិការណ៍ហ្នឹងជាព្រឹត្តិការណ៍ទី១។ ព្រឹត្តិការណ៍ទី២ ចាប់ផ្តើមឆ្នាំ៧៣ គឺការបោសសម្អាត និងការចាប់កម្មាភិបាលមកពីខាងជើង ដែលបានបណ្តុះបណ្តាលនៅវៀតណាមខាងជើងនិងហាណូយ។ វាចាប់ផ្តើមចាប់បណ្តើរៗហើយ"។ តើលោកអាចបញ្ជាក់ទេចំណុចទាំងអស់នេះ គឺអ្នកដែលលោកបានសម្ភាសហ្នឹងបាននិយាយប្រាប់លោកដូច្នេះ?

[១៥:៣៣:២៨]

**ឆ៖** ជាការពិតដូច្នេះមែន។ ក៏ប៉ុន្តែមានការបកប្រែខុសបន្តិចនៅក្នុងឯកសារនេះ។ ការបកប្រែនោះគេដាក់ថាខាងជើង តាមពិតទៅវាសំដៅលើភូមិភាគឧត្តរ។ នៅក្នុងប្រព័ន្ធខ្មែរក្រហមនោះ គឺសំដៅទៅលើភូមិភាគឧត្តរ។

**ស៖** យើងមើលឯកសារមួយទៀត គឺសំណុំឯកសារទី២ *ថេប*១។ E3/1714 ទំព័រ១។ នេះគឺជានៅក្នុងលិបិក្រមទី១ ឯកសារទី២នៅក្នុងឯកសារដដែលនៅខាងមុខដែលលោកមាននោះឯង។ លោកមានលេខនៅពីមុខ ហៅថា "*ថេប*" នោះ។ *ថេប១* នៅខាងក្រោយ*ថេប*១។ តើលោកឃើញទេ? នេះ

ឯកសារ E3/1714, ចំណងឯកសារ "បទសម្ភាសន៍ជាមួយជនភៀសខ្លួនខ្មែរនៅព្រំដែនកម្ពុជា-ថៃ, ខែកុម្ភៈ មីនា ឆ្នាំ១៩៨០"។ អ្នកធ្វើសម្ភាស ម៉ាសាតូ ម៉ាស៊ុស៊ីតា នាយកព័ត៌មានប្រចាំប្រទេស, សារព័ត៌មានក្យូដូ, ស៊្មីវិន ហេដឌ័រ និស្សិតបញ្ចប់ការសិក្សាសាកលវិទ្យាល័យខូណែល។ ហើយខ្ញុំនឹង -- ទំព័រលេខ ERN ដែលនៅខាងក្រោមទំព័រ២០បាទ។

ទំព័រ២០ អង់គ្លេស ERN 00170712, បារាំង 00648977, ខ្មែរ 00234703។ បទសម្ភាសន៍លេខ១៣ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៨០ នៅស្រះកែវ។ មានប្រភពពីរ "ទាំងពីរសុទ្ធតែជាគ្រូមកពីស្រះកែវមួយឈ្មោះ ខែម កើតនៅកំពង់ហ្លួង នៅក្នុងតំបន់រំដោះ ក្នុងឆ្នាំ១៩៧០។ គេចាត់ទុកគាត់ជាអ្នកមូលដ្ឋានទំនងជាមានការអប់រំ ប៉ុន្តែអះអាងថាមិនមានមុខតំណែងនៅក្នុងបក្ស ឬក៏នៅក្នុងរដ្ឋបាលអ្វីនោះទេ"។

ប្រភពមួយទៀតមានឈ្មោះថា "ហែម -- កែម ជាគ្រូនៅ -- ឈ្មោះ ហែម ជាគ្រូនៅសាលាបច្ចេកទេសឫស្សីកែវ គីឡូលេខ៦ ខាងជើងភ្នំពេញ ក្រោយឆ្នាំ១៩៧៥ គាត់ក៏ធ្វើជាជាងជួសជុលរថយន្តដែរ។ គាត់គឺជាខ្មែរកាត់ចិន"។ តើលោកបានបញ្ជាក់បានទេ បានសម្ភាសអ្នកទាំងពីរនេះ នៅក្នុងឱកាសពេលនោះ?

[១៥:៣៨:០៨]

**ឆ៖** បាទ។

**ស៖** ទំព័របន្ទាប់ ទំព័រ២១ នៅខាងក្រោម អង់គ្លេស ERN 00170713, បារាំង 00648978, ខ្មែរ 00324705។ "ខែម មានកងកម្លាំងវៀតណាមនៅក្នុងតំបន់១៥រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ នៅពេលដែលពួកគេត្រូវបានគេដកទៅវិញមានការចរចាជាបន្តបន្ទាប់សំដៅឲ្យមានការដកពួកវៀតណាមចេញពីតំបន់១២ ក្រោយឆ្នាំ១៩៧០ ប៉ុន្តែនៅឆ្នាំ១៩៧០ ពួកវៀតណាមមានកម្លាំងខ្លាំងក្លាណាស់។ បើយោងតាមគោលជំហរបក្ស គឺថាវៀតណាមមិនមានសិទ្ធិនៅក្នុងទីនោះទេ ហើយបក្សមានអំណាចចង់ឲ្យពួកគេចេញពីទីនោះ ប៉ុន្តែយើងទុក -- ទុនខ្សោយពេកមិនអាចបណ្តេញបានទេ។ ចាប់ពីឆ្នាំ១៩៧១ ពួកវៀតណាមបានទទួលសម្ពាធយោធា និងការទូតឲ្យចាកចេញពីទីនោះ។ សម្ពាធទីនោះបានបន្តរហូតដល់ឆ្នាំ១៩៧២។ ក្នុងឆ្នាំ១៩៧៣ មានការចរចាជាច្រើនរវាងមេបញ្ជាការវៀតណាម និងមេបញ្ជាការខ្មែរ ហើយពួកគេបានយល់ព្រមជាគោលការណ៍ថា វៀតណាមនឹងធ្វើការដកចេញ ប៉ុន្តែអង្គភាពវៀតណាមខ្លះ មានការរឹងរូសមិនព្រមដកចេញឡើយ ហើយពួកគេក៏ត្រូវបានបង្ខំឲ្យចេញ។ មានការបង្ហូរឈាមយ៉ាងច្រើននៅក្នុងឆ្នាំ១៩៧៣ មុនពេលដែលកងទ័ពវៀតណាមទាំងអស់បានចាកចេញផងដែរ។

[១៥:៣៩:៤៥]

នៅពេលនោះ យើងក៏បានបណ្តេញចេញជនជាតិ ប្រជាជនវៀតណាមចាកចេញផងដែរ។ នេះគេចាត់ទុកថាជាមាតុនិវត្តន៍។ មាគ៌ាបក្ស គឺថានរណាម្នាក់ដែលស្រលាញ់កម្ពុជា អាចនៅបន្តទៀតបាន។ ប៉ុន្តែគេបញ្ជាក់ច្បាស់ថា ប្រសិនបើនៅអនាគតមានវិវាទកាន់តែរីកធំឡើង ប្រជាជនវៀតណាមមិនអាចទទួលរបបនៅកម្ពុជាបានទេ ពួកគេនឹងមិនត្រូវបានទុកឲ្យនៅទៀត តទៅទៀតទេ”។ តើលោកអាចបញ្ជាក់ថា លោកបានឮពាក្យសម្តីហ្នឹងពីប្រភពដែរឬទេ?

**ឆៈ** បាទ។

**សៈ** ឥឡូវយើងស្ថិតនៅឯកសារនេះដដែល ទំព័រ៣២, អង់គ្លេស ERN 00170723, ខ្មែរ 00324722, បារាំង 00648987។ បទសម្ភាសន៍លេខ១៨ នៅស្រះកែវ គឺប្រភពបុរសម្នាក់មកតំបន់១៣ នៅប៉ែកនិរតី។ ជាតំបន់១៣ មានស្រុកចំនួន៥។

ឥឡូវនេះ គឺនៅទំព័រ៣៣, អង់គ្លេស 00170724, បារាំង 00648988, ហើយខ្មែរ 00324 725។ នៅក្នុងពេល -- នៅពេលមានរដ្ឋប្រហារ លន់ នល់ កងទ័ពវៀតណាមបានចូលមក ហើយបានបង្កើតអំណាច។ រដ្ឋស្ថិតនៅក្រោមការត្រួតត្រារបស់តំបន់១៣។ ជនជាតិខ្មែរដែលនៅហាណូយ ឆ្នាំ ១៩៥៤ ត្រូវបានដាក់ឲ្យទទួលបន្ទុកកិច្ចការនៅទីនោះ ប៉ុន្តែស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម។ ខ្ញុំនៅចាំឈ្មោះតែម្នាក់ប៉ុណ្ណោះក្នុងចំណោមអ្នកទាំងនោះ យ៉ែម គឺជាអ្នកមក -- គឺជាលេខាជនជាតិខ្មែរម្នាក់ ហើយមានជនជាតិខ្មែររាប់រយនាក់បានមកតំបន់១៣ ដែលអ្នកទាំងនោះមកហាណូយ។ ក្រោយពេលវៀតណាមត្រួតត្រាប្រទេសកម្ពុជា ខ្មែរដែលមកពីហាណូយ កាន់តំណែងនៅថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ។ ខ្ញុំមិនដឹងថាតើអ្នកទាំងនោះ ជនជាតិនោះមកពីហាណូយនោះមានកាន់តំណែងនៅភូមិភាគដទៃ។ ជនជាតិខ្មែរទាំងនោះ គឺជាមុខសញ្ញានៃការបោសសម្អាតចាប់ពីចុងឆ្នាំ១៩៧១”។ តើលោកអាចពន្យល់អ្វីបន្ថែម ថាលោកពិតជាបានឮអ្នកផ្តល់សម្ភាសប្រាប់លោកនោះមែនឬទេ?

**ឆៈ** បាទ។

[១៥:៤២:៥៥]

**សៈ** ទំព័របន្ទាប់ គឺទំព័រ៣៤, អង់គ្លេស 00170725, បារាំង 00648989 ដល់ 90, ខ្មែរ 00324726 ដល់ 27។ សូមដកស្រង់៖ “ប៉ុន្តែនៅដើមឆ្នាំ១៩៧២ កងកម្លាំងកម្ពុជាទាំងអស់ ត្រូវបានប្រគល់មកឲ្យអង្គការខ្មែរវិញ។ នៅពេលនេះ ជនជាតិខ្មែរដែលមកពីហាណូយ មិនត្រូវបានគេទទួល

ចូលអង្គការខ្មែរឡើយ។ ពួកគេត្រូវបានហាមមិនឱ្យលាយឡំក្នុងអំណាចរដ្ឋរបស់យើងឡើយ។ ទាំងកម្មាភិបាលយោធា និងកម្មាភិបាលស៊ីវិល មិនត្រូវបានគេទទួលឡើយ។ អង្គការរបស់យើងបានធ្វើការដោះស្រាយបញ្ហានេះតាមលក្ខណៈដូចខាងក្រោម: យើងហៅជនជាតិខ្មែរទាំងអស់ដែលមកពីហាណូយឱ្យមករៀនសូត្រ ហើយមានមនុស្សម្នាក់នាំពួកគាត់ទៅ។ ដូច្នេះពិតណាស់ហើយ បណ្ដាញគឺថាអ្នកទាំងអស់នេះមានតំណែងជារដ្ឋបាល មិនមែនជាយោធានោះឡើយ។ អ្នកទាំងអស់នេះ គឺមានតែម្នាក់ពីរនាក់នៅក្នុងកន្លែងមួយដែលនៅដាច់ៗពីគ្នា។ ដូច្នេះ នៅពេលដែលយើងចាប់ផ្ដើមដកពួកគេចេញ អ្នកដទៃទៀតមិនបានដឹងថាមានអ្វីកើតឡើងទេ។ ដូច្នេះ យើងអាចមានលទ្ធភាពបោសសម្អាតពួកគេបានស្ទើរតែទាំងអស់។ មានតិចតួចណាស់ដែលបានដឹងថាមានអ្វីកំពុងកើតឡើង ហើយអ្នកទាំងនោះបានរត់ទៅប្រទេសវៀតណាម។ ខ្ញុំមិនដឹងថាគម្រោងការទូទៅចេញមកពីណានោះទេ ប៉ុន្តែគ្រប់ថ្នាក់នៃអង្គការខ្មែរមានការប្រជុំជាច្រើនដើម្បីពិភាក្សាអំពីវិធីអនុវត្តផែនការនោះ។ លំដាប់ថ្នាក់នីមួយៗបានទទួលការណែនាំពីថ្នាក់លើរបស់ខ្លួនជាបន្តបន្ទាប់"។ តើលោកអាចបញ្ជាក់បានឬទេ ខ្លឹមសារនេះពិតជាត្រឹមត្រូវតាមអ្វីដែលលោកដឹងដែរឬទេ?

**ឆ៖** បាទ។

[១៥:៤៥:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីវ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួររបស់សហព្រះរាជអាជ្ញា សួរថាតើលោកអាចបញ្ជាក់ថាខ្លឹមសារនេះត្រឹមត្រូវដែរឬទេ? នេះជាសំណួរដែលមានន័យថា អ្វីដែលសរសេរនៅទីនេះគឺជាការពិតកើតមានអ៊ីចឹងមែន។ សំណួរគួរសួរថាតើអ្នកណាអ្នកសរសេរនេះ តើលោកឮពីអ្នកណា? ហើយបាទ-- ប៉ុន្តែមិនអាចបញ្ជាក់ថាអាហ្នឹងវាជាការពិតនោះទេ។ សំណួរហ្នឹងជាសំណួរទូលំទូលាយ ប៉ុន្តែសួរថាតើលោកបានសរសេរដោយខ្លួនឯង ឬក៏លោកបានឮពីគេបែបនេះ ហើយលោកកត់ត្រា។ គួរសួរបែបនេះវិញ។

**លោក ឃីត រេយ៍ន័រ៖**

**ស៖** តើលោកសាក្សី តើអ្នកណាប្រាប់លោកពីរឿងនេះ ឬក៏លោកបានកត់តាមគេដែរឬទេ?

**ឆ៖** បាទ ។

**ស៖** ឥឡូវនេះ នៅក្នុងការរៀបរាប់ពីបុរសម្នាក់ដែលមកពីតំបន់១៣ តាកែវនោះថាតើខុសពីអ្នកហ្នឹង ថាតើលោកចាំពីមុខតំណែងរបស់គាត់ ឬឋានៈគាត់ទេ អ្នកដែលនិយាយនេះ?

**ឆ៖** អត់ទេ។ ខ្ញុំមានការចងចាំស្រពិចស្រពិលអំពីរាងរៅ ឬភិនភាគរបស់បុរសនេះ។

**ស៖** នៅក្នុងឯកសារហ្នឹង E3/1714, ឥឡូវនេះមើលទំព័រ៥៤, អង់គ្លេស គឺ 00170745, បារាំង 00649007, ខ្មែរ 00324757 បទសម្ភាសន៍២៩ នៅជំរំនាវា ថ្ងៃទី -- កងនាវាលេខ៦២ នៅចាន់បូរី ថ្ងៃទី១២ ខែមីនា "ប្រភព ឡុញ ហៅ ឡួន ជាសមាជិកគណៈអចិន្ត្រៃយ៍កំពង់សោម" តើសូមលោកពន្យល់ថា តើគណៈកម្មាធិការអចិន្ត្រៃយ៍កំពង់សោមហ្នឹងជាអ្វីឲ្យពិតប្រាកដនោះ?

[១៥:៤៨:១៥]

**ឆ៖** បាទ កំពង់សោមគឺជាកន្លែងតែពីរក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ដែលថាដូចជាកន្លែងដែលគណៈដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅកំពង់សោម ដែលក្នុងនោះ ឡុញ ក៏ជាសមាជិកដែរ។

**ស៖** ទំព័រ៥៧, អង់គ្លេស 00170748, បារាំង00649010, ខ្មែរ00324763 "ប្រសិនបើយើងបានភ្នំពេញក្នុងឆ្នាំ១៩៧៤ ក៏នៅតែត្រូវជម្លៀសប្រជាជនដដែល។ ព្រោះថាជាផែនការមានតាំងពីយូរមកហើយ"។ ពាក្យស្លោកនិយាយថា "រំដោះប្រជាជនពីដៃខ្មាំង" តើនេះជាការកត់ត្រាត្រឹមត្រូវអំពីអ្វីដែលគេប្រាប់លោកទេ លោកសាក្សី?

**ឆ៖** បាទ។

**ស៖** នៅក្នុងការសម្ភាសផ្ទាល់ដែលលោកបានធ្វើជាមួយបុគ្គលិកដែលទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យនៅក្នុងសម័យកាលនោះ តើមានសាក្សីណា មានឯកសារណាមួយដែលលោកនឹកឃើញថាមានការបញ្ជាក់អំពីឃ្លារំដោះប្រជាជនពីដៃខ្មាំងដែរឬទេ?

**ឆ៖** បាទ មានឯកសារច្រើនណាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៥:៥០:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ការសុំឲ្យបំភ្លឺសហព្រះរាជអាជ្ញាបានសួរថា តើមានសាក្សីណា

ផ្សេងទៀត តើសាក្សីជាន័យច្បាប់ ឬក៏សាក្សីជាសាក្សីឃើញផ្ទាល់ភ្នែកដែលបានប្រាប់មកលោកសាក្សី ហេងឆ័រ នៅពេលនេះ? អ៊ីចឹងសូមឲ្យបញ្ជាក់។

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំយល់ស្រប។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** សូមបំបែកសំណួរ។ ទី១ តើមានបុគ្គលណាម្នាក់ដែលលោកបានសម្ភាសដោយផ្ទាល់ប្រើឃ្លា "រំដោះប្រជាជនពីដៃខ្មាំង" ដែរឬទេ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** បាទ។

**ស៖** តើលោកអាចចង្អុលបង្ហាញថា មានបុគ្គលប៉ុន្មាននាក់ ឬក៏ភាគច្រើន ឬក៏ចំនួនដូចម្ដេច?

**ឆ៖** ខ្ញុំត្រូវតែនិយាយពីភាពទូទៅ។ ឃ្លាពិសេសមួយនេះបានបញ្ជាក់ប្រាប់ខ្ញុំដោយមនុស្សជាច្រើនច្រើនឆ្នាំនៅពេលដែលខ្ញុំធ្វើសម្ភាស។ បើខ្ញុំត្រូវទាយថាប្រហែលមានប៉ុន្មាន គឺថាលើសពី១២នាក់ទៅនោះច្រើនណាស់។ អ៊ីចឹងហើយគឺខ្ញុំបានឮតាំងពីសម័យកាលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្ញុំនៅភ្នំពេញ ខ្ញុំបានឮរួចទៅហើយ។ ហើយខ្ញុំសូមបន្ថែម ដោយសារលោកសួរទៅហើយនោះហើយក៏ធ្លាប់បានឃើញជាញឹកញាប់ៗ នៅក្នុងការផ្សាយឯកសារជាសាធារណៈនៅក្នុងសម័យមុនថ្ងៃទី១៧ ខែមេសា ៧៥ គឺថាមានវិទ្យុដែលស្ថិតនៅក្រោមផ្ទាល់ ឬដោយប្រយោលរបស់ខ្មែរក្រហមបានប្រើឃ្លានេះនៅក្នុងការផ្សព្វផ្សាយរបស់ខ្លួន។ ដែលក្រោយមក គឺសេវាផ្សាយព័ត៌មានបរទេសបានកត់ត្រាយក ថតបានសំឡេងហ្នឹងទៀតផង។

[១៥:៥៣:០១]

**ស៖** សូមអរគុណ។ ទំព័របន្ទាប់នូវបុគ្គលដែលលោកបានសម្ភាសនោះ គឺទំព័រ៥៨ ដែលមានអង់គ្លេស ERN 00170749, ខ្មែរ 00324763, បារាំង 00649011។ បន្ទាប់ពីការបរាជ័យ ការវាយលុកដើមឆ្នាំ១៩៧៤ គេមានរៀបវគ្គរៀនសូត្រមួយ។ ចុងឆ្នាំ១៩៧៤ មានវគ្គរៀនសូត្រទូទៅមួយ។ គោលដៅគឺដើម្បីរៀបចំការវាយលុកក្នុងឆ្នាំ១៩៧៥។ តើនេះគឺជាកំណត់ត្រាត្រឹមត្រូវពីអ្វីដែលលោក គេប្រាប់លោកដែរឬទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំឲ្យលោកទៅមើល *ថេប*ទី២ នៅក្នុងឯកសាររបស់លោក។ នេះជាបទសម្ភាសន៍របស់លោកជាមួយលោក អៀង សារី នៅថ្ងៃទី១៧ ឆ្នាំ១៩៧៧ គឺឯកសារ E3/89។ សូមបើកទំព័រលេខ៥នៃឯកសារនេះ, អង់គ្លេស ERN 00147603, បារាំង 00332685, ខ្មែរ 00062457 ដល់ 58។ លោកបានពិភាក្សាអំពីការប្រជុំខែកញ្ញា ឆ្នាំ១៩៧៨ បាទ សូមបង្ហាញត្រង់ចំណុចនេះ៖ "បញ្ហាហ្នឹងអត់មានជជែករឿងហ្នឹងទេ រឿងជម្លៀសហ្នឹងពីភ្នំពេញហ្នឹងគឺបានសម្រេចជាមុនរួចមកហើយ នេះបើតាមអ្វីដែលខ្ញុំដឹង គេប្រាប់ខ្ញុំ។ ខែមេសា ឆ្នាំ១៩៧៥? អត់ទេ គឺខែ៤ហ្នឹង ខែ៤... ក៏ប៉ុន្តែដើមខែ គឺមានលទ្ធភាពបើឈ្នះភ្នំពេញត្រូវគិតយ៉ាងម៉េច? បញ្ហា ខ្ញុំលើកបញ្ហានេះជាមួយ ប៉ុល ពត ក្នុងឆ្នាំ១៩៧៤ ថាតើត្រូវត្រៀមរៀបចំយ៉ាងម៉េចនៅពេលដែលយើងឈ្នះភ្នំពេញ? យើងបានពិភាក្សាអំពីប្រជាជនហ្នឹងពេលហ្នឹង"។ លោកសួរថា "ហ្នឹងសូមទោស លោកជួបគាត់នៅពេលណា? អៀង សារី៖ ខ្ញុំជួបគាត់នៅជិតភ្នំពេញ។ ខ្ញុំត្រឡប់មកពីប៉េកាំងវិញ ខ្ញុំមកក្នុងឆ្នាំ១៩៧៣ ជួបសម្តេចនៅហាណូយ ហើយខ្ញុំទៅប៉េកាំង ត្រឡប់មកវិញឆ្នាំ១៩៧៤"។

[១៥:៥៦:២៨]

លោកសួរថា "នៅពេលដែលលោកដឹកគណៈប្រតិភូសេដ្ឋកិច្ចទៅវៀតណាម ហើយទៅប៉េកាំង? អៀង សារី៖ បាទ ខ្ញុំត្រឡប់មកវិញ។ ខ្ញុំត្រឡប់មកវិញដល់ពេលនុ៎ងយើងជជែកគ្នាថា ត្រូវធ្វើដូចម្តេចនៅពេលយើងឈ្នះ ត្រូវរៀបចំដូចម្តេច។ នេះគឺមតិរបស់ឯកឧត្តម ជូ អេនឡាយ គាត់សួរខ្ញុំ បើពួកមិត្តឈ្នះ ពួកមិត្តមានផែនការដូចម្តេច? ខ្ញុំក៏ពិបាកដែរ ខ្ញុំមិនបានឆ្លើយអីទាំងអស់នៅពេលនុ៎ង។ ខ្ញុំនិយាយថា ខ្ញុំមិនទាន់ដឹងអីច្បាស់លាស់ទេ ខ្ញុំចាំមកសួរប្រទេស -- ក្នុងប្រទេសកម្ពុជាពីបញ្ហាហ្នឹងបន្ទាប់។ នៅពេលដែលខ្ញុំមកប្រទេសកម្ពុជាវិញ ខ្ញុំមិនបានសួរពីបញ្ហានេះទេ។ ប៉ុន្តែខ្ញុំសួរ ថាតើត្រូវមានដំណោះស្រាយអ្វីអំពីប្រជាជន។ តើដំណោះស្រាយអ្វីដែលត្រូវទាក់ទងនឹងប្រជាជន៣លាននៅភ្នំពេញ។ ប៉ុល ពត ឆ្លើយប្រាប់ខ្ញុំវិញថា គេមានបទពិសោធន៍គ្រប់គ្រាន់ដែលគេត្រូវការហើយ ហើយខ្ញុំមិនត្រូវព្រួយបារម្ភពីរឿងនេះទេ ហើយត្រូវព្រួយពីរឿងការងារនៅបរទេសហ្នឹងបានហើយ។ បន្ទាប់មក ខ្ញុំនិយាយថា មេដឹកនាំចិនបានសួរខ្ញុំអំពីបញ្ហានេះ។ គាត់និយាយថា ជាបញ្ហាងាយស្រួលក្នុងការដោះស្រាយទេ។ សមមិត្តចិនមិនមានអ្វីត្រូវព្រួយពីរឿងនេះទេ ពីព្រោះយើងជាខ្មែរ យើងមានសញ្ញាច្បាស់ក្រឡែតអំពីបញ្ហានេះ ដើម្បីដោះស្រាយ។ គឺយើងអាចដោះស្រាយបញ្ហានេះបាននៅក្នុងស្ទឹងត្រែង និងខេត្តក្រចេះរួចមកហើយ។ ដូច្នេះដំណោះស្រាយពីបញ្ហានេះ គឺត្រូវជម្លៀសប្រជាជន។ នោះគឺជាជម្រើសតែមួយ

ដែលយើងអាចដោះស្រាយបញ្ហានេះបាន។ ខ្ញុំឆ្លើយសួរ -- ថាតើជាការជម្លៀសទាំងអស់ ឬមួយយ៉ាងម៉េច? គាត់និយាយថាចាំមើលតើពេលមកដល់ជាក់ស្ដែងដូចម្ដេច។ ផ្ទុយទៅវិញពាក្យថាជម្លៀសនោះក៏បានប្រើរួចមកហើយនៅក្នុងឆ្នាំ១៩៧៤"។

តើនេះជាការកត់ត្រាត្រឹមត្រូវអ្វីដែលគេប្រាប់លោកដែរឬទេ ក្នុងពេលដែលសម្ភាសនោះលោកសាក្សី?

**ផ៖** បាទ។

[១៥:៥៩:២១]

**ស៖** ឥឡូវនេះយើងផ្អាកបន្តិច ត្រង់ការសម្ភាសជាមួយលោក អៀង សារី។ តើលោកអាចរៀបរាប់ពីបរិយាកាសនៃការសម្ភាស? តើណាត់ជួបម៉េច? តើការរៀបចំការសម្ភាសដូចម្ដេច? អ្នកណាត្រូវជួបណា ពេលវេលាកន្លែងណា? សូមដោយសង្ខេប។

**ផ៖** ការសម្ភាសនេះ គឺកើតឡើងបន្ទាប់ពីលោក អៀង សារី ត្រូវបានផ្ដាច់ខ្លួនជាផ្លូវការចេញពីកងកម្លាំងខ្មែរក្រហម ដើម្បីមកចូលរដ្ឋាភិបាល។ ហើយខ្ញុំមានមនុស្សទំនាក់ទំនងជាមួយលោក អៀង សារី តាមទូរស័ព្ទមួយចំនួនមុនពេលនោះទៅទៀត។ បន្ទាប់មកក្នុងខែធ្នូ ឆ្នាំ១៩៩៦ ខ្ញុំចូលរួមកិច្ចប្រជុំការសិក្សាមួយនៅប្រទេសអូស្ត្រាលី ខ្ញុំព្យាយាមចង់ជួបលោក អៀង សារី តាមដំណើរត្រឡប់ទៅអឺរ៉ុបវិញ ហើយខ្ញុំហៅគាត់ថា "តើខ្ញុំសូមសម្ភាសបានឬអត់?" គាត់ឆ្លើយថា "បាន"។ ខ្ញុំសួរថា "នៅកន្លែងណា?" គាត់ឆ្លើយថា "ប៉ៃលិន"។ "ពេលណា?" ខ្ញុំសួរគាត់ថា "គឺនៅថ្ងៃដូចដែលបញ្ជាក់នេះឯង"។ ហើយខ្ញុំបានធ្វើដំណើរទៅចាន់បុរី ហើយធ្វើដំណើរបន្តទៅប៉ៃលិន។ ហើយទាក់ទងតាមទូរស័ព្ទជាមួយគាត់ម្ដងទៀត គាត់ពន្យល់ថា អាជ្ញាធរថៃក៏មិនអនុញ្ញាតទៅប៉ៃលិនទេ។ បន្ទាប់ហើយ គាត់ត្រូវធ្វើដំណើរមកជួបខ្ញុំវិញ។ ហើយខ្ញុំរង់ចាំគាត់នៅសណ្ឋាគារមួយ។ ខ្ញុំត្រូវទៅចាំគាត់នៅសណ្ឋាគាររហូតទាល់តែគាត់មកជួប។ បន្ទាប់មក យើងបានសម្ភាសជាផ្លូវការ នៅក្នុងនោះមានអង្គរក្សគាត់អមមកជាមួយមាន អ៊ី ឈាន។ ហើយយើងបន្ទាប់ពីសម្ភាស យើងបានហូបអាហារ ហើយគាត់ក៏ត្រឡប់ទៅប៉ៃលិនវិញ។

[១៦:០១:២៣]

**ស៖** យើងអាចឃើញនៅខាងដើមឯកសារ E389 ប្រតិចារឹកមកពីខ្សែអាត់សំឡេង។ អ៊ីចឹងគឺថាឃើញមានព័ត៌មានមួយចំនួនដែលបង្ហាញពីអ្វីលោកបានពន្យល់ហ្នឹង។ តើមានអ្វីបញ្ជាក់ថែមទៀតទេ?

**ផ៖** ខ្ញុំមានកាសែតម៉ាញេតូចមួយសម្រាប់ថតសំឡេងកាលប្រើក្នុងសម័យនោះ ដើម្បីថតនោះ។

យើងបានប្រើកាសែតបីសម្រាប់សម្ភាស សរុបទាំងអស់ហ្នឹង។

**ស៖** ឥឡូវនេះ តើលោកអាចពន្យល់បន្ថែមបានទេនៅទំព័រទី៥? ដើម្បីកំណត់ពីពេលវេលាអំពីពេលដែលលោកសួរទៅលោក អៀង សារី នោះ។ សូមបំបែកអ៊ីចេះវិញ គាត់និយាយថា គាត់ត្រឡប់ -- គាត់ទៅប៉ៃលិន ហើយត្រឡប់មកវិញនៅឆ្នាំ១៩៧៤។ លោកសួរថា តើលោកៗបានដឹកនាំគណៈប្រតិភូសេដ្ឋកិច្ចទៅវៀតណាម ហើយទៅប៉េកាំងហ្នឹង តើលោកបានសួរពីរឿងហ្នឹងបន្ថែមទៀតទេ ពេលដែលជួបសម្ភាសគាត់នោះ?

[១៦:០២:៥៣]

**ឆ៖** ឥឡូវនេះ ខ្ញុំនិយាយស្មាន គឺថាប្រហែលជាចុងឆ្នាំ១៩៧៤ ពីរឿងឆ្នាំនោះ ប៉ុន្តែខ្ញុំមិនទាន់ច្បាស់ទេ។

**ស៖** បាទអរគុណ។ ឥឡូវនេះខ្ញុំចូលប្រធានបទផ្សេងមួយទៀតនិយាយអំពីការជម្លៀស។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរផ្នែកមួយនៃសៀវភៅមួយ។ ខ្ញុំបានពិនិត្យមើលម៉ោង។ តែមួយសំណួរតែប៉ុណ្ណោះទេលោកប្រធានបាទ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ បាទលោកទុកឯកសារមួយ យកសំណុំឯកសារទី៤ បាទនៅលើតុរបស់លោកនោះឯង។ បាទឯកសារទី៤ *ថេប*១។ ឯកសារ E190.1.398 ចំណងជើងថា "ការវាយតម្លៃពីតួនាទីមេដឹកនាំជាន់ខ្ពស់ ហើយនិងមន្ត្រីមូលដ្ឋាននៅក្នុងកម្ពុជាប្រជាធិបតេយ្យអំពីបទឧក្រិដ្ឋ គឺការទទួលខុសត្រូវកម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប"។ សូមអនុញ្ញាតឲ្យលោកពិនិត្យមើលទំព័រទី៦។

[១៦:០៤:៤៨]

ចំណងជើងផ្នែកនេះ គឺការគិតឡើងវិញអំពីការទទួលខុសត្រូវបទឧក្រិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងខ្ញុំដកស្រង់៖ "បញ្ហាកើតឡើងចាប់តាំងពីការដឹកនាំដំបូងរបស់បក្សកុម្មុយនីស្ត គឺគេកត់សម្គាល់អំពីការបង្ខិតបង្ខំអំពើហិង្សា ហើយនិងការជម្លៀសដោយបង្ខំចេញពីភ្នំពេញ និងទីប្រជុំជន តំបន់ផ្សេងៗទៀតដែលគ្រប់គ្រងដោយរបបចាស់របស់ លន់ នល់។ ដោយសេនាប្រមុខ លន់ នល់ ជាសាធារណរដ្ឋខ្មែរ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានបំណងធ្វើការជម្លៀសនេះ ប្រជាជននេះគឺដើម្បីលុបបំបាត់នូវសក្តិភូមិ ទីក្រុង គហបតី ហើយនិងអនុធន បញ្ញវន្ត វណ្ណៈទាំងឡាយ ដើម្បីគេអាច

ត្រួតត្រាលើខាងនយោបាយ អ្នកទាំងនោះឲ្យក្លាយទៅជាកសិករតាមជនបទ ហើយក្លាយទៅជាវណ្ណៈកម្មករ កសិករ នៅក្នុងបក្សរបស់ខ្លួន ដើម្បីបង្កើតឲ្យបានជាប្រជាជន ៩៩ភាគរយនៃប្រជាជនទាំងមូល"។ កំណត់លេខយោង១៦ គឺថា S2-*ម៉ាល* គឺបទសម្ភាសន៍ អ៊ុង ចុងហឿង នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៧ នៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មកការប្រមូលរបស់ឯកសារហ្នឹង គឺគេបានធ្វើការបកប្រែ។ តើលោកអាចបញ្ជាក់បានដែរឬទេ ថានេះជាប្រភពដែលលោកយកមកប្រើសម្រាប់សរសេរសៀវភៅរបស់លោកនោះ?

[១៦:០៦:៤៥]

**ឆ៖** បាទ។ ហើយគួរតែដាក់ថា ស-២១។

**ស៖** ឯកសារ គឺថា D313/1.2.251។ ព័ត៌មានបន្ថែមគឺថាសៀវភៅកំណត់ហេតុផ្ទាល់នេះគឺរបស់ ប៉ុន គឺមិនឲ្យលម្អិតពេកទេ គឺគ្រាន់តែនិយាយពិស្តារតែបន្តិចទេ បាទ។

**ឆ៖** នេះគឺជាពេល មុនពេលដែល ស៊ី.ឌី.ខេម គេធ្វើកាតាឡុកសៀវភៅ មានសៀវភៅកំណត់ដែលសរសេរដោយផ្ទាល់ដៃរបស់ ប៉ុន ដែលក្នុងចំណោមឯកសារជាច្រើន នៅក្នុងមជ្ឈមណ្ឌលឯកសារមិនទាន់បានធ្វើកាតាឡុកនៅឡើយកាលណោះ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយថាតែមួយសំណួរ ហើយខ្ញុំសូមបញ្ជាក់សេចក្តីសង្កេតមួយ គឺសំណើដែលធ្វើឡើងព្រឹកមិញនេះ គឺបានធ្វើឲ្យខាតពេល១ម៉ោងរបស់សហព្រះរាជអាជ្ញា។ ដូច្នេះខ្ញុំសូមតុលាការបន្ថែម១ម៉ោងជូនខ្ញុំវិញ។ សូមអរគុណលោកប្រធាន និងលោកសាក្សី ហេដឌ័រ។

**ប្រធានអង្គជំនុំ៖**

បាទ សំណើសុំនេះគឺមានមូលហេតុសមស្របហើយ អង្គជំនុំជម្រះនឹងផុសជួលឡើងវិញនូវពេលវេលាដែលខាងសហព្រះរាជអាជ្ញាបានបាត់បង់រយៈពេល១ម៉ោង កាលពីព្រឹកមិញនេះ។

[១៦:០៨:២២]

លោកតំណាងសហព្រះរាជអាជ្ញា ចុះឯកសារដែលលោកបានស្នើសុំផ្តល់ជូនទៅសាក្សីនូវឯកសារប៉ុន្មាន*ក្រណូ*នេះ តើគួរចាត់ចែងយ៉ាងដូចម្តេចនាពេលនេះ?

ឯកសារដែលលោកបានផ្តល់ជូនសាក្សីអម្បាញ់មិញនេះ ឥឡូវពេលវេលាត្រូវសម្រាកហើយ។ តើត្រូវការគ្រប់គ្រងឯកសារហ្នឹងយ៉ាងដូចម្តេច?

**លោក ឃីត វេយ៉ន័រ៖**

ខ្ញុំសូមជម្រាបថា យើងត្រូវរក្សាទុកនៅដដែល គឺថាយើងនឹងត្រូវប្រើ។ បាទ អ៊ីចឹង យើងយកត្រឡប់ទៅវិញ ហើយពេលជួបគាត់ យើងយកមកជូនគាត់វិញ។ តើអាចត្រឹមត្រូវទៅតាមនីតិវិធីដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញាដែលបានបង្ហាញឲ្យច្បាស់លាស់។ អ៊ីចឹងគឺក្រោយពេលចប់ហ្នឹង គឺសូមខាងផ្នែកមន្ត្រីជំនួយរបស់ខាងសហព្រះរាជអាជ្ញាដកយកឯកសារដែលនៅជិតសាក្សីនេះយកមករក្សាវិញ ហើយដល់ពេលពិភាក្សាដេញដោលនៅថ្ងៃស្អែកសឹមផ្តល់ឲ្យគាត់ជាបន្តទៀត ប្រសិនបើត្រូវការប្រើប្រាស់ឯកសារនោះដូចនៅរសៀលនេះ។

[១៦:០៩:៥០]

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ សម្រាប់សវនាការថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃ ព្រហស្បតិ៍ ទី១១ ខែកក្កដា ឆ្នាំ២០១៣ ហើយថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស្មីវ ហេងឌ័រ ដែលនឹងបន្តសួរដេញដោលដោយភាគីសហព្រះរាជអាជ្ញា។ សូមភាគីនៃរឿងក្តី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

លោកស្មីវ ហេងឌ័រ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស្មីវ ហេងឌ័រ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែក លោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម

និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១១ នាទី)*